# ធម៌សូត្រផ្សេងៗ

ចេះចាំដោយឧបាសិកា យស់ ណា

នៅអាស្រមកម្ពួបថ ឃុំបន្ទាយដែក

ស្រុកកៀនស្វាយ ខេត្តកណ្ដាល

ព. ស. ២៥៥១ គ. ស. ២០០៧

# ធម៌សូត្រផ្សេងៗ

ចេះចាំដោយឧបាសិកា យស់ ណា

ជំនួយការបោះពុម្ពដោយភិក្ខុ សុន្ទរ៍ សាមឿន

ព.ស. ២៥៥១ គ.ស. ២០០៨

# ធម៌សូត្រផ្សេងៗ

ចេះចាំដោយឧបាសិកា យស់ ណា

នៅអាស្រមកម្ពុបថ

ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល

ជំនួយការបោះពុម្ពដោយភិក្ខុ សុន្ទរ៍ សាមឿន

ព. ស. ២៥៥១ គ. ស. ២០០៨

# ពាក្យប្រារព្ធ

ខ្ញុំព្រះករុណា សូមនមស្ការ ឧទ្ទិសដៅចំពោះគុណព្រះរតន-ត្រ័យកែវទាំង ៣ គឺព្រះពុទ្ធរតនៈ ១ ព្រះធម្មរតនៈ ១ ព្រះសង្ឃ-រតនៈ ១ ដោយសេចក្តីគោរព ។ សូមក្រាបថ្វាយបង្គំព្រះបញ្ញា-គុណ ព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដោយសេចក្តីជ្រះថ្លា សូមក្រាបថ្វាយបង្គំនូវព្រះសព្វញ្ញុតញ្ញាណ ដែលព្រះអង្គត្រាស់ដឹងលើភពទាំងបី ព្រះអង្គជាព្រះទក្ខិណេយ្យបុគ្គលដ៏ប្រសើរលើលោក ព្រះអង្គជាព្រះអច្ឆរិយបុគ្គលដ៏ឆ្នើមលើលោក ព្រះអង្គជាទីពឹងនៃសត្វលោក ព្រះអង្គជាស្តេចនៃអ្នកប្រាជ្ញ ។ សូមក្រាបថ្វាយបង្គំព្រះពុទ្ធវចនៈទាំងអស់ ដែលហូរចេញពីព្រះឱស្ឋទិព្វថ្លៃ ដោយសេចក្តីគោរព ដោយសេចក្តីជ្រះថ្លា កោតក្រែងស្ងប់ស្ងែងជាទីបំផុតរបស់ខ្ញុំព្រះករុណា ។

កុសលទាំងអស់នេះ សូមឱ្យបានជាធម្មបណ្ណាការ សក្ការៈបូជាថ្វាយដល់ព្រះសម្មាសម្ពុទ្ធ សូមព្រះអង្គទ្រង់ជ្រាប ទ្រង់ទទួលដោយសេចក្តីអនុគ្រោះ ។ កុសលទាំងអស់នេះ សូមឧទ្ទិសជូនមាតាបិតាជីដូនជីតា សាច់សាលោហិតទាំអស់របស់ខ្ញុំ និងសព្វសត្វទាំងអស់ក្នុងលោក សូមឱ្យបាននូវសេចក្តីស្ងប់ជានិរន្តរ៍ ។

ចាប់សរសេរនៅថ្ងៃសុក្រ ៤ កើត ខែពិសាខ ឆ្នាំកុរ

ព.ស. ២៥៥០ ត្រូវនឹងខែមេសា គ.ស. ២០០៧

# ធម៌សូត្រផ្សេងៗ


មាតិកាធម៌ ទំព័រ

អញ្ជើញពពួកទេវតា ..... ..... ..... ..... ..... ..... ១

បទសរភញ្ញ ..... ..... ..... ..... ..... ..... ..... .. ៣

បូជាគ្រឿងសក្ការៈឥតមានទៀនធូប ..... ..... ..... ..... ៤

បូជាគ្រឿងសក្ការៈមានទៀនធូប ..... ..... ..... ..... ... ៤

គារវៈ ៦ យ៉ាង ..... ..... ..... ..... ..... ..... ..... . ៥

សង្វេជនីយដ្ឋានទាំង ៤ តំបន់ ..... ..... ..... ..... .... ៦

រំលឹកព្រះគុណកែវទាំង ៣ ..... ..... ..... ..... ..... .. ៦

ថ្វាយបង្គំព្រះពុទ្ធរតនៈ ..... ..... ..... ..... ..... ..... ៧

ប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា ..... ..... ..... .. ១១

ខមាទោសចំពោះព្រះពុទ្ធ ..... ..... ..... ..... ..... .. ១២

ថ្វាយបង្គំព្រះធម្មរតនៈ ..... ..... ..... ..... ..... .... ១៣

ឱនកាយហើយតាំងចិត្តរលឹកដល់ធម្មគុណថា ..... ..... ..១៤

ប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា ..... ..... ..... .. ១៦

ខមាទោសចំពោះព្រះធម៌ ..... ..... ..... ..... ..... .. ១៦

ថ្វាយបង្គំព្រះសង្ឃរតនៈ ..... ..... ..... ..... ..... .. ១៧

ឱនកាយវាចាហើយ តាំងចិត្តរលឹកដល់សង្ឃគុណថា ..... ១៩
ប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា ..... ..... ..... ២២
ខមាទោសចំពោះព្រះសង្ឃ ..... ..... ..... ..... ... ២២
អារក្ខកម្មដ្ឋាន កម្មដ្ឋានគួររក្សារឿយៗ ..... ..... ..... . ២៥
នមស្ការនូវព្រះពុទ្ធបាទ ..... ..... ..... ..... ..... ... ២៧
សីលមានអង្គ ៨ ..... ..... ..... ..... ..... ..... ... ៣០
អភិណ្ហប្បច្ចវេក្ខណសូត្រ ..... ..... ..... ..... ..... ... ៣១
បារមី ១០ ឬ ៣០ ..... ..... ..... ..... ..... ..... ... ៣៤
ទសជាតិ និង បារមី ១០ ឬ ៣០ ..... ..... ..... ..... .. ៣៦
នមស្ការព្រះរតនត្រ័យ បណាមគាថា ..... ..... ..... ... ៤៦
ថ្វាយបង្គំសុំសេចក្ដីសុខ ..... ..... ..... ..... ..... ... ៤៨
បត្តិទានគាថា (យំ កិញ្ចិ) ..... ..... ..... ..... ..... ... ៤៩
ចែកនូវបុណ្យកុសល ..... ..... ..... ..... ..... ..... ៥១
បត្ថនាគាថា (ឥមិនា) ..... ..... ..... ..... ..... ..... ៥២
បត្ថនាគាថា (ឥមិនា) ប្រែម្យ៉ាងទៀត ..... ..... ..... ... ៥៥
បត្តិទានគាថា (យា ទេវតា) ..... ..... ..... ..... ..... ៥៨
កុសលខ្ញុំសាង ..... ..... ..... ..... ..... ..... ..... ៦០

ធម៌ឧទ្ទិស្សផល ..... ..... ..... ..... ..... ..... ..... ៦២

អនុមោទនារក្ខាយាចនគាថា ..... ..... ..... ..... .... ៦៣

ផ្សាយមេត្តាចំពោះទិសទាំង ១០ ..... ..... ..... ...... ៦៥

ខមាបនគាថា (ពាក្យសូមទោសចំពោះសត្វ) ..... ..... .. ៦៨

នមស្ការដោយសង្ខេប ពុទ្ធគុណ ..... ..... ..... ..... . ៧០

ធម្មគុណ ..... ..... ..... ..... ..... ..... ..... ..... ៧១

សង្ឃគុណ ..... ..... ..... ..... ..... ..... ..... ... ៧២

អដ្ឋង្គិកមគ្គប្រកបដោយអង្គ ៨ ..... ..... ..... ....... ៧៣

កិច្ចរបស់មគ្គ មាន ៤ គឺ: ..... ..... ..... ..... ..... .. ៧៨

ទេវធម៌ ..... ..... ..... ..... ..... ..... ..... ..... ៧៩

គុណព្រះនិព្វាន ..... ..... ..... ..... ..... ..... ..... ៨០

ពាក្យអារាធនាព្រះភិក្ខុសង្ឃ សូមឱ្យចម្រើនព្រះបរិត្ត ..... ៨២

ប្រារព្ធនូវធម្មចក្កប្បវត្តនសូត្រ ..... ..... ..... ..... ... ៨៣

ព្រះធម្មចក្កប្បវត្តនសូត្រ ..... ..... ..... ..... ..... ... ៨៥

ប្រារព្ធនូវអនត្តលក្ខណសូត្រ ..... ..... ..... ..... .... ១០៩

អនត្តលក្ខណសូត្រ ..... ..... ..... ..... ..... ..... ១១០

ប្រារព្ធនូវអាទិត្តបរិយាយសូត្រ ..... ..... ..... ..... . ១២៨

អាទិត្តបរិយាយសូត្រ ..... ..... ..... ..... ..... ... ១២៩

គិរិមានន្ទសូត្រ ..... ..... ..... ..... ..... ..... .... ១៤៥

ប្រារព្ធនូវរតនសូត្រ ..... ..... ..... ..... ..... ..... ១៧០

រតនសូត្រ ..... ..... ..... ..... ..... ..... ..... . ១៧២

ព្រះត្រៃសរណគមន៍ ..... ..... ..... ..... ..... ... ១៨៥

នមស្ការព្រះពុទ្ធច្រើនព្រះអង្គ ..... ..... ..... ..... ...១៨៦

ពាក្យប្រារព្ធនូវមង្គលសូត្រ ..... ..... ..... ..... .... ១៨៩

មង្គលសូត្រ ..... ..... ..... ..... ..... ..... .... ១៩២

ប្រកាសនូវករណីយមេត្តសូត្រ ..... ..... ..... ....... ១៩៨

ករណីយមេត្តសូត្រ ..... ..... ..... .......... ..... ១៩៨

អាដានាដិយបរិត្ត ..... ..... ..... ..... ..... ..... ២០៣

មង្គលចក្កវាឡ ..... ..... ..... ..... ..... ..... .. ២១០

ជយបរិត្តគាថា ..... ..... ..... ..... ..... ..... .. ២១៧

អភយបរិត្តគាថា ..... ..... ..... ..... ..... ..... ២១៩

អាដានាដិយបរិត្តគាថា ..... ..... ..... ..... ...... ២២២

យានទានានុមោទនាគាថា ..... ..... ..... ..... ... ២២៣

ភត្តានុមោទនារម្ភគាថា ..... ..... ..... ..... ..... ២២៥

សិទ្ធិយាចនគាថា ..... ..... ..... ..... ..... ..... ២២៧
អគ្គប្បសាទសុត្តគាថា ..... ..... ..... ..... ....... ២២៧
ភោជនទានានុមោទនាគាថា ..... ..... ..... ..... .. ២២៩
ជីវភត្តានុមោទនាគាថា ..... ..... ..... ..... ..... ២៣០
សាមញ្ញានុមោទនាគាថា ..... ..... ..... ..... ..... ២៣១
មង្គលចក្កវាឡ ..... ..... ..... ..... ..... ..... .. ២៣២
ពិចារណានូវគ្រឿងឧបភោគ-បរិភោគ ..... ..... ..... ២៣៥
បដិច្ចសមុប្បាទ ..... ..... ..... ..... ..... ..... .. ២៤៩
បឋមពុទ្ធវចនៈ ..... ..... ..... ..... ..... ..... .. ២៥៦
បច្ឆិមពុទ្ធវចនៈ ..... ..... ..... ..... ..... ..... .. ២៥៧
ភាសិតោវាទសង្ខេប ..... ..... ..... ..... ..... ... ២៦០
ពុទ្ធជយមង្គល ..... ..... ..... ..... ..... ..... .. ២៧១
អារាធនាព្រះធម្មកថិក ..... ..... ..... ..... ..... .. ២៧៨
សុភមង្គលគាថា ..... ..... ..... ..... ..... ..... ២៨៣
បរាភវសូត្រ ..... ..... ..... ..... ..... ..... ..... ២៨៤
បុញ្ញភាគប្បដិបត្តិ ..... ..... ..... ..... ..... ..... .. ២៩៥
វិធីសុំសីល ..... ..... ..... ..... ..... ..... ..... ៣០៤
អង្គនៃសីល ៥ ឬនិច្ចសីល ..... ..... ..... ..... .... ៣១៨

អង្គនៃសីល ៨ ឬ ឧបោសថសីល ..... ..... ..... .... ៣២០

អកុសលកម្មបទ ១០ យ៉ាង ..... ..... ..... ..... ... ៣២៤

កុសលកម្មបទ ១០ យ៉ាង ..... ..... ..... ..... .... ៣២៦

អង្គនៃអកុសលកម្មបថ ..... ..... ..... ..... .... .. ៣២៨

ពាក្យថា ឧបោសថ ..... ..... ..... ..... ..... ..... ៣៣១

គុណនៃឧបាសក ១០ យ៉ាង ..... ..... ..... ..... ... ៣៣៧

សំណួរ និង ចម្លើយ ..... ..... ..... ..... ..... ... ៣៣៩

បុញ្ញកិរិយាវត្ថុ ១០ គឺ : ..... ..... ..... ..... ..... ៣៤១

ថ្ងៃបូជា ..... ..... ..... ..... ..... .......... ... ៣៤៣

វដ្ដវធំ១ មាន ៣ យ៉ាង គឺ : ..... ..... .......... ..... ៣៤៩

អភិធម្មបិដក ធម្មសង្គណី ..... ..... ..... ..... ..... ៣៥១

វិភង្គ ក្នុងអដ្ឋកថា ..... ..... ..... ..... ..... ..... ៣៥៧

ធាតុកថា ក្នុងអដ្ឋកថា ..... ..... ..... ..... ..... .. ៣៥៨

បុគ្គលប្បញ្ញត្តិ ក្នុងអដ្ឋកថា ..... ..... .......... ..... ៣៦១

កថាវត្ថុ ក្នុងអដ្ឋកថា ..... ..... ..... ..... ..... .....៣៦១

យមកៈ ក្នុងអដ្ឋកថា ..... ..... .......... ..... ..... ៣៦២

បដ្ឋាន ក្នុងអដ្ឋកថា ..... ..... ..... ..... ..... ..... ៣៦៣

ខន្ធវិភង្គ ក្នុងបាលី ..... ..... ..... ..... ..... ..... ៣៦៥

ធាតុកថា ក្នុងបាលី ..... ..... ..... ..... ..... ... ៣៦៩

បុគ្គលប្បញ្ញត្តិ ក្នុងបាលី ..... ..... ..... ..... ..... ៣៧៣

កថាវត្ថុ ក្នុងបាលី ..... ..... ..... ..... ..... ..... ៣៨១

យមកៈ ក្នុងបាលី ..... ..... ..... ..... ..... ..... ៣៨៦

បដ្ឋាន ក្នុងបាលី ..... ..... ..... ..... ..... ..... ៣៩១

សំវេជនីយគាថា ..... ..... ..... ..... ..... ..... ៣៩៥

# អញ្ជើញពួកទេវតា

សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហ-វត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ ។

ប្រែថា: ទេវតាទាំងឡាយដែលស្ថិតនៅក្នុងឋាន សួគ៌ដែលជាកាមភព និងរូបភពក្តី ភុម្មទេវតាទាំងឡាយ ដែលឋិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ឰដ៏អាកាសក្តី នៅនាកោះ និងដែន និងស្រុកក្តី នៅនាដើមព្រឹក្សា និងព្រៃញាតស្បាត ឬទីស្រែចំការក្តី យក្ខ និងគន្ធព្វ និងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹក ទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញមកប្រជុំគ្នា (ក្នុងទីនេះ) ពាក្យឯណា ដែលជាពាក្យព្រះសាក្យមុនីដ៏ប្រសើរ (ដែលយើងខ្ញុំនឹងសូត្រឥឡូវនេះ) លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ (អំពីសំ-ណាក់) នៃខ្ញុំដោយគោរព ។

ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌ ។

ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌ ។

ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌

## សម្ពុទ្ធេ

សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ បញ្ចសតសហស្សានិ នមាមិ សិរសា អហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨ ព្រះអង្គផង ១ ម៉ឺន ២ ពាន់ព្រះអង្គផង ៥ សែនព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។

តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ**

**អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំង-ឡាយជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

**សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិសហស្សកេ**

**ទសសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំង-ឡាយ ៥៥ ព្រះអង្គផង ២ ម៉ឺន ៤ ពាន់ព្រះអង្គផង ១ លានព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ**

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ**

**អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រព្យទាំងឡាយទាំងពួង ទាំងសេចក្តី អន្តរាយទាំងឡាយ ជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

**សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ**

**វីសតិសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំង-ឡាយ ១០៩ ព្រះអង្គផង ៤ ម៉ឺន ៨ ពាន់ព្រះអង្គផង ២ លានព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ**

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ**

**អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំង-ឡាយ ជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ

# ពាក្យប្រាប់ព្រួនខមង្គលសូត្រ

**យេ សន្តា សន្តចិត្តា តិសរណសរណា ឯត្ថ លោកន្តរេ វា ភុម្មា ភុម្មា ច ទេវា គុណគណគ-ហណព្យាវដា សព្វកាលំ** ទេវតាទាំងឡាយឯណា ជាភុម្ម-ទេវតាក្តី មិនមែនជាភុម្មទេវតាក្តី ជាអ្នកមានចិត្តស្ងប់ មានព្រះរតនត្រ័យជាទីពឹងទីរឭក ដែលមាននៅក្នុងលោកនេះ ឬក្នុងចន្លោះនៃលោក ជាអ្នកខ្វល់ខ្វាយ ក្នុងកិរិយាកាន់យកនូវពពួកនៃគុណសព្វៗ កាល ។

**ឯតេ អាយន្តុ ទេវា វរកនកមយេ មេរុរាជេ វសន្តោ សន្តោ សន្តោ សហេតុំ មុនិវរវចនំ សោតុមគ្គំ សមគ្គំ** សូមទេវតាទាំងឡាយនោះ អញ្ជើញមក ម្យ៉ាងទៀត ទេវតាដែលស្ថិតនៅលើភ្នំមេរុរាជ សុទ្ធសឹងតែមាសដ៏ប្រសើរ សូមអញ្ជើញមកផង សូមទេវតាជាសប្បុរសទាំងឡាយ អញ្ជើញមកកាន់ទីសមាគម ដើម្បីស្តាប់នូវពាក្យនៃ

ព្រះមុនីដ៏បវរ ជាធម៌ដ៏ប្រសើរ លើសជាហេតុនាំឱ្យកើតសេចក្ដីត្រេកអរ ។

សព្វេសុ ចក្កវាឡេសុ យក្ខា ទេវា ច ព្រហ្ម-
នោ យំ អម្ហេហិ កតំ បុញ្ញំ សព្វសម្បត្តិ សាធកំ

បុណ្យឯណាដែលយើងបានធ្វើហើយ ជាបុណ្យអាចឱ្យសម្រេចនូវសម្បត្តិទាំងពួង សូមយក្ខទាំងឡាយផង ទេវតាទាំងឡាយផង ព្រហ្មទាំងឡាយផង ក្នុងចក្រវាឡទាំងអស់ (អនុមោទនាត្រេក-អរនឹងបុណ្យនោះ) ។

សព្វេ តំ អនុមោទិត្វា សមគ្គា សាសនេ រតា
បមាទរហិតា ហោន្តុ អារក្ខាសុ វិសេសតោ

យក្ខ និងទេវតា និងព្រហ្មទាំងអស់ កាលបើបានអនុមោទនានូវបុណ្យនោះហើយ ចូរព្រមព្រៀងគ្នាត្រេកអរ ក្នុងព្រះពុទ្ធ-សាសនា ហើយចូរប្រាសចាកសេចក្ដីប្រហែសធ្វេស ក្នុងការរក្សា (នូវព្រះពុទ្ធសាសនា) ដោយឧបាយដ៏វិសេស ។

សាសនស្ស ច លោកស្ស វុឌ្ឍី ភវតុ សព្វទា
សាសនម្បិ ច លោកញ្ច ទេវា រក្ខន្តុ សព្វទា

សូមឱ្យសេចក្តីចម្រើន កើតមានដល់ព្រះពុទ្ធសាសនាផង ដល់សត្វលោកផង ឱ្យបានសព្វៗកាលទៅ សូមទេវតាទាំងឡាយ អភិបាលរក្សានូវព្រះពុទ្ធសាសនាផង នូវសត្វលោកផង ឱ្យបាន សព្វៗ កាល រៀងទៅ ។

**សទ្ធី ហោន្តុ សុខី សព្វេ បរិវារេហិ អត្តនោ**

**អនីឃា សុមនា ហោន្តុ សហ សព្វេហិ ញាតីភិ**

សព្វសត្វទាំងអស់ ព្រមទាំងបរិវារទាំងឡាយរបស់ខ្លួន សូមឱ្យ មានសេចក្តីសុខស្រួល សូមឱ្យជាអ្នកឥតមាន សេចក្តីទុក្ខភ័យ ជាអ្នកមានចិត្តល្អ ព្រមទាំងជនជាញាតិសន្តានទាំងអស់គ្នា ។

**យញ្ច ទ្វាទស វស្សានិ ចិន្តយិំសុ សទេវកា**

**ចិរស្សំ ចិន្តយន្តាបិ នេវ ជានឹសុ មង្គលំ**

**ចក្កវាឡសហស្សេសុ ទសសុ យេន តត្តកំ**

**កាលំ កោលាហលំ ជាតំ យាវ ព្រហ្មនិវេសនា**

មនុស្សព្រមទាំងទេវតាទាំងឡាយ បាននាំគ្នាគិតរក នូវ មង្គលឯណា អស់ ១២ ឆ្នាំ មនុស្ស និងទេវតាទាំងនោះ ក្នុង ១ ម៉ឺនចក្រវាឡ ទោះខំប្រឹងគិតអស់កាលយូរ ម្ល៉ោះក៏នៅតែមិន

ដឹងនូវមង្គលនោះត្រឹមណា វីកោលាហលក៏កើត រហូតដល់ភព ជាទីនៅនៃព្រហ្ម អស់កាលត្រឹមណោះឯង ។

**យំ លោកនាថោ ទេសេសិ សព្វបាបវិនាសនំ**
**យំ សុត្វា សព្វទុក្ខេហិ មុញ្ចន្តា សំខិយា នរា**
**ឯវមាទិគុណូបេតំ មង្គលន្តម្ភណាម ហេ**

ព្រះបរមលោកនាថ ទ្រង់ត្រាស់សម្ដែងហើយនូវមង្គលឯណា ដែលជាគ្រឿងញាំងបាបទាំងពួងឱ្យវិនាស នរជនទាំងឡាយ រាប់ចំនួនមិនបានស្ដាប់នូវមង្គលឯណា ហើយបានរួចចាកទុក្ខទាំង-ពួង ម្នាលទេវតាទាំងឡាយ យើងពោលឥឡូវនេះ នូវមង្គលនោះ ដ៏ប្រកបដោយគុណមានយ៉ាងនេះជាដើម

# មង្គលសូត្រ

**ឯវម្មេ សុតំ** (សូត្រនេះឈ្មោះមង្គលសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្ដាប់មកហើយយ៉ាងនេះថា

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិក-សេដ្ឋីទៀបក្រុងសាវត្ថី ។

អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ លំដាប់នោះឯង ទេវតាអង្គ ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញ៉ាំងវត្តជេតពនជុំវិញទាំងអស់ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះ អង្គព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

**ឯកមន្តំ បិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** កាលទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា(យ៉ាងនេះ)ថា:

**ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ**
**អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។**

ទេវតា និងមនុស្សទាំងឡាយជាច្រើនប្រាថ្នានូវ សិរីសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាសម្តែងប្រាប់នូវមង្គលដ៏ឧត្តម (ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សម្តែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះ) ថា:

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**
**បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។**

កិរិយាមិនសេពគប់ នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គល ជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា

អត្តសម្មាបណីធិ ច ឯតម្មង្គលមុត្តមំ

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ

សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយ ដោយច្រើន ១ សិល្ប៍សាស្ត្រ គឺសេចក្តីឆ្លៀវឈ្លាសក្នុងហត្ថកម្ម របស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សា ដោយប្រពៃ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ

អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ

កិរិយាបំរើនូវមាតា ១ កិរិយាបំរើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រ និងភរិយា ១ ការងារទាំងឡាយ ដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។

កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តិនូវធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយ ដែលមិនមានទោស ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១ សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។

សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រ-ព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន១ កិរិយាស្តាប់នូវធម៌តាមកាល ១ ទាំង ៥ នេះ ជាមង្គលដ៏ឧត្តម ។

ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។

សេចក្តីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ
និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។

សេចក្តីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយ ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធូលី

គឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។**

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តីក្នុងទីទាំងពួង (ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់ នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្សទាំងអម្បាលនោះ ជាមង្គលដ៏ឧត្តម

# ពាក្យប្រកាសនូវករណីយមេត្តសូត្រ

**យស្សានុភាវតោ យក្ខា នេវ ទស្សេន្តិ ភីសនំ**

យក្ខទាំងឡាយ មិនហ៊ានសំដែងនូវអាការៈគួរខ្លាចឡើយ ព្រោះអានុភាពនៃព្រះបរិត្តឯណា ។ **យម្ហិ ចេវានុយុញ្ជន្តោ រត្តិន្ទិវមតន្ទិតោ** ម្យ៉ាងទៀត បុគ្គលមិនខ្ជិលច្រអូសក្នុងយប់

និងថ្ងៃ ហើយព្យាយាមរៀនសូត្រ នូវព្រះបរិត្តឯណា ។ **សុខំ សុបតិ សុត្តោ ច បាបំ កិញ្ចិ ន បស្សតិ** កំពុងដេកលក់ ឬលក់រួចហើយ ក៏ជាសុខ រមែងមិនឃើញនូវសុបិន ក៏អាក្រក់តិចតួច ។

**ឯវមាទិគុណូបេតំ បរិត្តន្តម្ភណាម ហេ** យើងទាំងឡាយសូត្រឥឡូវនេះ នូវព្រះបរិត្តនោះ ដែលប្រកបដោយគុណទាំងឡាយ មានយ៉ាងនេះជាដើម

# ករណីយមេត្តសូត្រ

**ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិ-សមេច្ច** កិច្ចឯណា (ដែលព្រះអរិយៈ) បានត្រាស់ដឹង នូវកោដ្ឋាសៈនៃធម៌ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន បានធ្វើហើយ កិច្ចនោះ គឺកុលបុត្រ អ្នកឈ្លាសក្នុងប្រយោជន៍ គួរធ្វើ ។ **សក្កោ ឧជូ ច សុហុជូ ច** កុលបុត្រនោះ ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និងវាចាផង ត្រង់ល្អដោយចិត្តផង ។ **សុវចោ**

ចស្ស មុទុ អនតិមានី ជាអ្នកប្រដៅងាយផង សុភាពទន់-ភ្លន់ផង មិនមានមានះ ដ៏ក្រៃលែងផង ។ សន្តុស្សកោ ច សុភរោ ច ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង ។ អប្ប-កិច្ចោ ច សល្លហុកវុត្តិ ជាអ្នកមានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាល (ក្នុងកាយ និងចិត្តផង) ។ សន្តិន្ទ្រិយោ ច និបកោ ច ជាអ្នកមានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង ។ អប្បគព្ភោ សុលេសុ អននុគិទ្ធោ ជាអ្នកមិនឆ្គងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង ។ ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ វិញ្ញូជនទាំងឡាយគួរតិះដៀលនូវជនទាំងឡាយដទៃដោយកម្មឯណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមកសូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្ត ចំពោះពពួកនៃសត្វថា) សុខិនោ វា ខេមិនោ ហោតុ សព្វេ សត្តា ភវន្តុ សុខិតត្តា សត្វទាំងឡាយទាំងពួង សូមឱ្យមានសេចក្ដីសុខ ឱ្យមានសេចក្ដីក្សេម ឱ្យមាន

ខ្លួនដល់នូវសេចក្តីសុខចុះ ។ **យេ កេចិ បាណភូតត្ថិ តសា វា ថាវរា វា អនវសេសា** សត្វមានជីវិតទាំងឡាយឯណា ឥតមានសេសសល់ ទោះសត្វដែលជាអ្នកមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី ជាអ្នកមាំមួន គឺឥតមានតណ្ហាក្តី ។ **ទីឃា វា យេ មហន្តា វា** សត្វទាំងឡាយឯណា មានកាយវែងក្តី ធំក្តី ។ **មជ្ឈិមា រស្សកា អនុកថូលា** មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយដ៏ស្តួម ឬធាត់ក្តី ។ **ទិដ្ឋា វា យេ ច អទិដ្ឋា** សត្វទាំងឡាយឯណា ដែលយើងឃើញក្តី មិនឃើញក្តី ។ **យេ ច ទូរេ វសន្តិ អវិទូរេ** សត្វទាំងឡាយឯណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ។ **ភូតា វា សម្ភវេសី វា** ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី ។ **សព្វេ សត្តា ភវន្តុ សុខិតត្តា** សត្វទាំងឡាយទាំងពួង សូមឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ **ន បរោ បរំ និកុព្វេថ** សត្វដទៃមិនគួរកំហែងបៀតបៀន នូវសត្វដទៃឡើយ ។ **នាតិ-**

មញ្ញេថ កត្ថចិ នំ កិញ្ចិ មិនគួរមើលងាយគេតិចតួច ក្នុងទីណាមួយឡើយ ។ ព្យារោសនា បដិឃសញ្ញា នាញ្ញ-មញ្ញស្ស ទុក្ខមិច្ឆេយ្យ មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានឹងគ្នា ដោយសេចក្តីក្រេវក្រោធ និងដោយបដិឃសញ្ញា គឺសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ ។ មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយដោយអាយុ គឺថាសូម្បីជីវិត ក៏ហ៊ានលះបង់ក្នុងការរក្សានូវបុត្របាន យ៉ាងណាមិញ ។ ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណ ចំពោះទៅរកសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង ។ មេត្តញ្ច សព្វលោកស្មឹ មាន-សម្ភាវយេ អបរិមាណំ ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ បុគ្គលគួរចម្រើននូវមេត្តាចិត្តមិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមាន

សត្រូវទៅក្នុងលោកទាំងអស់ គឺក្នុងខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្តាលផង ។

**តិដ្ឋញ្ចរំ និសិន្នោ វា សយានោ វា យាវ តស្ស វិគតមិទ្ធោ** (បុគ្គលអ្នកចម្រើននូវមេត្តាចិត្តនោះ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាស ហើយ គឺថា ជាអ្នកមិនដេកលក់ អស់កាលត្រឹមណា ។ **ឯតំ សតឹ អធិដ្ឋេយ្យ** គួរដំកល់នូវមេត្តានុស្សតិនុ៎ះ (អស់កាលត្រឹមនោះ)។ **ព្រហ្មមេតំ វិហារំ ឥធ មាហុ** បណ្ឌិតទាំងឡាយពោលនូវកិរិយានុ៎ះថាជាព្រហ្មវិហារក្នុងសាសនានេះ ។

**ទិដ្ឋិញ្ច អនុបគម្ម សីលវា ទស្សនេន សម្បន្នោ កាមេសុ វិនេយ្យ គេធំ នហិជាតុ គព្ភសេយ្យំ បុនរេតីតិ** (បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនដល់ស៊ប់នូវទិដ្ឋិ ជាអ្នកមានសីលប្រកបដោយទស្សនសម្ប័ទ គឺសោតាបត្តិ-មគ្គបន្ទោបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់គព្ភសេយ្យាសៈ គឺថា មិនកើតក្នុងគភ៌ទៀតឡើយ

# អាដានាដិយបរិត្ត

(វិបស្សិស្ស នមត្ថុ ។បេ។ មហន្តំ វីតសារទំ មានហើយ)

**នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ (ព្រះសម្ពុទ្ធទាំងនោះ គឺ)

**តណ្ហង្ករោ មហាវីរោ** ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ ។

**មេធង្ករោ មហាយសោ** ព្រះមេធង្ករ ព្រះអង្គមានយសធំ ។

**សរណង្ករោ លោកហិតោ** ព្រះសរណង្ករ ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់សត្វលោក ។

**ទីបង្ករោ ជុតិន្ធរោ** ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង ។

**កោណ្ឌញ្ញោ ជនបាមោក្ខោ** ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន ។

**មង្គលោ បុរិសោសភោ** ព្រះមង្គល ព្រះអង្គជាបុរសដ៏ប្រសើរ ។

**សុមនោ សុមនោ ធីរោ** ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញ មានព្រះហឫទ័យដ៏ល្អ ។

**រេវតោ រតិវឌ្ឍនោ** ព្រះរេវតៈ ព្រះអង្គញ៉ាំងសេចក្តីត្រេកអរឱ្យចម្រើន ។

**សោភិតោ គុណសម្បន្នោ** ព្រះសោភិតៈ ព្រះអង្គបរិបូណ៌ ដោយព្រះគុណ ។

**អនោមទស្សី ជនុត្តមោ** ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន ។

**បទុមោ លោកបជ្ជោតោ** ព្រះបទុមៈ ព្រះអង្គញ៉ាំងលោកឱ្យភ្លឺស្វាង ។

**នារទោ វរសារថី** ព្រះនារទៈ ព្រះអង្គដូចជាសារថីដ៏ប្រសើរ ។

**បទុមុត្តរោ សត្តសារោ** ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពពួកសត្វ ។

**សុមេធោ អប្បដិបុគ្គលោ** ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន ។

**សុជាតោ សព្វលោកគ្គោ** ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង ។

**បិយទស្សី នរាសភោ** ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន ។

**អត្ថទស្សី ការុណិកោ** ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត ។

**សិទ្ធត្ថោ អសមោ លោកេ** ព្រះសិទ្ធត្ថៈ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក ។

**តិស្សោ ច វទតំ វរោ** ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសំដីទាំងឡាយ ។

**ផុស្សោ ច វរទោ ពុទ្ធោ** ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ ។

**វិបស្សី ច អនូបមោ** ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណា ប្រៀបផ្ទឹមបានឡើយ ។

**សិខី សព្វហិតោ សត្ថា** ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឱ្យជាប្រយោជន៍ដល់សត្វទាំងពួង ។

**វេស្សភូ សុខទាយកោ** ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ ។

**កកុសន្ធោ សត្ថវាហោ** ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស ។

**កោនាគមនោ រណញ្ជហោ** ព្រះកោនាគមនៈ ព្រះអង្គបំបាក់នូវសត្រូវ គឺកិលេស ។

**កស្សបោ សិរិសម្បន្នោ** ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី ។

**គោតមោ សក្យបុង្គវោ** ព្រះគោតមៈ ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ។

(ឯតេ ចញ្ញេ ច សម្ពុទ្ធា ។បេ។ និព្វុតោ ចតុរំ ភវ មានហើយ)។

**តេសំ សច្ចេន សីលេន ខន្តិមេត្តាពលេន ច** ដោយសច្ចៈផង ដោយសីលផង ដោយកម្លាំងនៃខន្តី និងមេត្តាផង នៃព្រះសម្ពុទ្ធទាំងឡាយនោះ ។

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច** ព្រះសម្ពុទ្ធទាំងឡាយនោះ សូមបីបាច់រក្សា នូវអ្នកទាំងឡាយដោយមិនមានរោគផង ឱ្យមានសេចក្ដីសុខផង ។

**បុរត្ថិមស្មឹ ទិសាភាគេ សន្តិ ភូតា មហិទ្ធិកា** ភូត គឺគន្ធព្វទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងកើត ។

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច

គន្ធព្វទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង ។

ទក្ខិណស្មឹ ទិសាភាគេ សន្តិ ទេវា មហិទ្ធិកា

ទេវតាទាំងឡាយ មានឫទ្ធច្រើន មានក្នុងទិសាភាគខាងត្បូង ។

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច

ទេវតាទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង ។

បច្ឆិមស្មឹ ទិសាភាគេ សន្តិ នាគា មហិទ្ធិកា

នាគទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងលិច ។

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច

នាគទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង ។

ឧត្តរស្មឹ ទិសាភាគេ សន្តិ យក្ខា មហិទ្ធិកា

យក្ខទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងជើង ។

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច

យក្ខទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង ។

បុរិមទិសំ ធតរដ្ឋោ ស្តេចធតរដ្ឋៈ (នៅរក្សា) ខាងបុរិមទិស ។

ទក្ខិណេន វិរុឡ្ហកោ ស្តេចវិរុឡ្ហកៈ (នៅរក្សា) ខាងទក្ខិណទិស ។

បច្ឆិមេន វិរូបក្ខោ ស្តេចវិរូបក្ខៈ (នៅរក្សា) ខាងបច្ឆិម-ទិស ។

កុវេរោ ឧត្តរំ ទិសំ ស្តេចកុវេរៈ (នៅរក្សា) ខាងឧត្តរ-ទិស ។

ចត្តារោ តេ មហារាជា លោកបាលា យសស្សិនោ

មហារាជទាំងឡាយ៤នោះសុទ្ធតែមានយស ជាអ្នករក្សានូវលោក

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច**

មហារាជទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

ទេវតានិងនាគទាំងឡាយ មានឫទ្ធិច្រើន ដែលឋិតនៅក្នុងអាកាសក្តី ឋិតនៅលើផែនដីក្តី ។

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច**

ទេវតា និងនាគទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង ។

(នត្ថិ មេ សរណំ ... - មានហើយ)

(យំ កិញ្ចិ រតនំ លោកេ ... - មានហើយ)

(សក្កត្វា ពុទ្ធរតនំ ... - មានហើយ)

(សព្វីតិយោ វិវជ្ជន្តុ ... - មានហើយ)

# មង្គលចក្រវាឡ

**សិរិធិតិមតិតេជោជយសិទ្ធិមហិទ្ធិមហាគុណា បរិមិតបុញ្ញាធិការស្ស សព្វន្តរាយនិវារណសមត្ថ-ស្ស ភគវាតោ អរហតោ សម្មាសម្ពុទ្ធស្ស ទ្វត្តឹស-មហាបុរិសលក្ខណានុភាវេន**

ដោយអានុភាពនៃមហាបុរិសលក្ខណៈ ៣២ ប្រការ នៃព្រះដ៏មានព្រះភាគ ជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យ-ធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ទ្រង់មានបុញ្ញាធិការនឹងកំណត់មិនបាន ដោយឫទ្ធិដ៏ធំ និងគុណដ៏ធំ ដ៏សម្រេចដោយសិរី ដោយបញ្ញាជាគ្រឿងតម្កល់មាំ ដោយបញ្ញាជាគ្រឿងដឹងដោយតេជៈ ដោយជ័យជម្នះ ព្រះអង្គអាចក្នុងកិរិយាឃាត់បង់នូវអន្តរាយគ្រប់យ៉ាង ។

**អសីត្យានុព្យញ្ជនានុភាវេន** ដោយអានុភាពនៃអនុ-ព្យញ្ជនៈ ៨០ ។

អដ្ឋុត្តរសតមង្គលានុភាវេន ដោយអានុភាព នៃមង្គល ១០៨ ។

ឆព្វណ្ណរំស្យានុភាវេន ដោយអានុភាព នៃរស្មីមានពណ៌ ៦ ។

កេតុមាលានុភាវេន ដោយអានុភាពនៃព្រះកេតុមាលា

ទសបារមីតានុភាវេន ដោយអានុភាពនៃបារមី ១០

ទសឧបបារមីតានុភាវេន ដោយអានុភាព នៃឧបៈ-បារមី ១០ ។

ទសបរមត្ថបារមីតានុភាវេន ដោយអានុភាពនៃបរៈ-មត្ថបារមី ១០ ។

សីលសមាធិបញ្ញានុភាវេន ដោយអានុភាពនៃសីលសមាធិ បញ្ញានៃព្រះអង្គ ។

ពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធ

ធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌

សង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃ

តេជានុភាវេន ដោយអានុភាពនៃតេជៈ

ឥទ្ធានុភាវេន ដោយអានុភាពនៃឫទ្ធិ

ពលានុភាវេន ដោយអានុភាពនៃកម្លាំង

ញេយ្យធម្មានុភាវេន ដោយអានុភាពនៃញេយ្យធម៌

ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន ដោយអានុ-ភាពនៃព្រះធម្មក្ខន្ធ ៨ ម៉ឺន ៤ ពាន់ ។

នវលោកុត្តរធម្មានុភាវេន ដោយអានុភាពនៃលោ-កុត្តរធម៌ ៩ ។

អដ្ឋង្គិកមគ្គានុភាវេន ដោយអានុភាពនៃព្រះអរិយមគ្គមានអង្គ ៨ ។

អដ្ឋសមាបត្យានុភាវេន ដោយអានុភាពនៃសមាបត្តិ៨

ឆឡភិញ្ញានុភាវេន ដោយអានុភាពនៃអភិញ្ញា ៦

ចតុសច្ចញ្ញាណានុភាវេន ដោយអានុភាពនៃសច្ច-ញ្ញាណ ៤ ។

**ទសពលញ្ញានុភាវេន**ដោយអានុភាពនៃពលញ្ញាណ១០

**សព្វញ្ញុតញ្ញាណានុភាវេន** ដោយអានុភាពនៃសព្វ-ញ្ញុតញ្ញាណ ។

**មេត្តាករុណាមុទិតាឧបេក្ខានុភាវេន** ដោយអានុ-ភាពនៃមេត្តាករុណាមុទិតាឧបេក្ខា ។

**សព្វបរិត្តានុភាវេន** ដោយអានុភាព នៃព្រះបរិយត្ត ទាំងពួង ។

**រតនត្តយសរណានុភាវេន** ដោយអានុភាពនៃកិរិយា រឭកដល់ព្រះរតនត្រ័យ ។

**តុយ្ហំ សព្វរោគសោកុបទ្ទវទុក្ខទោមនស្សុបាយាសា វិនស្សន្តុ** រោគ សោក ឧបទ្រព ទុក្ខ ទោមនស្ស និង ឧបាយាសទាំងពួងរបស់អ្នក ចូរវិនាសបាត់ទៅ ។

**សព្វអន្តរាយាបិ វិនស្សន្តុ** សេចក្តីអន្តរាយទាំងពួង (របស់អ្នក) ចូរវិនាសបាត់ទៅ ។

**សព្វសង្កប្បា តុយ្ហំ សមិជ្ឈន្តុ** សេចក្ដីត្រិះរិះគ្រប់យ៉ាងរបស់អ្នក ចូរសម្រេចដោយល្អ ។

**ទីឃាយុកា តុយ្ហំ ហោតុ** ភាវៈជាអ្នកមានអាយុវែងចូរមានដល់អ្នក ។

**សតវស្សជីវេន សមង្គិកោ ហោតុ សព្វទា** សូមឱ្យអ្នកជាបុគ្គល មានសេចក្ដីសមប្រកបដោយកិរិយារស់នៅ អស់រយៈនៃឆ្នាំសព្វៗ កាល ។

**អាកាសបព្វតវនភូមិគង្គាមហាសមុទ្ទា អារក្ខកា ទេវតា** ទេវតាទាំងឡាយ ជាអ្នករក្សាដោយយកចិត្តទុកដាក់ ដែលស្ថិតនៅក្នុងអកាសបពឹត វនស្ថាន ភូមិស្ថាន និងទន្លេ និងមហាសមុទ្រ ។

**សទា តុម្ហេ អនុរក្ខន្តុ** ចូរបីបាច់រក្សានូវអ្នកទាំងឡាយសព្វៗ កាល ។

**ភវតុ សព្វមង្គលំ** មង្គលទាំងពួងចូរមាន (ដល់អ្នក)។

**រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងអស់ បីបាច់រក្សា (នូវអ្នក)។

**សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ ។

**សទា សោត្ថី ភវន្តុ តេ** សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា ។

**ភវតុ សព្វមង្គលំ** មង្គលទាំងពួងចូរមាន (ដល់អ្នក)។

**រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)។

**សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង

**សទា សោត្ថី ភវន្តុ តេ** សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា។

**ភវតុ សព្វមង្គលំ** មង្គលទាំងពួងចូរមាន (ដល់អ្នក)។

**រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក) ។

**សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំង-ពួង ។

**សទា សោត្ថី ភវន្តុ តេ** សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា ។

**នក្ខត្តយក្ខភូតានំ បាបគ្គហនិវារណា** កិរិយារារាំងនូវបាបគ្រោះទាំងឡាយ (ដែលកើតអំពីសំណាក់) នៃនក្ខត្តឫក្សនិងយក្ស និងភូតបិសាចទាំងឡាយ ។

**បរិត្តស្សានុភាវេន ហន្ត្វា តេសំ ឧបទ្ទវេ** ដោយអានុភាពនៃព្រះបរិត្ត សូមកំចាត់បង់នូវឧបទ្រពទាំងឡាយ(ដែលកើតអំពីសំណាក់) នៃនក្ខត្តឫក្ស និងយក្ស និងភូតបិសាចទាំង-ឡាយនោះ

(សូត្រ ១ ចប់ក៏បាន សូត្រ ៣ ចប់ក៏បាន)

# ជយបរិត្តគាថា

មហាការុណិកោ នាថោ ហិតាយ សព្វបាណិនំ

បូរេត្វា បារមី សព្វា បត្តោ សម្ពោធិមុត្តមំ

ព្រះសម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណា ព្រះអង្គបំពេញនូវបារមីទាំងឡាយទាំងពួង ដើម្បីប្រយោជន៍ដល់សត្វទាំងអស់ ហើយទ្រង់បានដល់នូវសម្ពោធិ-ញ្ញាណដ៏ឧត្តមហើយ ។

ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គល កើតមានដល់អ្នក ។

ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ

ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ

អបរាជិតបល្លង្កេ សីសេ បថវិបោក្ខរេ

អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ញុំាងសេចក្ដីត្រេកអរ នៃសាក្យទាំង-ឡាយឱ្យចម្រើន ព្រះអង្គឈ្នះមារហើយ បានដល់នូវភាពជាបុគ្គលប្រសើរបំផុត ទ្រង់រីករាយ (ចំពោះធម៌ដែលព្រះអង្គត្រាស់ដឹង) លើអបរាជិតបល្ល័ង្ក ជាជយមង្គល ទៀបគល់ពោធិព្រឹក្សត្រង់ផ្ចិត ផែនដីដូចជាស្លឹកឈូក ជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះអង្គ (យ៉ាងណាមិញ) សូមឱ្យអ្នកជាបុគ្គល មានជំនះឈ្នះ (អស់សត្រូវ) យ៉ាងនោះឯង ។

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**

**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ**

(ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ពេលនោះ) ឈ្មោះថាជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ (ទានដែលបុគ្គលបានបូជាហើយ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿងបូជាល្អ ។

**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ**

**បទក្ខិណំ មនោកម្មំ បណិធិ តេ បទក្ខិណា**

(ក្នុងថ្ងៃនោះ) កាយកម្ម ក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន វចីកម្មក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន មនោកម្ម ក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន ។

**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ**

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចំរើន (យ៉ាងនេះ) ហើយ ក៏រមែងបាននូវប្រយោជន៍ ដ៏ចំរើនទាំងឡាយ ។

# អភយបរិត្តគាថា

**យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ ពុទ្ធានុភាវេន វិនាសមេន្តុ** និមិត្តអាក្រក់ឯណាក្តី អព-មង្គលឯណាក្តី សម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្តី ដោយអានុ-

ភាពនៃព្រះពុទ្ធជាម្ចាស់ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅ ។

**យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ ធម្មានុភាវេន វិនាសមេន្តុ** និមិត្តអាក្រក់ឯណាក្ដី អពមង្គលឯណាក្ដី សម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្ដី បាបគ្រោះឯណាក្ដី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្ដី ដោយអានុភាពនៃព្រះធម៌ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅ ។

**យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ សង្ឃានុភាវេន វិនាសមេន្តុ** និមិត្តអាក្រក់ឯណាក្ដី អពមង្គលឯណាក្ដី ម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្ដី បាបគ្រោះឯណាក្ដី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្ដី ដោយអានុភាពនៃព្រះសង្ឃ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ** សត្វទាំងឡាយទាំងពួងដែលដល់ហើយ នូវសេចក្ដីទុក្ខ សូមឱ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយ នូវសេចក្ដីសោក សូមឱ្យជាសត្វបាត់សេចក្ដីសោកទៅ ។

**ឯត្តាវតា ច អម្ហេហិ សម្ភតំ បុញ្ញសម្បទំ សព្វេ ទេវានុមោទន្តុ សព្វសម្បត្តិសិទ្ធិយា** សូមទេវតាទាំង-ឡាយទាំងពួង អនុមោទនានូវសម្បទា គឺបុណ្យដែលយើងទាំងឡាយបានកសាងហើយទាំងប៉ុណ្ណោះ ដើម្បីឱ្យបានសម្រេចនូវសម្បត្តិទាំងពួង ។

**ទានំ ទទន្តុ សទ្ធាយ សីលំ រក្ខន្តុ សព្វទា ភាវនាភិរតា ហោន្តុ គច្ឆន្តុ ទេវតា គតា** មនុស្សទាំងឡាយចូរនាំគ្នាឱ្យទានដោយសទ្ធា ចូរនាំគ្នារក្សាសីល ចូរជា

អ្នកត្រេកអរចំពោះភាវនាសព្វៗកាលទៅ ទេវតាទាំងឡាយដែលមកហើយ សូមអញ្ជើញត្រឡប់ទៅវិញចុះ ។

សព្វេ ពុទ្ធា ពលប្បត្តា បច្ចេកានញ្ច យម្ពលំ អរហន្តានញ្ច តេជេន រក្ខំ ពន្ធាមិ សព្វសោ ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គ សុទ្ធតែទ្រទ្រង់នូវកម្លាំង ទាំងព្រះបច្ចេកពុទ្ធទាំងឡាយក៏មានកម្លាំង ព្រះអរហន្តទាំងឡាយក៏មានកម្លាំង ខ្ញុំសូមចងនូវការរក្សាដោយតេជះ (នៃកម្លាំងទាំង-ឡាយនោះ) ដោយប្រការៈទាំងពួង

# អាដានាដិយបរិត្តគាថា

សក្កត្វា ពុទ្ធរតនំ ឱសថំ ឧត្តមំ វរំ ហិតំ ទេវ-មនុស្សានំ ពុទ្ធតេជេន សោត្ថិនា នស្សន្តុបទ្ទវា សព្វេ ទុក្ខា វូបសមេន្តុ តេ សូមឱ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យសេចក្តីទុក្ខ ទាំងឡាយរបស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាព នៃព្រះពុទ្ធ

ជាម្ចាស់ ព្រោះធ្វើគោរពនូវព្រះពុទ្ធរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ ។

**សក្កត្វា ធម្មរតនំ ឱសថំ ឧត្តមំ វរំ ហិតំ បរិឡាហូបសមនំ ធម្មតេជេន សោត្ថិនា នស្សន្តុបទ្ទវា សព្វេ ភយា វូបសមេន្តុ តេ** សូមឱ្យឧបទ្រពទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យភ័យទាំងឡាយ របស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះធម៌ ព្រោះធ្វើគោរពនូវព្រះធម្មរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាគ្រឿងរម្ងាប់នូវសេចក្តីក្រវល់ក្រវាយ ។

**សក្កត្វា សង្ឃរតនំ ឱសថំ ឧត្តមំ វរំ អាហុនេយ្យំ បាហុនេយ្យំ សង្ឃតេជេន សោត្ថិនា នស្សន្តុបទ្ទវា សព្វេ រោគា វូបសមេន្តុ តេ** សូមឱ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យរោគទាំងឡាយរបស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះសង្ឃ ព្រោះធ្វើគោរពនូវព្រះសង្ឃរតន៍ ដូចជា

ឱសថដ៏ឧត្តមប្រសើរ ជាវត្ថុគួរគេនាំមកបូជា ជាវត្ថុគួរគេទទួលរាក់ទាក់ ។

**ភវតុ សព្វមង្គលំ** មង្គលទាំងពួងចូរមាន (ដល់អ្នក) ។

**រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងអស់ បីបាច់រក្សា (នូវអ្នក) ។

**សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ ។

**សទា សោត្ថី ភវន្តុ តេ** សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា ។

**ភវតុ សព្វមង្គលំ** មង្គលទាំងពួងចូរមាន(ដល់អ្នក) ។

**រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក) ។

**សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង

**សទា សោត្ថី ភវន្តុ តេ** សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា ។

ភវតុ សព្វមង្គលំ មង្គលទាំងពួងចូរមាន (ដល់អ្នក) ។

រក្ខន្តុ សព្វទេវតា សូមទេវតាទាំងអស់ បីបាច់រក្សា (នូវអ្នក) ។

សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំង-ពួង ។

សទា សោត្ថី ភវន្តុ តេ សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា ។

នក្ខត្តយក្ខភូតានំ បាបគ្គហនិវារណា កិរិយារារាំងនូវបាបគ្រោះទាំងឡាយ (ដែលកើតអំពីសំណាក់) នៃនក្ខត្តឫក្សនិងយក្ខ និងភូតបីសាចទាំងឡាយ ។

បរិត្តស្សានុភាវេន ហន្ត្វា តេសំ ឧបទ្ទវេ ដោយអានុភាពនៃព្រះបរិត្ត សូមកម្ចាត់បង់នូវឧបទ្រពទាំងឡាយ (ដែលកើតអំពីសំណាក់) នៃនក្ខត្តឫក្ស និងយក្ខ និងភូតបីសាចទាំង-ឡាយនោះ

អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ ទានវត្ថុ ឥមេ ទស ទានវត្ថុទាំងឡាយ ១០ យ៉ាងនេះ គឺបាយ ទឹក យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសំណាក់អាស្រ័យ គ្រឿងប្រទីប គឺចង្កៀងគោម ។

អន្នទោ ពលទោ ហោតិ អ្នកឱ្យរបស់បរិភោគ ឈ្មោះថា ឱ្យកម្លាំង ។

វត្ថទោ ហោតិ វណ្ណទោ អ្នកឱ្យសំពត់ ឈ្មោះថា ឱ្យពណ៌ ។

យានទោ សុខទោ ហោតិ អ្នកឱ្យយាន ឈ្មោះថា ឱ្យសេចក្ដីសុខ ។

ទីបទោ ហោតិ ចក្ខុទោ អ្នកឱ្យប្រទីប ឈ្មោះថា ឱ្យចក្ខុ គឺភ្នែក ។

មនាបទាយី លភតេ មនាបំ អ្នកឱ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត ។

**អគ្គស្ស ទាតា លភតេ បុនគ្គំ** អ្នកឱ្យវត្ថុដ៏លើស រមែងបាននូវវត្ថុដ៏លើស ។

**វរស្ស ទាតា វរលាភី ច ហោតិ** អ្នកឱ្យរបស់ល្អ រមែងបានរបស់ល្អ ។

**សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ** អ្នកឱ្យទីស្ថានដ៏ប្រសើរ រមែងចូលទៅដល់ទីស្ថានដ៏ប្រសើរ ។

**អគ្គទាយី វរទាយី សេដ្ឋទាយី ច យោ នរោ** នរជនប្រុសស្រីឯណា ឱ្យរបស់ដែលលើស ឱ្យរបស់ដែលល្អ និងទីស្ថានដ៏ប្រសើរ ។

**ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ** នរជនប្រុសស្រីនោះ កើតក្នុងទីណាៗ រមែងជាអ្នកមានអាយុយឺនយូរ មានយសក្នុងទីនោះៗ ។

**ឯតេន សច្ចវជ្ជេន** ដោយភាសិតសច្ចវាចានេះ

**សុវត្ថិ ហោតុ សព្វទា អរោគិយសុខញ្ចេវ កុសលញ្ច អនាមយំ** សូមឱ្យសេចក្តីសួស្តី និងសេចក្តីសុខ

ដែលកើតអំពីសេចក្ដីមិនមានរោគ និងអនាម័យ គឺសេចក្ដីប្រាស ចាកទុក្ខព្យាធិ ស្រួលងាយ ចូរមានដល់អ្នកទាំងឡាយ ឱ្យបាន គ្រប់កាល

# ភត្តានុមោទនាគាថា

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ** ផ្លូវទឹក ទាំងឡាយ មានទន្លេ និងស្ទឹងជាដើមដ៏ពេញ ដែល ញុំាងសាគរ គឺសមុទ្រឱ្យពេញ ប្រៀបដូចម្ដេចមិញ **ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ** ទានដែលទាយកទាយិកា ឧទ្ទិសឱ្យ ហើយអំពីលោកនេះ រមែងសម្រេចផលដល់អ្នកដែលចែកស្ថាន ទៅកាន់បរលោកហើយដូច្នោះឯង **ឥច្ឆិតំ បត្ថិតំ តុម្ហំ ខិប្បមេវ សមិជ្ឈតុ** សូមឥដ្ឋផលគឺផលជាទីគាប់ចិត្ត ដែល អ្នកប្រាថ្នាហើយតាំងចិត្ត ហើយចូរឱ្យសម្រេចដល់អ្នក ឱ្យបាន ឆាប់រួសរាន់ទាន់ចិត្ត ។ **សព្វេ បូរេន្តុ សង្កប្បា** សូមតម្រិះ ត្រូវទាំងពួងចូរពេញ (ដល់អ្នក)។ **ចន្ទោ បណ្ណរសោ យថា**

ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត **មណិជោតិរសោ យថា** (ពុំនោះសោត) ដូចកែវមណី មានរស្មីដ៏រុងរឿង ជាកែវពិសេស អាចញុំាងសេចក្តីប្រាថ្នាទាំងពួងឱ្យសម្រេចបាន

# សិទ្ធិយាចនគាថា

**សិទ្ធមត្ថុ សិទ្ធមត្ថុ សិទ្ធមត្ថុ ឥទំ ផលំ ឯតស្មឹ រតនត្តយស្មឹ សម្បសាទនចេតសោ** សូមផលនៃចិត្ត ដែលជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ ផលនេះ ចូរជាផលសម្រេច ចូរជាផលសម្រេច ចូរជាផលសម្រេច

# អគ្គប្បសាទសុត្តគាថា

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ
អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ

បុណ្យដ៏ប្រសើរ រមែងចំរើន អាយុដ៏ប្រសើរផង សម្បុរៈកាយដ៏ប្រសើរផង យសសក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សេចក្តីសុខដ៏ប្រសើរផង កំលាំងដ៏ប្រសើរផង រមែងចំរើនដល់ជនទាំងឡាយ ដែលដឹងច្បាស់នូវធម៌ដ៏ប្រសើរ ដែលជាអ្នកជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរដោយពិត ដែលជ្រះថ្លាក្នុងព្រះពុទ្ធជាបុគ្គលដ៏ប្រសើរលើសលប់ ជាទក្ខិណេយ្យបុគ្គល រកអ្នកឯណាមួយឱ្យស្មើនឹងព្រះអង្គគ្មាន ដែលជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរជាធម៌រម្ងាប់បង់នូវរាគាទិក្កិលេស ជាធម៌នាំមកនូវសេចក្តីសុខ

(ដល់អ្នកប្រតិបត្តិ) ដែលជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាស្រែបុណ្យ រកស្រែបុណ្យឯទៀត ឱ្យក្រៃលែងជាងគ្មាន ដែលជាអ្នកឱ្យនូវទានដល់បុគ្គលដ៏ប្រសើរ ។

**អគ្គស្ស ទាតា មេធាវី អគ្គធម្មសមាហិតោ**

បុគ្គលមានប្រាជ្ញា ដែលមានចិត្តដំកល់ក្នុងធម៌ដ៏ប្រសើរ ហើយជាអ្នកឱ្យនូវទានដល់បុគ្គលដ៏ប្រសើរ ។

**ទេវភូតោ មនុស្សោ វា អគ្គប្បត្តោ បមោទតិ**

តែងនឹងបានទៅហើយជាទេវតា ឬមនុស្ស ក៏រមែងបានដល់នូវភាវៈជាអ្នកប្រសើរហើយរីករាយសប្បាយ

## ភោជនទានានុមោទនាគាថា

**អាយុទោ ពលទោ ធីរោ វណ្ណទោ បដិភាណ-ទោ** ជនអ្នកមានបញ្ញា ជាអ្នកឱ្យនូវអាយុ ជាអ្នកឱ្យនូវកម្លាំង ជាអ្នកឱ្យនូវសម្បុរកាយ ជាអ្នកឱ្យនូវប្រាជ្ញា ។

**សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ**

អ្នកមានប្រាជ្ញាជាអ្នកឱ្យនូវសេចក្តីសុខ (ដល់អ្នកឯទៀតហើយ) រមែងបាននូវសេចក្តីសុខ (នោះមកខ្លួនវិញ) ។

**អាយុំ ទត្វា ពលំ វណ្ណំ សុខញ្ច បដិភាណទោ**

(បុគ្គលឯណា) បានឱ្យនូវអាយុផង នូវកំលាំងផង នូវសម្បុរកាយផង នូវសេចក្តីសុខផង (ដល់អ្នកឯទៀត) ហើយឈ្មោះថា ឱ្យនូវប្រាជ្ញា ។

**ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ**

បុគ្គលនោះលុះបានកើតក្នុងភពណា១ រមែងមានអាយុវែង មានយសបរិវារក្នុងភពនោះ១

## ជីវភត្តានុមោទនាគាថា

**បណ្ឌុបលាសោវ ទានិសិ** ខ្លួនអ្នកក្នុងកាលឥឡូវនេះជាបុគ្គលប្រៀបដូចស្លឹកឈើទុំ មានពណ៌លឿង ។

**យមបុរិសាបិ ច តេ ឧបដ្ឋិតា** បុរស (ជាបំរើ) នៃយមរាជ គឺមរណៈសោត ក៏ប្រាកដដល់អ្នកហើយ ។

**ឧយ្យោគមុខេ បតិដ្ឋសិ** អ្នកជាបុគ្គលស្ថិតនៅក្នុងប្រធាននៃសេចក្ដីសាបសូន្យ ។

**បាថេយ្យំបិ ច តេ ន វិជ្ជតិ** សៀង គឺកុសលរបស់អ្នកសោត ក៏គ្មាន ។

**សោ ករោហិ ទីបមត្តនោ** ចូរធ្វើនូវទីពឹងនៃខ្លួនចុះ

**ខិប្បំ វាយម បណ្ឌិតោ ភវ** អ្នកចូរតាំងព្យាយាមរួតរះ ចូរជាអ្នកឈ្លាស (កុំជាអ្នកល្ងង់ខ្លៅឡើយ) ។

**និទ្ធន្តមលោ អនង្គណោ ទិព្វំ អរិយភូមិមេហិសិ** អ្នក (កាលធ្វើយ៉ាងនេះ) នឹងជាបុគ្គលមានមន្ទិល (មានរាគៈជាដើម) ខ្ចាត់ចេញមិនមានគ្រឿងពួន គឺកិលេស ហើយនឹងដល់នូវអរិយភូមិដ៏ជាទិព្វ

# សាមញ្ញានុមោទនាគាថា

**សព្វីតិយោ វិវជ្ជន្តុ** សូមឱ្យចង្រៃទាំងពួង ទាំងឡាយប្រាសចេញ គឺថា ចូរឱ្យចៀសវាងចេញឆ្ងាយទៅ **សព្វរោគោ វិនស្សតុ** សូមឱ្យរោគទាំងពួង (របស់អ្នក) ជាសះស្បើយទៅ ។

**មា តេ ភវត្វន្តរាយោ** អន្តរាយកុំបីមានដល់អ្នកឡើយ **សុខី ទីឃាយុកោ ភវ** សូមឱ្យអ្នកជាបុគ្គលមានសេចក្ដីសុខ មានអាយុវែង ។

**អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**
**ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ**

ធម៌គឺពរទាំងឡាយ ៤ ប្រការ គឺអាយុ ១ ពណ៌សម្បុរកាយ១ សេចក្ដីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្ដីឱនកាយថ្វាយបង្គំ ដល់ព្រះរតនត្រ័យជាប្រក្រតី និងអ្នកដែលមានសេចក្ដីគោរពកោតក្រែងដល់បុគ្គល ដែលជាអ្នកមានសេចក្ដីចម្រើនដោយគុណ មានសីលគុណជាដើម ឬដែលចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ

# មង្គលចក្កវាឡ

សព្វពុទ្ធានុភាវេន ដោយអានុភាព នៃព្រះពុទ្ធគ្រប់ព្រះអង្គ ។ សព្វធម្មានុភាវេន ដោយអានុភាពនៃ ព្រះធម៌ទាំង-ពួង ។ សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង ។ ពុទ្ធរតនំ ធម្មរតនំ សង្ឃរតនំ តិណ្ណំ រតនានំ អានុភាវេន ដោយអានុភាពនៃព្រះរតនៈទាំង ៣ គឺ ពុទ្ធរតនៈ១ ធម្មរតនៈ ១ សង្ឃរតនៈ ១ ។

ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន ដោយអានុ-ភាពនៃព្រះធម្មក្ខន្ធ ៨ ម៉ឺន ៤ ពាន់ ។

បិដកត្តយានុភាវេន ដោយអានុភាពនៃព្រះត្រៃបិដក

ជិនសាវកានុភាវេន ដោយអានុភាពនៃសាវ័ក នៃព្រះជិនស្រី ។

សព្វេ តេ រោគា រោគទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ ភយា ភ័យទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ អន្តរាយា អន្តរាយទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ ឧបទ្ទវា ឧបទ្រពទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ ទុន្និមិត្តា និមិត្តអាក្រក់ទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ អវមង្គលា អពមង្គលទាំងឡាយទាំងពួង នៃអ្នក ។ វិនស្សន្តុ សូមឱ្យវិនាសបាត់ទៅ ។

អាយុវឌ្ឍកោ សេចក្តីចម្រើនដោយអាយុ

ធនវឌ្ឍកោ សេចក្តីចម្រើនដោយទ្រព្យ

សិរីវឌ្ឍកោ សេចក្តីចម្រើនដោយសិរីសួស្តី

យសវឌ្ឍកោ សេចក្តីចម្រើនដោយយសបរិវារ

ពលវឌ្ឍកោ សេចក្តីចម្រើនដោយកំលាំង

វណ្ណវឌ្ឍកោ សេចក្តីចម្រើនដោយសម្បុរកាយ

សុខវឌ្ឍកោ សេចក្តីចម្រើនដោយសុខ

ហោតុ សព្វទា សូមឱ្យមានដល់អ្នកឱ្យបានសព្វៗកាល

**ទុក្ខរោគភយា វេរា** សេចក្ដីទុក្ខ និងរោគ និងភ័យ និងពៀរទាំងឡាយក្ដី ។ **សោកា សត្តូបុបទ្ទវា** សេចក្ដីសោកទាំងឡាយក្ដី សត្រូវ និងឧបទ្រពទាំងឡាយក្ដី ។ **អនេកា អន្តរាយាបិ** អន្តរាយទាំងឡាយដ៏ច្រើនក្ដី ។ **វិនស្សន្តុ ច តេជសា** សូមឱ្យវិនាសបាត់ទៅដោយតេជៈ (នៃអានុភាព មានពុទ្ធានុភាពជាដើមនោះ) ។ **ជយសិទ្ធិ ធនំ លាភំ** សេចក្ដីសម្រេចនៃជ័យជំនះក្ដី ទ្រព្យក្ដី លាភក្ដី ។ **សោត្ថិភាគ្យំ សុខំ ពលំ** សួស្ដីក្ដី ជោគជ័យល្អក្ដី សេចក្ដីសុខក្ដី កំលាំងក្ដី ។ **សិរី អាយុ ច វណ្ណោ ច** បុញ្ញសិរីក្ដី អាយុក្ដី ពណ៌សម្បុរកាយក្ដី។ **ភោគំ វុឌ្ឍី ច យសវា** ភោគសម្បទាក្ដី សេចក្ដីចម្រើនក្ដីមានយសក្ដី ។ **សតវស្សា ច អាយុ ច** អាយុប្រមាណ ១ រយឆ្នាំក្ដី ។ **ជីវសិទ្ធី ភវន្តុ តេ** សេចក្ដីសម្រេចនៃកិរិយាចិញ្ចឹមជីវិតជាសុខក្ដី (ទាំងអស់នេះ សូមឱ្យមានដល់អ្នក)

# ពិចារណានូវគ្រឿងឧបភោគ-បរិភោគ ឱ្យឃើញត្រឹមតែធាតុ

## ធាតុប្បច្ចវេក្ខណៈ បាលី-ប្រែ:

ធាតុប្បច្ចវេក្ខណៈនោះ គឺត្រូវពិចារណា ក្នុងពេលដែលទទួលនូវបច្ច័យ ៤ ឱ្យឃើញថា ជាធាតុ ។ កាលដែលទទួលនូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

សំពត់ចីវរឯណានេះ សំពត់ចីវរនេះ គ្រាន់តែជាធាតុពិតប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកប្រើប្រាស់សំពត់ចីវរនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្ត-កោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

ចង្ហាន់បិណ្ឌបាតឯណានេះ ចង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគចង្ហាន់បិណ្ឌបាតនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថាៈ

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

ទីសេនាសនៈឯណានេះ ទីសេនាសនៈនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគប្រើប្រាស់ទីសេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវគិលានប្បច្ច័យ ឱ្យពិចារណា ដូច្នេះថា:

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជ- កោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ

# បដិក្ខលប្បច្ចវេក្ខណៈ

បដិកូលប្បច្ចវេក្ខណៈ គឺត្រូវពិចារណាក្នុងខណៈ ដែលប្រារព្ធនឹងបរិភោគនូវបច្ច័យ ៤ ឱ្យឃើញថាជារបស់បដិកូល គួរខ្ពើមរអើម ។ កាលដែលប្រារព្ធនឹង ប្រើប្រាស់នូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

## សព្វានិ បនិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។

សំពត់ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងបរិភោគ នូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

## សព្វោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

ចង្ហាន់បិណ្ឌបាតទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងប្រើប្រាស់ នូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

**សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។**

ទីសេនាសនៈទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងបរិភោគនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

**សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។**

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក

# តង្ខណិកបច្ចវេក្ខណៈ

តង្ខណិកបច្ចវេក្ខណៈនោះ គឺគប្បីពិចារណាក្នុងខណៈដែលបរិភោគនូវបច្ច័យ ៤ ។

កាលដែលប្រើប្រាស់នូវចីវរបច្ច័យ ឱ្យពិចារណាថា:

**បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។**

(សីលវន្ត = បុរសមានសីលជាធម្មតា, សីលវតី = ស្ត្រីមានសីលជាធម្មតា) គប្បីពិចារណាដោយឧបាយថា :

អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរ កំណត់ទុក ដើម្បីការពារនូវត្រជាក់ ដើម្បីនឹងការពារ នូវសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំងនូវអវៈយវៈដែលធ្វើនូវសេចក្ដីខ្មាសឱ្យកម្រើក។

កាលដែលបរិភោគ នូវបិណ្ឌបាតប្បច្ច័យ គប្បីពិចារណា ដូច្នេះថា :

បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

សីលវន្ត-សីលវតី គប្បីពិចារណាដោយឧបាយថា អញ អាស្រ័យសេព គឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូច

ក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានៈស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែង រាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផ្លូវផង់សម្បុរ ដូចអ្នកលេងរបាំក៏ទេបរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយ ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារី អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង និងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។

កាលដែលបរិភោគប្រើប្រាស់ នូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

## បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិ-ឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ

**បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។**

សីលវន្ត-សីលវតី គប្បីពិចារណាដោយឧបាយថា អញ អាស្រ័យសេព គឺបរិភោគប្រើប្រាស់នូវសេនាសនៈ កំណត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីការពារនូវកំដៅដើម្បីការពារនូវសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹង បន្ទោបង់នូវក្រវល់ក្រវាយដែលកើតឡើងអំពីរដូវហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

កាលដែលបរិភោគនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

**បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជ-បរិក្ខារំ បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យា-ពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈ-បរមតាយាតិ ។**

សីលវន្ត សីលវតី គប្បីពិចារណាដោយឧបាយថា អញ អាស្រ័យសេព គឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ទុកដើម្បីនឹង ការពារនូវវេទនា

ទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា

# អតីតប្បច្ចវេក្ខណៈ

អតីតប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណានូវបច្ច័យ ៤ ក្នុងអតីតកាល គឺកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណាបានក្នុងថ្ងៃនោះ គឺក្នុងវេលាថ្ងៃ ១ យប់ ១ កុំឱ្យអរុណរះឡើងទាន់ ហើយក្នុងបច្ចវេក្ខណៈមួយៗ ពិចារណា ១ ចប់ ឬ ២ ចប់ ៣ ចប់ ឬច្រើនជាងនេះទៅទៀតក៏បាន ។

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិ-ឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។**

សំពត់ចីវរឯណា ដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់កំណត់

ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារ នូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និង ពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំង នូវអវយវៈដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើកបាន ។

អជ្ជ មយា អបច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុ-វិហារោចាតិ ។

ចង្ហាន់បិណ្ឌបាតឯណា ដែលអញមិនបានពិចារណា ហើយបរិភោគហើយក្នុងថ្ងៃនេះ ចង្ហាន់បិណ្ឌបាតនោះ អញបរិភោគ កំណត់ទុក ដើម្បីនឹងលេង ដូចក្មេងអ្នក ស្រុកក៏ទេ ដើម្បីនឹង

ឱ្យកើតបុរិសមានៈស្រវឹង ដូចអ្នក ប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រីយ៍ ឱ្យប្រព្រឹត្តទៅដើម្បីនឹងបំបាត់បង់ នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារី អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តីសេចក្តីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិ-ឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយ វិនោទនំ បដិសល្លានារាមត្ថំ ។**

ទីសេនាសនៈឯណា ដែលអញមិនបានពិចារណា ហើយបរិភោគប្រើប្រាស់ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការ-ពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្ស របោមមូស ខ្យល់កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

**អជ្ជ មយា អបច្ចវេក្ខិត្វា យោ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារោ បរិភុត្តោ សោ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។**

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណា ដែលអញមិនបានពិចារណាហើយបរិភោគ ហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគកំណត់ទុកដើម្បី នឹងការពារនូវវេទនា

ទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

**ចំណាំ :** បើកាលដែលទទួល និងកាលដែលប្រាថ្នា ដើម្បីបរិភោគ និងកាលដែលបរិភោគនោះ បានពិចារណា ដោយធាតុបច្ចវេក្ខណៈ ដោយបដិកូលបច្ចវេក្ខណៈ ដោយតង្ខណិក-បច្ចវេក្ខណៈរួចសព្វគ្រប់ហើយ និងមិនបាច់ពិចារណាក្នុងអតីត-បច្ចវេក្ខណៈទៀត ក៏បានដែរ

# បដិច្ចសមុប្បាទ

អវិជ្ជាបច្ចយា សង្ខារា សង្ខារទាំងឡាយ (កើតមាន) ព្រោះបច្ច័យ គឺអវិជ្ជា ពោលគឺសេចក្ដីល្ងង់ ។

សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណ (កើតមាន) ព្រោះបច្ច័យ គឺសង្ខារ ។

វិញ្ញាណប្បច្ចយា នាមរូបំ នាម និងរូបកើតមាន ព្រោះបច្ច័យ គឺវិញ្ញាណ ។

នាមរូបប្បច្ចយា សឡាយតនំ អាយតនៈ ៦ (កើតមាន) ព្រោះបច្ច័យ គឺនាម និងរូប ។

សឡាយតនប្បច្ចយា ផស្សោ សម្ផស្ស (កើតមាន) ព្រោះបច្ច័យ គឺអាយតនៈ ៦ ។

ផស្សប្បច្ចយា ផស្សោ សម្ផស្ស (កើតមាន) ព្រោះបច្ច័យ គឺអាយតនៈ ៦ ។

ផស្សប្បច្ចយា វេទនា វេទនា (កើតមាន) ព្រោះបច្ច័យ គឺសម្ផស្ស ។

**វេទនាបច្ចយា តណ្ហា** តណ្ហា (កើតមាន) ព្រោះបច្ច័យ គឺវេទនា ។

**តណ្ហាបច្ចយា ឧបាទានំ** ឧបាទាន (កើតមាន) ព្រោះបច្ច័យ គឺតណ្ហា ។

**ឧបាទានប្បច្ចយា ភវោ** ភព (កើតមាន) ព្រោះបច្ច័យ គឺឧបាទាន ។

**ភវប្បច្ចយា ជាតិ** ជាតិ (កើតមាន) ព្រោះបច្ច័យ គឺភព

**ជាតិប្បច្ចយា ជរាមរណំ** ជរា និងមរណៈ (កើតមាន) ព្រោះបច្ច័យ គឺជាតិ ។

**សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងកើតមាន (ព្រោះជាតិជាបច្ច័យដែរ) ។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** កិរិយាកើតមាននៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ ។

**អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារ-និរោធោ** កិរិយារលត់នៃសង្ខារ ព្រោះកិរិយារលត់ ដោយអរិយមគ្គ ឥតមានសេសសល់នៃអវិជ្ជាមែនពិត ។

**សង្ខារនិរោធា វិញ្ញាណនិរោធោ** កិរិយារលត់នៃវិញ្ញាណ ព្រោះរលត់នៃសង្ខារ ។

**វិញ្ញាណនិរោធា នាមរូបនិរោធោ** កិរិយារលត់នៃនាម និងរូប ព្រោះកិរិយារលត់នៃវិញ្ញាណ ។

**នាមរូបនិរោធា សឡាយតននិរោធោ** កិរិយារលត់នៃអាយតនៈ ៦ ព្រោះរលត់នៃនាម និងរូប ។

**សឡាយតននិរោធា ផស្សនិរោធោ** កិរិយារលត់នៃសម្ផស្ស ព្រោះរលត់នៃអាយតនៈ ៦ ។

**ផស្សនិរោធា វេទនានិរោធោ** កិរិយារលត់នៃវេទនា ព្រោះរលត់នៃសម្ផស្ស ។

**វេទនានិរោធា តណ្ហានិរោធោ** កិរិយារលត់នៃតណ្ហា ព្រោះរលត់នៃវេទនា ។

**តណ្ហានិរោធា ឧបាទាននិរោធោ** កិរិយារលត់នៃឧបាទាន ព្រោះរលត់នៃតណ្ហា ។

**ឧបាទាននិរោធា ភវនិរោធោ** កិរិយារលត់នៃភព ព្រោះរលត់នៃឧបាទាន ។

**ភវនិរោធា ជាតិនិរោធោ** កិរិយារលត់នៃជាតិ ព្រោះរលត់នៃភព ។

**ជាតិនិរោធា ជរាមរណំ** ជរា និងមរណៈ (រលត់) ព្រោះកិរិយារលត់នៃជាតិ ។

**សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ**

សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីព្រួយ សេចក្ដីតូចចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងរលត់ទៅ (ព្រោះកិរិយារលត់នៃជាតិដែរ) ។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ** កិរិយារលត់ទៅនៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ ។

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**

**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ**

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត មានកិរិយាកើតឡើងនឹងវិនាសទៅវិញជាធម្មតា រមែងតែកើតឡើងហើយរលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្ដីសុខគ្រប់យ៉ាង ។

**អចិរំ វត យំ កាយោ បឋវឹ អធិសេស្សតិ**

**ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។**

កាយនេះ មិននៅយូរប៉ុន្មានឡើយ តែមានវិញ្ញាណទៅប្រាសហើយ ជាកាយគឺគេបោះបង់ចោល ក៏នឹងដេកសង្កត់នៅលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

**សព្វេ សត្តា មរិស្សន្តិ មរណន្តំ ហិ ជីវិតំ យថាកម្មំ គមិស្សន្តិ បុញ្ញបាបផលូបគា និរយំ បាបកម្មន្តា បុញ្ញកម្មា ច សុគតឹ ។**

សត្វទាំងឡាយទៀងតែនឹងស្លាប់គ្រប់ៗគ្នា ព្រោះថា ជីវិត (របស់សត្វទាំងឡាយ) សុទ្ធតែមានសេចក្តីស្លាប់ នៅខាងចុងបំផុតគ្រប់ៗប្រាណ (ម្យ៉ាងទៀត) សត្វទាំងឡាយ រមែងកាន់យកនូវផលបុណ្យ ផលបាប ហើយនឹងទៅតាមយថាកម្ម គឺទៅតាមគួរដល់អំពើល្អ និងអាក្រក់ដែលខ្លួនបានធ្វើ អ្នកដែលធ្វើបាបតែងធ្លាក់ទៅសោយទុក្ខក្នុងនរក ចំណែកខាងអ្នកធ្វើបុណ្យ តែងឡើងទៅកាន់សុគតិភព ។

**តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ**
**បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ។**

ព្រោះហេតុដូច្នោះហើយ សាធុជនអ្នកមានចំណង់ចង់បាន សេចក្តីសុខដល់ (ខ្លួន) គួរតែប្រញាប់ប្រញាល់ ធ្វើអំពើបុណ្យ ដែលជាគុណ គឺអ្នកប្រាជ្ញតែងរាប់អានឱ្យបានជានិច្ច គឺខ្លួនត្រូវ កសាងសន្សំ (គ្រាន់នឹងបានជាទីពឹង) ទៅក្នុងភពខាងនាយ (ព្រោះថា) បុណ្យទាំងឡាយ តែងជាទីពឹងពុំនាក់របស់សត្វទាំង-ឡាយ ក្នុងបរលោក ។

**អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ**
**អបវិទ្ធោ តទា សេតិ និរត្ថំវ កលិង្គរំ ។**

អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែលះបង់នូវកាយនេះ ទៅ ក្នុងកាលណាហើយ (កាយនេះក៏ដល់នូវសេចក្តីមិនគួរ នឹងទុក ដាក់ឱ្យនៅលើផ្ទះសម្បែងបានឡើយ) គេតែងនាំយកទៅចោល ឱ្យដេកនៅ (លើផែនដី) ក្នុងកាលណោះឯង ដូចជាអង្កត់ឧស រកប្រយោជន៍គ្មានឡើយ ។

**យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ**
**ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ**

គង្វាលគោ គៀងគោទាំងឡាយ ទៅកាន់ទីគោចរ ដោយ អាជ្ញា គឺដំបង ឬរំពាត់ យ៉ាងណាមិញ ជរា គឺសេចក្តីទ្រុតទ្រោមគ្រាំគ្រា និងមច្ចុរាជ គឺសេចក្តីស្លាប់ ក៏គៀងទៅនូវអាយុរបស់សត្វទាំង-ឡាយ យ៉ាងនោះឯង

**ផេណុបិណ្ឌុបមំ រូបំ វេទនា បុព្វុឡុបមា**
**មរីចិកូបមា សញ្ញា សង្ខារា កទលូបមា**
**មាយូបមញ្ចវិញ្ញាណំ ទេសិតា ទិច្ចពន្ធុនា**

រូបមានសេចក្តីប្រៀបផ្ទៀបនឹងដុំនៃពពុះទឹក វេទនាមានសេចក្តីប្រៀបផ្ទៀបនឹងក្រពេញទឹក ដែលប៉ោងឡើងព្រូច១ សញ្ញាមានសេចក្តីប្រៀបផ្ទៀបនឹងថ្ងៃបណ្តើរកូន សង្ខារទាំងឡាយ មានសេចក្តីប្រៀបផ្ទៀបនឹងដើមចេក វិញ្ញាណមានសេចក្តីប្រៀបផ្ទៀបនឹងកលមាយា (សេចក្តីប្រៀបផ្ទៀបនៃខន្ធទាំង ៥ នេះ) គឺព្រះសម្ពុទ្ធមានផៅពង្សដ៏ខ្ពង់ខ្ពស់ ដូចជាព្រះអាទិត្យ ព្រះអង្គទ្រង់សម្តែងហើយ ។

# ទសជាតិ និង បារមី ១០

**១_តេមិយោ, ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មោ** មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា

- នេក្ខម្ម បារមី
- នេក្ខម្ម ឧបបារមី
- នេក្ខម្ម បរមត្ថបារមី សម្បន្នោ សោ ភគវា

២_មហាជនកោ
- វីរិយ បារមី
- វីរិយ ឧបបារមី
- វីរិយ បរមត្ថបារមី សម្បន្នោ សោ ភគវា

៣_សុវណ្ណសាមោ
- មេត្តា បារមី
- មេត្តា ឧបបារមី
- មេត្តា បរមត្ថបារមី សម្បន្នោ សោ ភគវា

- អធិដ្ឋាន បារមី

៤_និម្មរាជា អធិដ្ឋាន ឧបបារមី

អធិដ្ឋាន បរមត្ថបារមី សម្បន្នោ សោ ភគវា

៥_មហោសថោ
- បញ្ញា បារមី
- បញ្ញា ឧបបារមី
- បញ្ញា បរមត្ថបារមី សម្បន្នោ សោ ភគវា

៦_ភូរិទត្តោ
- សីល បារមី
- សីល ឧបបារមី
- សីល បរមត្ថបារមី សម្បន្នោ សោ ភគវា

៧_ចន្ទកុមារោ
- ខន្តិ បារមី
- ខន្តិ ឧបបារមី
- ខន្តិ បរមត្ថបារមី សម្បន្នោ សោ ភគវា

៨_ព្រហ្មនារទោ
- ឧបេក្ខា បារមី
- ឧបេក្ខា ឧបបារមី
- ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោ ភគវា

៩_វិធុរោ
- សច្ច បារមី
- សច្ច ឧបបារមី
- សច្ច បរមត្ថបារមី សម្បន្នោ សោ ភគវា

១០_វេស្សន្តរោ
- ទាន បារមី
- ទាន ឧបបារមី
- ទាន បរមត្ថបារមី សម្បន្នោ សោ ភគវា

សិទ្ធត្ថោ
- ទស បារមី
- ទស ឧបបារមី
- ទស បរមត្ថបារមី សម្បន្នោ សោ ភគវា

សមត្តឹស បរមត្ថបារមី សម្បន្នោ សោ ភគវាតិ

## bcäimBuT§vcn³

យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ ម្នាលអានន្ទ សភាវៈឯណា គឺព្រះធម៌ក្តី

ព្រះវិន័យក្តី ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយ ដល់អ្នកទាំងឡាយ ។

**សោ វោ មមច្ចយេន សត្ថា** សភាវៈ គឺព្រះធម៌ និង ព្រះវិន័យនោះ លុះអំណើះឥតអំពីតថាគតទៅហើយ នឹងបានជាគ្រូប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

**អហំ ឯកកោវ បរិនិព្វាយិស្សាមិ** តថាគតជាព្រះពុទ្ធមួយអង្គឯងពិត នឹងបរិនិព្វានទៅ ។

**អហញ្ច បនិទានិ ឯកកោវ ឱវទាមិ អនុសា-សេមិ** តែថា ឥឡូវនេះ តថាគតជាព្រះពុទ្ធមួយអង្គឯងពិត តែងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

**មយិ បរិនិព្វុតេ** កាលបើតថាគតបរិនិព្វានទៅហើយ ។

**ឥមានិ ចតុរាសីតិសហស្សធម្មក្ខន្ធានិ តុម្ហេ ឱវទិស្សន្តិ អនុសាសិស្សន្តិ** ព្រះធម្មក្ខន្ធ ៨ ហ្មឺន ៤ ពាន់ នេះ នឹងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ជាខាងក្រោយ ។

យោ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិធម៌វិន័យតាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្តីគោរពកោតក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាមធម៌វិន័យជាប្រក្រតី ។

សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ បុគ្គលទាំងអស់នោះ បានឈ្មោះថា ធ្វើសក្ការៈនឹងតថាគត ធ្វើនូវសេចក្តីគោរពរាប់អាន បូជានូវតថាគត ដោយបដិបត្តិបូជា ជាបូជាយ៉ាងក្រៃលែង ។

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ឥទម្បច្ឆិមពុទ្ធវចនំ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគត

នឹងផ្ដាំនូវអ្នកទាំងឡាយ ឱ្យបានដឹងគ្រប់គ្នា នៃភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅ និងសាបសូន្យទៅជាធម្មតា ។ អ្នករាល់គ្នា ចូរញុំាងប្រយោជន៍ ឱ្យដល់ព្រមដោយអប្បមាទៈ គឺការមិនបណ្ដែតបណ្ដោយក្នុងធម៌វិន័យ ពាក្យប្រៀន-ប្រដៅមានប្រមាណប៉ុណ្ណេះជាដើមនេះ ឈ្មោះថា បច្ឆិមពុទ្ធ-វចនៈ ជាពាក្យផ្ដាំពៅបំផុត របស់ព្រះពុទ្ធជាម្ចាស់នៃយើង ។

**ឧភិន្នមន្តរេ យំ វុត្តំ ឯតំ មជ្ឈិមពុទ្ធវចនំ** ពាក្យប្រដៅឯណា ដែលទ្រង់ត្រាស់ពោលជាចន្លោះនៃបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ទាំងពីរនេះ ពាក្យប្រដៅនោះ ឈ្មោះថា មជ្ឈិមពុទ្ធវចនៈ គឺពាក្យប្រដៅ ជាកណ្ដាលរបស់ព្រះពុទ្ធ ជាបរមគ្រូ (នៃយើង)

ចប់បច្ឆិមពុទ្ធវចនៈ

PasietavaTsegçb

**ឧកាស** ខ្ញុំសូមគោរព !

## យោ បន ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិបដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ ។

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ ជាប្រក្រតី អ្នកនោះឈ្មោះថា ធ្វើសក្ការៈ ធ្វើសេចក្ដីគោរព រាប់អាន បូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។

## សព្វបាបស្ស អករណំ កុសលស្សូបសម្បទា សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួន ឱ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

# ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ ។

អំណត់ គឺសេចក្ដីអត់ធន់ ជាតបធម៌ដ៏ឧត្ដម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្ដម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

# អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេក និងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**សីលសមាធិគុណានំ ខន្តិ បធានការណំ**

**សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ ។**

សេចក្តីអត់ធន់ ជាហេតុ ជាទីតាំងនៃគុណ គឺសីល និងសមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចំរើនដោយសេចក្តីអត់ធន់មែនពិត ។

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**

**គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ ។**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថា ជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀល និងការឈ្លោះប្រកែកជាដើម ។

**ខន្តិ ធីរស្ស លង្ការោ ខន្តិ តបោ តបស្សិនោ**

**ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុខាវហា ។**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការ របស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែល មានតបធម៌ សេចក្តីអត់ធន់ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។

ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា
បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ ។

អ្នកអត់ធន់ ជាអ្នកមានមិត្រសំឡាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្ដីសុខជាប្រក្រតី អ្នកអត់ធន់រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃទេវតា និងមនុស្សទាំងឡាយ ។

អត្តនោបិ បរេសញ្ច អត្ថាវហោ វ ខន្តិកោ
សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ ។

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ជាអ្នកឡើងកាន់ផ្លូវជាទីទៅស្ថានសួគ៌ និងព្រះនិព្វាន ។

សត្ថុនោ វចនោវាទំ  ករោតិយេវ ខន្តិកោ
បរមាយ ច បូជាយ  ជិនំ បូជេតិ ខន្តិកោ ។

អ្នកអត់ធន់ ឈ្មោះថា ធ្វើតាមនូវព្រះពុទ្ធដីកា ជាឱវាទនៃព្រះសាស្ដាមែនពិត អ្នកអត់ធន់ ឈ្មោះថា បូជានូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្ដម ។

**ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ ។**

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយ បានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយ បានដោយកម្រ កិរិយាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង ។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្ដីសុខ កិរិយាសំដែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្ដីសុខ សេចក្ដីព្រមព្រៀងគ្នារបស់សង្ឃ ឬពួកក្រុម នាំមកនូវសេចក្ដីសុខ សេចក្ដីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្ដីសុខ ។

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ ។**

សេចក្តីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ (ក្នុងទីស្ងាត់) ជាអ្នកមានធម៌បានស្តាប់ហើយ ពិចារណាឃើញ (នូវធម៌) នាំមកនូវសេចក្តីសុខ កិរិយាបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

**សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ**
**អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ ។**

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាស នូវអស្មិមានៈនេះឯង នាំមកនូវសេចក្តីសុខដ៏ឧត្តម ។

**កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ។**

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក សេចក្តីរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្តាប់នូវព្រះសទ្ធម្មជាការកម្រ កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក ។

សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មី ជិនសាសនេ
កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ ។

បុគ្គលឯណាបានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅ នៃព្រះវិជិតមារទាំងពួង បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ អស់នៃសែនកប្ប ។

បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ
បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ បច្ចូសេវ
គតេ កាលេ ភព្វាភព្វេ វិលោកនំ ឯតេ បញ្ចវិធេ
កិច្ចេ វិសោធេតិ មុនិបុង្គវោតិ ។

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជំរះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹកទ្រង់ស្តេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាចទ្រង់សំដែងធម៌ទេសនា ១ ក្នុងពេលព្រលប់ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអាធ្រាត្រ ទ្រង់

ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ [១] ទ្រង់ប្រមើលមើល នូវសត្វលោក ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១ ។

**កុក្កដេ គព្ភវាសោ ច សោណេ ចុទរនិក្ខមិ ឧសភេ**
**រាជសម្បត្តិ សសេ បព្វជិតោ ជិនោ ។**

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះ គភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតិចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួស ក្នុងឆ្នាំថោះ ។

**កុក្កុដេ សព្វញ្ញុពុទ្ធោ តត្ថ ចក្កំ បវត្តយិ**
**និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ ។**

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ ក្នុងឆ្នាំរកា ទ្រង់សំដែងនូវព្រះធម្មចក្រ ក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វាន ក្នុង

---

[១] -ក្នុងអដ្ឋកថាធម្មបទសំដែងថាព្រះអង្គប្រមើលមើលឧបនិស្ស័យសត្វ ក្នុង ១ ថ្ងៃ ១ យប់ ពីរដង គឺក្នុងពេលជិតភ្លឺម្តង ពេលល្ងាចម្តង ។ ពេលជិតភ្លឺ ទ្រង់ប្រមើលមើលពីកណ្តាប់មាត់ ចក្រវាឡ រហូតដល់មកគន្ធកុដិ ពេលល្ងាច ទ្រង់ប្រមើលមើលពីគន្ធកុដិ រហូតដល់កណ្តាប់មាត់ចក្រវាឡ ។ ប្រមើលមើលនូវសត្វលោកដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១ ។

ឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥.០០០ គត់ ក្នុងឆ្នាំជូត ។

**ឱក្កន្តោ ច គរុវារស្មឹ សុក្រវារេ ច និក្ខមិ**

**សម្ពុទ្ធោ ពុធវារស្មឹ អង្គារេ បរិនិព្វុតោ ។**

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វាន ក្នុងថ្ងៃអង្គារ ។

**អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ**

**វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ ។**

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា)ក្នុងថ្ងៃ ពេញបូណ៌មីខែអាសាធ ប្រសូតិក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ។

**និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ**

**បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ**

**ចតុរាសីតិសហស្ស- ធម្មក្ខន្ធា សុទេសិតា អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ បាណិនំ ។**

កាលព្រះសម្មាសម្ពុទ្ធជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមាផង ព្រះពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ហ្មឺន ៤ ពាន់ ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សំដែងហើយ ដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងស្ថានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។

**ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ ឋបេត្វា សម្មាសម្ពុទ្ធេន វុត្តប្បការេន បដិបត្តិបូជាយ បូជំ ករោន្តេន លោកិយលោកុត្តរសម្បត្តិសិទ្ធំ កាតព្វំ ឱកាស អារាធនំ ករោមិ ។**

បុគ្គលគួរដំកល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង ហើយទុកក្នុងចិត្ត ហើយធ្វើការបូជាដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សំដែងហើយ គួរធ្វើឱ្យ

សម្រេចនូវសម្បត្តិជាលោកិយ និងលោកុត្តរ ខ្ញុំសូមគោរព អារាធនាទុក ដោយប្រការដូច្នេះ ។

ឱកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវប្បច្ចូសសមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហ ឧតុម្ហិ វិសាខមាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយ និព្វានធាតុយា ។

ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងបច្ចូសម័យ ដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្ស ឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើត ខែវិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះហោង

(តពីនេះទៅ ត្រូវបកសករាជប្រាប់ថ្ងៃ ខែ ឆ្នាំ ដែលជាអតីតៈ បច្ចុប្បន្ន និងអនាគត ដរាបដល់ចប់) ។

# ពុទ្ធជយមង្គល

## ១_ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ

## គ្រីមេខលំ ឧទិតឃោរសសេនមារំ

## ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ

## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ

និមិត្តដៃ ១ ពាន់ កាន់សាស្ត្រាវុធនានា ។

ជិះគ្រីមេខលជាតិ កោញូនាទ ខ្ពរពសុធា

ព្រមដោយមារសេនា ពន្លឹកលន់កងស័ព្ទស៊ាន ។

ដោយធម្ម_ ពិធី ទានបារមី ជាប្រធាន

ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។

វីជយមង្គល ចូរមានដល់អ្នករាល់គ្នា

ដោយតេជៈជយា ព្រះឈ្នះមារ គ្រានោះហោង ។

## ២_មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ

## ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ

## ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ

## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិននាយកៈ ផ្ចាញ់អាឡវយក្ខឃោរឃៅ
រឹងរូសមិនតាំងនៅ ក្នុងខន្តី គុណសត្យា ។
រហូតដល់រាត្រី ព្រះជិនស្រីទ្រង់ យុទ្ធនា
ក្រៃលែងក្រុងមារា ក្នុងបឋម សម្ពោធិ ។
ដោយព្រះពិធីញាណ ទ្រង់ទូន្មាន ដោយខន្តី
ញុាំងចិត្ត អសុរី ឱ្យបង់ ព្យសន៍ ចុះវន្ទា
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះអាឡវយក្ខហោង។

## ៣_នាឡាគិរឹ គជវរំ អតិមិត្តភូតំ

## ទាវគ្គិចក្កមសនីវ សុទារុណន្តំ

## មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ

## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គិរី វរៈ គជា ដ៏ហានក្លាចុះព្រេងព្រេច ។

សាហាវឆាវឆេះក្រៃ　　ដូចភ្លើងព្រៃឆេះកំទេច
មុតដូច　ចក្រក្រុតពេជ្រ　　ខ្លាំងដូចកាំ អសនី ។
ដោយព្រះពិធីស្រប់　　ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី　　ញុាំងដរី　ឱ្យជ្រះថ្លា ។
វិជយមង្គល　　ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា　　ព្រះឈ្នះនាឡាគីរី ។

## ៤-ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
## ធាវន្តិ យោជនបថង្គុលិមាលវន្តំ
## ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនលោកត្រៃ　　មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល៍　　មានកម្រង គឺម្រាមដៃ
នៃមនុស្សដែលគាត់កាត់　　មកដោតចាក់ជាមាល័យ
អង់អាចអំណាចក្រៃ　　ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវ　ងារគ្រវី　　ដេញព្រះមុនីសាស្តាចារ្យ
ចម្ងាយផ្លូវកន្តារ　　កណ្តាលព្រៃបីយោជនា

វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្មោះអង្គុលិមាល៍ ។

៥_កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ ចាស់ចើសពោះ ។
យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្មោះកាលនោះ ដោយសមាចារពិធី ។
រម្ងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី
ចិញ្ចា ចាញ់បារមី គឺសច្ចំ ពាក្យសត្យា
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះសាស្តាឈ្មោះចិញ្ចា ។

៦_សច្ចំ វិហាយមតិសច្ចកវាទកេតុំ

វាទាភិរោបិតមនំ អតិអន្ធភូតំ
បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈ ជា និគ្រន្ថ ក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់ ។
បង្កើតមូរ ងងឹត ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីប គឺបញ្ញា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ឈ្នះ សច្ចកៈ និគ្រន្ថ ។

៧_នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច
ឱ្យប្លែងជានាគរាជ ទៅទូន្មាន ព្យសន៍ ភុជង្គ ។
ឈ្មោះ នន្ទោបនន្ទ ចិត្តមោហន្ធ រឿង ឫទ្ធិវង់
ទិដ្ឋិ កាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឱ្យ ឧបទេស ឫទ្ធិវិសេស ដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះភគវាឈ្នះនាគហោង ។

## ៨_ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
## ព្រហ្មំ វិសុទ្ធិ ជុតិមិទ្ធិ ពកាភិធានំ
## ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថាអាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដែកាន់អាសិរ្ពិស គឺចិត្តទ្រឹស្ត ដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ។

ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ឈ្នះព្រហ្មាឥតមានហ្មង ។

## ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា

**យោ វាចនោ ទិនទិនេ សរតេ មតន្ទី**
**ហិត្វានេក វិវិធានិ ចុបទ្ទវានិ**
**មោក្ខំ សុខំ អធិកមេយ្យ នរោ សបញ្ញោ**

**យោ នរោ** ជនឯណា កបបញ្ញាប្រាសក្តិខ្ជិល
ឧស្សាហ៍សាងទានសីល សូត្ររំឭកព្រះធម៌ថ្លៃ ។
គាថាប្រាំបីបទ នេះកំណត់ ឈ្មោះពុទ្ធជ័យ
ខំសូត្រសព្វៗថ្ងៃ កើតមង្គល ជានិរន្តរ៍ ។
**សោ នរោ** វីជននោះ បានរំដោះរោគអាសន្ន
ឧបទ្រព អនេកលន់ មានប្រការផ្សេងៗ ផង ។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វាន សុខកន្លង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជយមង្គលនេះ

# នមស្ការនូវព្រះពុទ្ធបាទ

វន្ទាមិ ពុទ្ធំ វន្ទាមិ ធម្មំ វន្ទាមិ សង្ឃំ មុនិ-
រាជបុត្តំ ។

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

ប្រែថា: ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរ ក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញុំាងជនជាអនន្ត ឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃ-លោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ យំ តត្ថ យោនក-បុរេ មុនិនោ ច បាទំ តំ បាទលញ្ឆនមហំ សិរសា នមាមិ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធ

ទ្រង់ប្រតិស្ឋានទុក) លើផ្ទះរខ្សាច់ទៀបឆ្នេរនៃស្ទឹង ឈ្មោះនម្មទា ស្នាមព្រះព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចព័ន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំងនោះ នៃព្រះសក្យមុនី ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថានដែលមានព្រះបាទ ដ៏ប្រសើរ ៥ កន្លែង គឺស្ថានលើភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណ-បព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា១

# អារាធនាព្រះធម្មកថិក

គ្រានោះសហម្បតី ព្រហ្មជាឥ‗សូវលោកា
ចូលគាល់ ព្រះសាស្តា លើកហត្ថា សិរោរាប ។
ហើយពោល ពាក្យទូលថា សូមករុណា ស្តេចទ្រង់ជ្រាប
ដ្បិតសត្វ អន់ទន់ទាប ទុព្វលភាព ចាប់ក្រៃក្រាស់ ។
ទន្ទឹង ព្រះធម៌ថ្លៃ ជានិស្ស័យ បច្ច័យច្បាស់
ឥឡូវ ទ្រង់បានត្រាស់ ត្រេកអរណាស់ ពុំកន្តើយ ។
សត្វខ្លះ ក្រាស់ដោយកាម មិនយល់តាម ត្រៃលក្ខណ៍ឡើយ
ឥឡូវ យល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ ។
បើបានស្តាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តត្រាស់ទេសនា ។
ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា
ងងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។
ត្រៃលោកគោកត្រៃលក្ខណ៍ សង្សារចក្រវិលមិនដល់
អវិជ្ជា កប្បសគល់ ជាបច្ច័យ នៃសង្ខារ ។
នាំសត្វឱ្យសោកសៅ លិចលង់នៅក្នុងសង្សារ
បញ្ចូមារមោហន្ធការ វិតរុំហុំជុំជាប់នៅ ។

ហេតុនោះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ
ចម្លងសត្វឆ្លោះទៅ កាន់ត្រើយត្រាននិព្វននាយ ។
ដូចកងប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វ ទាំងឡាយ ឱ្យសប្បាយ ក្សាន្តភិរម្យ ។
ព្រះសទ្ធម្ម ជាស្គរជ័យ ព្រះវិន័យ ជារាងធំ
ព្រះសូត្រ ជាខ្សែរុំ ព្រះអភិធម្ម ជាស្បែកដាស់ ។
អរិយសច្ច ជាអណ្តូង សម្រាប់ទូង ឱ្យឮច្បាស់
សត្វលោកងោកងុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។
បរិស័ទ បួនជំពូក ដូចផ្កាឈូក ក្នុងជលដ្ឋាន
ខ្លះដុស ចាំសូរ្យឆាន រះនឹងរីក ដោយរស្មី ។
ព្រះធម៌ ជាសូរ្យសែង រះឡើងចែង ចាំងរស្មី
បំភ្លឺ លោកទាំងបី ឱ្យយល់ផ្លូវ ឋានសុខា ។
សហម្បតិ្ត ព្រហ្ម ឱនបង្គំ អារាធនា
សម្តេច ព្រះភគវា ដោយគាថា យ៉ាងនេះឯង ។
ព្រះពុទ្ធ ទ្រង់អនុកូល ព្រមទទួល នឹងសម្តែង
ដោយតុណ្ហីភាពថ្លែង តាមភាវៈ គុណករុណា ។
ទើបក្រោកចាកទីនោះ ភក្រ្តាឆ្ពោះ ព្រៃមិគទា

យាងចេញ ចរលីលា ពីទីនោះ ដោយព្រះបាទ ។
ញ៉ាំងសត្វ ចូលពុទ្ធចក្រ មានបញ្ចវគ្គីយ៍ ជាអាទិ៍
ឱ្យផឹក អម្រឹតជាតិ រស់និព្វាន តាមធម្មតា ។
ចាប់ដើម ពីនោះឯង ទ្រង់សម្តែង ធម៌ទេសនា
ធ្វើពុទ្ធ ក្រឹត្យា អស់វស្សា សែសិបប្រាំ ។
ពុំថយ ពុំបន្ធូរ ប្រយោជន៍យូរ អង្វែងឆ្នាំ
សម្រេច បុញ្ញកម្ម ដល់សព្វសត្វ ទាំងភពត្រៃ ។
ហេតុនោះ ឥឡូវនេះ យើងខ្ញុំនេះ សាទរក្រៃ
បពិត្រ ព្រះគុណថ្លៃ សូមនិមន្ត ប្រោសទេសនា ។
អនុគ្រោះ ពួកបរិស័ទ ដែលជាប់ខាត់ ដោយមោហា
ឱ្យកើត មានបញ្ញា ប្រាកដនា ទីនេះហោង

ចប់

# គុណនៃឧបាសក ១០ យ៉ាង

ធម៌សម្រាប់ឧបាសក ឧបាសិកាគ្រប់រូប ប្រតិបត្តិដើម្បីនឹងឱ្យកើត ឱ្យចម្រើននូវសម្បត្តិទាំងពួង ឈ្មោះថា "គុណ" ។

គុណនេះ ជារបស់ឧបាសក ឧបាសិកា ហៅថា ឧបាសក-គុណ មាន ១០ យ៉ាង គឺ:

**១.សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ** ឧបាសកអ្នករួមសេចក្តីសុខទុក្ខ មួយអន្លើដោយភិក្ខុសង្ឃ គឺថា បើភិក្ខុសង្ឃមានសេចក្តីសុខក៏ត្រេកអរ បើភិក្ខុសង្ឃ មានសេចក្តីទុក្ខព្រួយ ក៏ព្រួយជាមួយផងដែរ ។

**២.កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ** ឧបាសកមានកាយកម្ម និងវចីកម្ម រក្សាហើយដោយប្រពៃ ។

**៣.ធម្មោ អធិបតេយ្យោ ហោតិ** ឧបាសកមានធម៌ជាអធិបតី គឺថា បើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ជាធំ ជាទីតាំង ជាទីអាងមាំ មិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

**៤.យថា ថាមេន សំវិភាគរតោ វ ហោតិ** ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិច និងច្រើន បើមានតិច ក៏ធ្វើតិច បើមានច្រើន ក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្តានចិត្តឡើយ ។

**៥.ជិនសាសនំ ជានិតុញ្ច វាយមតិ** ឧបាសកឧស្សាហ៍ព្យាយាម ដើម្បីនឹងឱ្យដឹងច្បាស់ នូវសាសនៈគឺពាក្យប្រៀនប្រដៅពាក្យបណ្ដាំនៃព្រះជិនស្រី ។

**៦.សម្មាទិដ្ឋិកោ វ ហោតិ** ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្ដីពិត ។

**៧.អបគតោ កោតុហលមង្គលិកោ វ ហោតិ** ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើម ឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសល និងអកុសលថាឱ្យផល ។

**៨.ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសកបើទុកជាមានហេតុ គួរដល់នូវសេចក្ដីវិនាសជីវិតក្ដី ក៏

មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យ ជាទីពឹងរបស់ខ្លួនថា ប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

**៩.សមគ្គារាមោ វា ហោតិ** ឧបាសកមានសេចក្តីត្រេកអរ ក្នុងសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងគ្នា ។

**១០.សាសនេ ចរតិ** ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធ-សាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា ។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកាគប្បីប្រព្រឹត្តតាមកុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តឧបាសកឧបាសិកា អ្នកប្រតិបត្តិឱ្យសុចរិតផូរផង់ ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង ។

បុៈ ដូចម្តេចហៅថា វិបត្តិរបស់ឧបាសក? វិៈ ធម្មជាតិដែលញ៉ាំងសីល និងអាជីវធម៌ ឱ្យវិនាស ឈ្មោះថា វិបត្តិ ។ បុៈ វិបត្តិនោះ មានប៉ុន្មានយ៉ាងអ្វីខ្លះ ? វិៈ វិបត្តិ មាន ៥ យ៉ាង គឺ :

**១_អស្សទ្ធោ ហោតិ** ឧបាសកមិនជឿគុណព្រះរតនត្រ័យ

**២_ទុស្សីលោ ហោតិ** ឧបាសក ទ្រុស្តសីល

៣_កោតុហលមង្គលិកោ ហោតិ ឧបាសកជឿមង្គលភ្ញាក់ផ្អើល ។

៤_មង្គលំ បច្ចេតិ នោ កម្មំ ឧបាសកជឿមង្គលភ្ញាក់ផ្អើល មិនជឿកម្មផល ។

៥_ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ ឧបាសកស្វែងរកទក្ខិណេយ្យ-បុគ្គលក្រៅពុទ្ធសាសនា ។

បុៈ ចុះអ្វីទៅជាគុណសម្បត្តិរបស់ឧបាសក ? វិៈ ធម្មជាតិដែលញុំាំងសីល និងអាជីវធម៌របស់ឧបាសក ឱ្យល្អបរិសុទ្ធ ផូរ-ផង់ឡើង ហៅថា សម្បត្តិឧបាសក ។ បុៈ ចុះសម្បត្តិនោះ មានប៉ុន្មានយ៉ាងអ្វីខ្លះ ? វិៈ សម្បត្តិនោះ មាន ៥ យ៉ាង គឺៈ

១_សទ្ធោ ហោតិ ឧបាសកមានសទ្ធា ជឿគុណព្រះរតនត្រ័យ ។

២_សីលវា ហោតិ ឧបាសកមានសីល

**៣-ន កោតុហលមង្គលិកោ ហោតិ** ឧបាសកមិនជឿមង្គលភ្ញាក់ផ្អើល ។

**៤-កម្មំ បច្ចេតិ នោ មង្គលំ** ឧបាសកជឿកម្មផល មិនជឿមង្គលភ្ញាក់ផ្អើល ។

**៥-ន ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុញ្ញការំ ករោតិ** ឧបាសកមិនស្វែងរកទក្ខិណេយ្យ-បុគ្គលក្រៅពុទ្ធសាសនា

## អកុសលកម្មបថ ១០ យ៉ាង

គន្លង ឬផ្លូវនៃអំពើជាអកុសល ហៅថា អកុសលកម្មបទ មាន ១០ យ៉ាងគឺ **កាយកម្ម** អំពើដែលសម្រេចដោយ **កាយ** មាន ៣ យ៉ាង, **វចីកម្ម** អំពើដែលសម្រេចដោយ **វាចា** មាន ៤ យ៉ាង, **មនោកម្ម** អំពើដែលសម្រេច ដោយចិត្តមាន ៣ យ៉ាង រួមត្រូវជា ១០ យ៉ាង ។

# កាយកម្ម ៣ យ៉ាង

**១.បាណាតិបាតោ** កិរិយាសម្លាប់សត្វ ដោយកាយរបស់ខ្លួន ឬប្រើគេឱ្យសម្លាប់ដោយវាចា ។

**២.អទិន្នាទានំ** កិរិយាលួចលាក់ឆក់ដណ្តើមទ្រព្យគេដោយកាយរបស់ខ្លួន ឬប្រើគេឱ្យលួចលាក់ឆក់ ដណ្តើមដោយវាចា ។

**៣.កាមេសុ មិច្ឆាចារោ** កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈ នឹងស្ត្រីដែលមានគេហួង-ហែងរក្សា ។

# វចីកម្ម ៤ យ៉ាង

**១.មុសាវាទោ** កិរិយាពោលនូវពាក្យកុហក ។

**២.បិសុណាវាចា** កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ។

**៣.ផរុសវាចា** កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

**៤.សម្ផប្បលាបោ** កិរិយាពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

**១.អភិជ្ឈា** ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានជាទ្រព្យរបស់ខ្លួន ។

**២.ព្យាបាទោ** ចិត្តចងគំនុំគុំគួនគិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្ដីវិនាស ។

**៣.មិច្ឆាទិដ្ឋិ** គំនិតយល់ខុសហើយប្រកាន់ឡើងថាជាត្រូវ។

## កុសលកម្មបថ ១០ យ៉ាង

គន្លង ឬផ្លូវនៃអំពើជាកុសល ហៅថា កុសលកម្មបទ មាន ១០ យ៉ាងគឺ **កាយកម្ម** អំពើដែលសម្រេចដោយ **កាយ** មាន ៣ យ៉ាង, **វចីកម្ម** អំពើដែលសម្រេចដោយ **វាចា** មាន ៤ យ៉ាង, **មនោកម្ម** អំពើដែលសម្រេចដោយចិត្តមាន ៣ យ៉ាង រួមត្រូវជា ១០ យ៉ាង ។

# កាយកម្ម ៣ យ៉ាង

**១.បាណាតិបាតា វេរមណី** កិរិយាវៀរចាកការសម្លាប់សត្វដោយកាយរបស់ខ្លួន ឬប្រើគេឱ្យសម្លាប់ដោយវាចា។

**២.អទិន្នាទានា វេរមណី** កិរិយាវៀរចាកការលួចលាក់ឆក់ដណ្តើមទ្រព្យគេ ដោយកាយរបស់ខ្លួន ឬប្រើគេឱ្យលួចលាក់ឆក់ដណ្តើមដោយវាចា ។

**៣.កាមេសុ មិច្ឆាចារា វេរមណី** កិរិយាវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈ នឹងស្ត្រីដែលមានគេហួងហែងរក្សា ។

# វចីកម្ម ៤ យ៉ាង

**១.មុសាវាទា វេរមណី** កិរិយាវៀរចាកការពោលនូវពាក្យកុហក ។

**២.បិសុណាវាចា វេរមណី** កិរិយាវៀរចាកការពោលនូវពាក្យញុះញង់ បំបែកបំបាក់អ្នកដទៃ ។

**៣.ផរុសវាចា វេរមណី** កិរិយាវៀរចាកការពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

**៤.សម្ផប្បលាបា វេរមណី** កិរិយាវៀរចាកការពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

**១.អនភិជ្ឈា** ចិត្តមិនសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានជាទ្រព្យរបស់ខ្លួន ។

**២.អព្យាបាទោ** ចិត្តមិនចងគំនុំគុំគួនគិតប៉ង នឹងឱ្យអ្នកដទៃដល់នូវសេចក្ដីវិនាស ។

**៣.សម្មាទិដ្ឋិ** គំនិតយល់ឃើញត្រូវ ។

# ពាក្យអារាធនាព្រះភិក្ខុសង្ឃ
# សូមឱ្យចម្រើនព្រះបរិត្ត

## ឧកាស

វិបត្តិប្បដិហាយ សព្វសម្បត្តិសិទ្ធិយា
សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។
វិបត្តិប្បដិហាយ សព្វសម្បត្តិសិទ្ធិយា
សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។
វិបត្តិប្បដិហាយ សព្វសម្បត្តិសិទ្ធិយា
សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។

ប្រែថា សូមព្រះករុណាទាំងឡាយ ចំរើននូវព្រះបរិត្តជាជយ-មង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្ដីអន្តរាយទាំងពួង ដើម្បីនឹងឱ្យបានសម្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញុំាងទុក្ខ ញុំាងភ័យ ញុំាងរោគទាំងអស់ ឱ្យវិនាសបាត់ទៅហោង

# អង្គនៃឧបោសថសីល

## បាណាតិបាតៈ មានអង្គ ៥ គឺ

១.**បាណោ** សត្វមានជីវិត ។

២.**បាណសញ្ញិតា** សេចក្ដីដឹងថាសត្វមានជីវិត ។

៣.**វធកចិត្តំ** គិតនឹងសម្លាប់ ។

៤.**ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ។

៥.**តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

## អទិន្នាទាន មានអង្គ ៥

១.**បរបរិគ្គហិតំ** ទ្រព្យដែលមានម្ចាស់របស់គេ ហួងហែងរក្សា ។

២.**បរបរិគ្គហិតសញ្ញិតា** សេចក្ដីដឹងថា ទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា ។

៣.**ថេយ្យចិត្តំ** គិតនឹងលួច ។

**៤.ឧបក្កមោ** ព្យាយាមនឹងលួច ។

**៥.តេន ហរណំ** លួចបានមកដោយព្យាយាមនោះ ។

## កាមេសុមិច្ឆាចារៈ មានអង្គ ៤

**១.អគមនីយដ្ឋានំ** ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ។

**២.តស្មឹ សេវនចិត្តំ** គិតនឹងសេពនូវមេថុនធម្ម នឹងស្ត្រីនោះ ។

**៣.ឧបក្កមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។

**៤.មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា។

## មុសាវាទ មានអង្គ ៤

**១.អតថំ វត្ថុ** វត្ថុមិនពិត ។

**២.វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស ។

**៣.តជ្ជោ វាយាមោ** ព្យាយាមនឹងពោលឱ្យខុស ។

៤.បរស្ស តទត្ថវិជាននំ ញុំាងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ។

## បិសុណាវាចា មានអង្គ ៤

១.ភិន្ទិតព្វោ បរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក ។

២.ភេទនបុរេក្ខារតោ គិតនឹងញុះញង់បំបែកអ្នកដទៃ

៣.តជ្ជោ វាយាមោ ព្យាយាមនឹងញុះញង់ បំបែកអ្នកដទៃនោះ ។

៤.តស្ស តទត្ថវិជាននំ ញុំាងអ្នកនោះឱ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកនោះ ។

## ផរុសវាចា មានអង្គ ៣

១.អក្កោសិតព្វោ បរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីជេរប្រទេច ។

២.កុប្បិតចិត្តំ ចិត្តខឹងរន្ធត់ ។

៣.អក្កោសនា បានជេរប្រទេចគេ ។

## សម្ផប្បលាបៈ មានអង្គ ២

**១.ភារតយុទ្ធសិតាហរណាទិនិរត្ថកថា** ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃមហាភារតៈ និងរឿងរាពណ៍លួចនាំនាងសេតាយកទៅជាដើម ។

**២.តថារូបីកថាកថនំ** បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នោះ ។

## អភិជ្ឈា មានអង្គ ២

**១.បរភណ្ឌំ** ទ្រព្យជារបស់អ្នកដទៃ ។

**២.អត្តនោ បរិណាមនំ** គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឱ្យបានមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេងៗ ។

## ព្យាបាទ មានអង្គ ២

**១.បរសត្តោ** អ្នកដទៃក្រៅពីខ្លួន ។

**២.តស្ស តំ តំ វិនាសចិន្តា** គិតគុំគួនប្រុងនឹងឱ្យអ្នកនោះដល់នូវសេចក្តីវិនាស ដោយហេតុនោះៗ ។

## មិច្ឆាទិដ្ឋិ មានអង្គ ២

**១.វត្ថុនោ ច គហិតាការវិបរិត្តតា** ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម ។

**២.យថា ច នំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ** គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះថាជាត្រូវវិញ ។

## អព្រហ្មចរិយៈ មានអង្គ ៤

**១.ភេទនវត្ថុ** វត្ថុជាទីទម្លាយនូវសីល គឺទ្វារទាំង ៣០ ចំពោះត្រង់ទ្វារណាមួយ ។

**២.សេវនចិត្តំ** គិតនឹងសេព ។

**៣.តជ្ជោ វាយាមោ** ព្យាយាមនឹងសេពនូវមេថុននោះ

**៤.មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គ និងមគ្គឱ្យដល់គ្នា។

## សុរាមេរយៈ មានអង្គ ៤

**១.មជ្ជនីយវត្ថុ** វត្ថុជាទីតាំង នៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ ។

**២.បាតុកម្យតាចិត្តំ** គិតបំរុងនឹងផឹក ។

**៣.តជ្ជោ វាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

**៤.តស្ស បានំ** បានផឹកនូវទឹកស្រវឹងនោះ ឱ្យកន្លងបំពង់កចូលទៅ ។

## វិកាលភោជន មានអង្គ ៣

**១.វិកាលោ** កាលខុស គឺព្រះអាទិត្យជ្រេទៅហើយ ដរាបទល់នឹងអរុណរះ ។

**២.យាវកាលិកំ** របស់ដែលគួរបរិភោគបាន ក្នុងកាល គឺតាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់ ។

**៣.អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

## នច្ចគីតៈ និងមាលា រួមគ្នាជាសិក្ខាបទ១ មានអង្គ៦ គឺៈ

**១.នច្ចគីតាទិ** ការល្បែងមានរាំនិងច្រៀងជាដើម ។

**២.កត្តុកម្យតាចិត្តំ** គិតបំរុងនឹងធ្វើ ។

**៣.សុតទស្សនត្ថាយ គមនំ** ទៅដើម្បីនឹងស្តាប់ ឬមើល ហើយបានស្តាប់ ឬមើល ។

**៤.មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើម ។

**៥.ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង ។

**៦.តស្ស ធារណំ** បានប្រដាប់តាក់តែង នូវវត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

## ឧច្ចាសយនៈ មានអង្គ ៣

**១.ឧច្ចាសយនមហាសយនំ** ទីដេក ទីអង្គុយ ដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ ។

**២.បរិភោគចិត្តំ** គិតនឹងដេក ឬអង្គុយ ។

**៣.បរិភោគករណំ** បានដេក ឬអង្គុយ

# សំណួរ និង ចម្លើយ

សួរៈ យ៉ាងម៉េចហៅថា វិបត្តិរបស់ឧបាសក ?

ឆ្លើយៈ ធម្មជាតិដែលញ៉ាំងសីល និងអាជីវធម៌ឱ្យវិនាស ឈ្មោះថា វិបត្តិ ។

សួរៈ វិបត្តិនោះ មានប៉ុន្មានយ៉ាងអ្វីខ្លះ?

ឆ្លើយៈ វិបត្តិ មាន ៥ យ៉ាង គឺ :

១_អស្សទ្ធោ ហោតិ មិនជឿគុណព្រះរតនត្រ័យ ។

២_ទុស្សីលោ ហោតិ ជាអ្នកទ្រុស្តសីល

៣_កោតុហលមង្គលិកោ ហោតិ ជាអ្នកជឿមង្គលភ្ញាក់ផ្អើល ។

៤_មង្គលំ បច្ចេតិ នោ កម្មំ ជឿតែមង្គលភ្ញាក់ផ្អើល មិនជឿកម្មផលឡើយ ។

៥_ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ ឧបាសកស្វែងរកទក្ខិណេយ្យបុគ្គលក្រៅពុទ្ធសាសនា ។

សួរ: ចុះអ្វីទៅជាគុណសម្បត្តិរបស់ឧបាសក ?

ឆ្លើយ: ធម្មជាតិដែលញ៉ាំងសីល និងអាជីវធម៌របស់ឧបា-សក ឱ្យល្អបរិសុទ្ធផូរផង់ឡើង ហៅថា សម្បត្តិឧបាសក ។

សួរ: ចុះសម្បត្តិនោះមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ្លើយ: សម្បត្តិនោះ មាន ៥ យ៉ាង គឺ:

**១-សទ្ធោ ហោតិ** ឧបាសកមានសទ្ធា ជឿគុណព្រះរតនត្រ័យ ។

**២-សីលវា ហោតិ** ជាអ្នកមានសីល

**៣-ន កោតុហលមង្គលិកោ ហោតិ** មិនជឿមង្គលភ្ញាក់ផ្អើល ។

**៤-កម្មំ បច្ចេតិ នោ មង្គលំ** ជឿតែកម្មផល មិនជឿមង្គលភ្ញាក់ផ្អើលឡើយ ។

**៥-ន ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ** មិនស្វែងរកទក្ខិណេយ្យបុគ្គលក្រៅពុទ្ធសាសនា

# ព្រះត្រៃសរណគមន៍

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ។

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ។

សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូម ដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូម ដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

# នមស្ការព្រះពុទ្ធច្រើនព្រះអង្គ

សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ បញ្ចសតសហស្សានិ នមាមិ សិរសា អហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំង-ឡាយ ២៨ ព្រះអង្គផង ១ ម៉ឺន ២ ពាន់ព្រះអង្គផង ៥ សែន ព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។

តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះ សង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។

នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ
អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំង-ឡាយជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

**សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិសហស្សកេ**
**ទសសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំង-ឡាយ ៥៥ ព្រះអង្គផង ២ ម៉ឺន ៤ ពាន់ព្រះអង្គផង ១ លានព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ**

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ**
**អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រព្យទាំងឡាយទាំងពួង ទាំងសេចក្តី អន្តរាយទាំងឡាយ ជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ
វីសតិសតសហស្សានិ នមាមិ សិរសា អហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំង-ឡាយ ១០៩ ព្រះអង្គផង ៤ ម៉ឺន ៨ ពាន់ព្រះអង្គផង ២ លាន ព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។

តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះ សង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។

នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ
អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកំចាត់ បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំង-ឡាយ ជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ

# ពាក្យប្រាវព្ធន្ធមង្គលសូត្រ

**យេ សន្តា សន្តចិត្តា តិសរណសរណា ឯត្ថ លោកន្តរេ វា ភុម្មា ភុម្មា ច ទេវា គុណគណគ-ហណព្យាវដា សព្វកាលំ** ទេវតាទាំងឡាយឯណា ជាភុម្ម-ទេវតាក្តី មិនមែនជាភុម្មទេវតាក្តី ជាអ្នកមានចិត្តស្ងប់ មានព្រះរតនត្រ័យជាទីពឹងទីរឭក ដែលមាននៅក្នុងលោកនេះ ឬក្នុងចន្លោះនៃលោក ជាអ្នកខ្វល់ខ្វាយ ក្នុងកិរិយាកាន់យកនូវពពួកនៃគុណសព្វៗ កាល ។

**ឯតេ អាយន្តុ ទេវា វរកនកមយេ មេរុរាជេ វសន្តោ សន្តោ សន្តោ សហេតុំ មុនិវរវចនំ សោតុមគ្គំ សមគ្គំ** សូមទេវតាទាំងឡាយនោះ អញ្ជើញមក ម្យ៉ាងទៀត ទេវតាដែលស្ថិតនៅលើភ្នំមេរុរាជ សុទ្ធសឹងតែមាសដ៏ប្រសើរ សូមអញ្ជើញមកផង សូមទេវតាជាសប្បុរសទាំងឡាយ អញ្ជើញមកកាន់ទីសមាគម ដើម្បីស្តាប់នូវពាក្យនៃព្រះមុនីដ៏បវរ ជាធម៌ដ៏ប្រសើរ លើសជាហេតុនាំឱ្យកើតសេចក្តីត្រេកអរ ។

សព្វេសុ ចក្កវាឡេសុ យក្ខា ទេវា ច ព្រហ្ម-
នោ យំ អម្ហេហិ កតំ បុញ្ញំ សព្វសម្បត្តិ សាធកំ

បុណ្យឯណាដែលយើងបានធ្វើហើយ ជាបុណ្យអាចឱ្យសម្រេច នូវសម្បត្តិទាំងពួង សូមយក្ខទាំងឡាយផង ទេវតាទាំងឡាយផង ព្រហ្មទាំងឡាយផង ក្នុងចក្រវាឡទាំងអស់ (អនុមោទនាត្រេក-អរនឹងបុណ្យនោះ) ។

សព្វេ តំ អនុមោទិត្វា សមគ្គា សាសនេ រតា
បមាទរហិតា ហោន្តុ អារក្ខាសុ វិសេសតោ

យក្ខ និងទេវតា និងព្រហ្មទាំងអស់ កាលបើបានអនុមោទនា នូវបុណ្យនោះហើយ ចូរព្រមព្រៀងគ្នាត្រេកអរ ក្នុងព្រះពុទ្ធ-សាសនា ហើយចូរប្រាសចាកសេចក្តីប្រហែសធ្វេស ក្នុងការរក្សា (នូវព្រះពុទ្ធសាសនា) ដោយឧបាយដ៏វិសេស ។

សាសនស្ស ច លោកស្ស វុឌ្ឍី ភវតុ សព្វទា
សាសនម្បិ ច លោកញ្ច ទេវា រក្ខន្តុ សព្វទា

សូមឱ្យសេចក្តីចម្រើន កើតមានដល់ព្រះពុទ្ធសាសនាផង ដល់សត្វលោកផង ឱ្យបានសព្វៗកាលទៅ សូមទេវតាទាំងឡាយ

អភិបាលរក្សានូវព្រះពុទ្ធសាសនាផង នូវសត្វលោកផង ឱ្យបាន សព្វៗ កាល រៀងទៅ ។

សទ្ធី ហោន្តុ សុខី សព្វេ បរិវារេហិ អត្តនោ អនីឃា សុមនា ហោន្តុ សហ សព្វេហិ ញាតីភិ

សព្វសត្វទាំងអស់ ព្រមទាំងបរិវារទាំងឡាយរបស់ខ្លួន សូមឱ្យ មានសេចក្តីសុខស្រួល សូមឱ្យជាអ្នកឥតមាន សេចក្តីទុក្ខភ័យ ជាអ្នកមានចិត្តល្អ ព្រមទាំងជនជាញាតិសន្តានទាំងអស់គ្នា ។

យញ្ច ទ្វាទស វស្សានិ ចិន្តយឹសុ សទេវកា ចិរស្សំ ចិន្តយន្តាបិ នេវ ជានឹសុ មង្គលំ ចក្កវាឡសហស្សេសុ ទសសុ យេន តត្តកំ កាលំ កោលាហលំ ជាតំ យាវ ព្រហ្មនិវេសនា

មនុស្សព្រមទាំងទេវតាទាំងឡាយ បាននាំគ្នាគិតរក នូវ មង្គលឯណា អស់ ១២ ឆ្នាំ មនុស្ស និងទេវតាទាំងនោះ ក្នុង ១ ម៉ឺនចក្រវាឡ ទោះខំប្រឹងគិតអស់កាលយូរ ម្ល៉ោះក៏នៅតែមិន ដឹងនូវមង្គលនោះត្រឹមណា វីកោលាហលក៏កើត រហូតដល់ភព ជាទីនៅនៃព្រហ្ម អស់កាលត្រឹមណោះឯង ។

**យំ លោកនាថោ ទេសេសិ សព្វបាបវិនាសនំ**

**យំ សុត្វា សព្វទុក្ខេហិ មុញ្ចន្តា សំខិយា នរា**

**ឯវមាទិគុណូបេតំ មង្គលន្តម្ភណាម ហេ**

ព្រះបរមលោកនាថ ទ្រង់ត្រាស់សម្ដែងហើយនូវមង្គលឯណា ដែលជាគ្រឿងញ៉ាំងបាបទាំងពួងឱ្យវិនាស នរជនទាំងឡាយ រាប់ចំនួនមិនបានស្ដាប់នូវមង្គលឯណា ហើយបានរួចចាកទុក្ខទាំង-ពួង ម្នាលទេវតាទាំងឡាយ យើងពោលឥឡូវនេះ នូវមង្គលនោះ ដ៏ប្រកបដោយគុណមានយ៉ាងនេះជាដើម

# មង្គលសូត្រ

**ឯវម្មេ សុតំ** (សូត្រនេះឈ្មោះមង្គលសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្ដាប់មកហើយយ៉ាងនេះថា

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិក-សេដ្ឋីទៀបក្រុងសាវត្ថី ។

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ** លំដាប់នោះឯង ទេវតា អង្គ ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញុំាងវត្តជេតពនជុំវិញទាំងអស់ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះ អង្គព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** កាលទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា(យ៉ាងនេះ)ថា:

**ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ**
**អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។**

ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្តីសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាសម្តែង

ប្រាប់នូវមង្គលដ៏ឧត្តម (ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សម្តែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះ) ថា៖

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។

កិរិយាមិនសេពគប់ នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គល ជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា
អត្តសម្មាបណីធិ ច ឯតម្មង្គលមុត្តមំ

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយ ដោយច្រើន ១

សិល្ប៍សាស្ត្រ គឺសេចក្តីឆ្លៀវឈ្លាសក្នុងហត្ថកម្ម របស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សា ដោយប្រពៃ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

មាតាបិតុឧបដ្ឋានំ   បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា   ឯតម្មង្គលមុត្តមំ

កិរិយាបំរើនូវមាតា ១ កិរិយាបំរើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រ និងភរិយា ១ ការងារទាំងឡាយ ដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ   ឯតម្មង្គលមុត្តមំ ។

កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តិនូវធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយ ដែលមិនមានទោស ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

អារតី វិរតី បាបា   មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១

សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្ដម ។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។

សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្ដីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន១ កិរិយាស្ដាប់នូវធម៌តាមកាល ១ ទាំង ៥ នេះ ជាមង្គលដ៏ឧត្ដម ។

ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។

សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្ដម ។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ
និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។

សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**

**អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ**

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយ ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្ដីសោក ១ មានធូលីគឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា សព្វត្ថ**

**សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។**

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្ដីក្នុងទីទាំងពួង (ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់ នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្សទាំងអម្បាលនោះ ជាមង្គលដ៏ឧត្តម

# ប្រកាសនូវករណីយមេត្តសូត្រ

**យស្សានុភាវតោ យក្ខា នេវ ទស្សេន្តិ ភីសនំ** យក្ខទាំងឡាយ មិនហ៊ានសំដែងនូវអាការៈគួរខ្លាចឡើយ ព្រោះអានុភាពនៃព្រះបរិត្តឯណា ។ **យម្ហិ ចេវានុយុញ្ជន្តោ រត្តិន្ទិវមតន្ទិតោ** ម្យ៉ាងទៀត បុគ្គលមិនខ្ជិលច្រអូសក្នុងយប់និងថ្ងៃ ហើយព្យាយាមរៀនសូត្រ នូវព្រះបរិត្តឯណា ។ **សុខំ សុបតិ សុត្តោ ច បាបំ កិញ្ចិ ន បស្សតិ** កំពុងដេកលក់ ឬលក់រួចហើយ ក៏ជាសុខ រមែងមិនឃើញនូវសុបិន ក៏អាក្រក់តិចតួច ។

**ឯវមាទិគុណូបេតំ បរិត្តន្តម្ភណាម ហេ** យើងទាំងឡាយសូត្រឥឡូវនេះ នូវព្រះបរិត្តនោះ ដែលប្រកបដោយគុណទាំងឡាយ មានយ៉ាងនេះជាដើម

# ករណីយមេត្តសូត្រ

**ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិ-សមេច្ច** កិច្ចឯណា (ដែលព្រះអរិយៈ) បានត្រាស់ដឹង នូវ

កោដ្ឋាសៈនៃធម៌ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន បានធ្វើហើយ កិច្ចនោះ គឺកុលបុត្រ អ្នកឈ្លាសក្នុងប្រយោជន៍ គួរធ្វើ ។ **សក្កោ ឧជូ ច សុហុជូ ច** កុលបុត្រនោះ ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និងវាចាផង ត្រង់ល្អដោយចិត្តផង ។ **សុវចោ ចស្ស មុទុ អនតិមានី** ជាអ្នកប្រដៅងាយផង សុភាពទន់-ភ្លន់ផង មិនមានមានះ ដ៏ក្រៃលែងផង ។ **សន្តុស្សកោ ច សុភរោ ច** ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង ។ **អប្ប-កិច្ចោ ច សល្លហុកវុត្តិ** ជាអ្នកមានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាល (ក្នុងកាយ និងចិត្តផង) ។ **សន្តិន្ទ្រិយោ ច និបកោ ច** ជាអ្នកមានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង ។ **អប្បគព្ភោ កុលេសុ អននុគិទ្ធោ** ជាអ្នកមិនឆ្គងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង ។ **ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ** វិញ្ញូជនទាំងឡាយគួរតិះដៀលនូវជនទាំងឡាយដទៃដោយកម្មឯណា មិនគួរប្រព្រឹត្ត

ធ្វើនូវកម្មនោះ ដែលជាកម្មលាមកសូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្ត ចំពោះពពួកនៃសត្វថា) **សុខិនោ វា ខេមិនោ ហោតុ សព្វេ សត្តា ភវន្តុ សុខិតត្តា** សត្វទាំងឡាយទាំងពួង សូមឱ្យមានសេចក្តីសុខ ឱ្យមានសេចក្តីក្សេម ឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ ។ **យេ កេចិ បាណភូតត្ថិ តសា វា ថាវរា វា អនវសេសា** សត្វមានជីវិតទាំងឡាយឯណា ឥតមានសេសសល់ ទោះសត្វដែលជាអ្នកមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី ជាអ្នកមាំមួន គឺឥតមានតណ្ហាក្តី ។ **ទីឃា វា យេ មហន្តា វា** សត្វទាំងឡាយឯណា មានកាយវែងក្តី ធំក្តី ។ **មជ្ឈិមា រស្សកា អនុកថូលា** មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយដ៏ស្គម ឬធាត់ក្តី ។ **ទិដ្ឋា វា យេ ច អទិដ្ឋា** សត្វទាំងឡាយឯណា ដែលយើងឃើញក្តី មិនឃើញក្តី ។ **យេ ច ទូរេ វសន្តិ អវិទូរេ** សត្វទាំងឡាយឯណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ។ **ភូតា វា សម្ភវេសី វា** ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី ។

**សព្វេ សត្តា ភវន្តុ សុខិតត្តា** សត្វទាំងឡាយទាំងពួង សូមឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ **ន បរោ បរំ និកុព្វេថ** សត្វដទៃមិនគួរកំហែងបៀតបៀន នូវសត្វដទៃឡើយ ។ **នាតិមញ្ញេថ កត្ថចិ នំ កិញ្ចិ** មិនគួរមើលងាយគេតិចតួច ក្នុងទីណាមួយឡើយ ។ **ព្យារោសនា បដិឃសញ្ញា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ** មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានឹងគ្នា ដោយសេចក្តីក្រេវក្រោធ និងដោយបដិឃសញ្ញា គឺសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ ។ **មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ** មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយដោយអាយុ គឺថាសូម្បីជីវិត ក៏ហ៊ានលះបង់ក្នុងការរក្សានូវបុត្របាន យ៉ាងណាមិញ។ **ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ** បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណ ចំពោះទៅរកសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង ។ **មេត្តញ្ច សព្វលោកស្មឹ មាន-**

សម្ភារយេ អបរិមាណំ ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវទៅក្នុងលោកទាំងអស់ គឺក្នុងខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្តាលផង ។

តិដ្ឋញ្ចរំ និសិន្នោ វា សយានោ វា យាវ តស្ស វិគតមិទ្ធោ (បុគ្គលអ្នកចម្រើននូវមេត្តាចិត្តនោះ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាសហើយ គឺថា ជាអ្នកមិនដេកលក់ អស់កាលត្រឹមណា ។ ឯតំ សតឹ អធិដ្ឋេយ្យ គួរដំកល់នូវមេត្តានុស្សតិនុ៎ះ (អស់កាលត្រឹមនោះ)។ ព្រហ្មមេតំ វិហារំ ឥធ មាហុ បណ្ឌិតទាំងឡាយពោលនូវកិរិយានុ៎ះថាជាព្រហ្មវិហារក្នុងសាសនានេះ ។

ទិដ្ឋិញ្ច អនុបគម្ម សីលវា ទស្សនេន សម្បន្នោ កាមេសុ វិនេយ្យ គេធំ នហិជាតុ គព្ភសេយ្យំ បុនរេតីតិ (បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនដល់ស៊ប់នូវ

ទិដ្ឋិ ជាអ្នកមានសីលប្រកបដោយទស្សនសម្ប័ទ គឺសោតាបត្តិ-មគ្គបន្ទោបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់គព្ភសេយ្យាសៈ គឺថា មិនកើតក្នុងគភ៌ទៀតឡើយ

# អាដានាដិយបរិត្ត

(វិបស្សិស្ស នមត្ថុ ។បេ។ មហន្តំ វីតសារទំ មានហើយ)

**នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ (ព្រះសម្ពុទ្ធទាំងនោះ គឺ)

**តណ្ហង្ករោ មហាវីរោ** ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ ។

**មេធង្ករោ មហាយសោ** ព្រះមេធង្ករ ព្រះអង្គមានយសធំ ។

**សរណង្ករោ លោកហិតោ** ព្រះសរណង្ករ ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់សត្វលោក ។

**ទីបង្ករោ ជុតិន្ធរោ** ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង ។

**កោណ្ឌញ្ញោ ជនបាមោក្ខោ** ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន ។

**មង្គលោ បុរិសាសភោ** ព្រះមង្គល ព្រះអង្គជាបុរសដ៏ប្រសើរ ។

**សុមនោ សុមនោ ធីរោ** ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញ មានព្រះហឫទ័យដ៏ល្អ ។

**រេវតោ រតិវឌ្ឍនោ** ព្រះរេវតៈ ព្រះអង្គញ៉ាំងសេចក្ដីត្រេកអរឱ្យចម្រើន ។

**សោភិតោ គុណសម្បន្នោ** ព្រះសោភិតៈ ព្រះអង្គបរិបូណ៌ ដោយព្រះគុណ ។

**អនោមទស្សី ជនុត្តមោ** ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន ។

**បទុមោ លោកបជ្ជោតោ** ព្រះបទុមៈ ព្រះអង្គញ៉ាំងលោកឱ្យភ្លឺស្វាង ។

នារទោ វរសារថី ព្រះនារទៈ ព្រះអង្គដូចជាសារថីដ៏ប្រសើរ ។

បទុមុត្តរោ សត្តសារោ ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពពួកសត្វ ។

សុមេធោ អប្បដិបុគ្គលោ ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន ។

សុជាតោ សព្វលោកគ្គោ ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង ។

បិយទស្សី នរាសភោ ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន ។

អត្ថទស្សី ការុណិកោ ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត ។

សិទ្ធត្ថោ អសមោ លោកេ ព្រះសិទ្ធត្ថៈ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក ។

តិស្សោ ច វទតំ វរោ ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសំដីទាំងឡាយ ។

**ផុស្សោ ច វរទោ ពុទ្ធោ** ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ ។

**វិបស្សី ច អនូបមោ** ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណា ប្រៀបផ្ទឹមបានឡើយ ។

**សិខី សព្វហិតោ សត្ថា** ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឱ្យជាប្រយោជន៍ដល់សត្វទាំងពួង ។

**វេស្សភូ សុខទាយកោ** ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្ដីសុខ ។

**កកុសន្ធោ សត្ថវាហោ** ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស ។

**កោនាគមនោ រណញ្ជហោ** ព្រះកោនាគមនៈ ព្រះអង្គបំបាក់នូវសត្រូវ គឺកិលេស ។

**កស្សបោ សិរិសម្បន្នោ** ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី ។

**គោតមោ សក្យបុង្គវោ** ព្រះគោតមៈ ព្រះអង្គប្រសើរ

ចម្បងជាងពួកសក្យរាជ ។

(ឯតេ ចញ្ញេ ច សម្ពុទ្ធា ។បេ។ និព្វុតោ ចតុរំ ភវំ មានហើយ)។

**តេសំ សច្ចេន សីលេន ខន្តិមេត្តាពលេន ច** ដោយសច្ចៈផង ដោយសីលផង ដោយកម្លាំងនៃខន្តី និងមេត្តាផង នៃព្រះសម្ពុទ្ធទាំងឡាយនោះ ។

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច** ព្រះសម្ពុទ្ធទាំងឡាយនោះ សូមបីបាច់រក្សា នូវអ្នកទាំងឡាយ ដោយមិនមានរោគផង ឱ្យមានសេចក្តីសុខផង ។

**បុរត្ថិមស្មឹ ទិសាភាគេ សន្តិ ភូតា មហិទ្ធិកា** ភូត គឺគន្ធព្វទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងកើត ។

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច** គន្ធព្វទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង ។

**ទក្ខិណស្មឹ ទិសាភាគេ សន្តិ ទេវា មហិទ្ធិកា** ទេវតាទាំងឡាយ មានឫទ្ធច្រើន មានក្នុងទិសាភាគខាងត្បូង ។

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច**

ទេវតាទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង ។

**បច្ឆិមស្មឹ ទិសាភាគេ សន្តិ នាគា មហិទ្ធិកា**

នាគទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងលិច ។

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច**

នាគទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង ។

**ឧត្តរស្មឹ ទិសាភាគេ សន្តិ យក្ខា មហិទ្ធិកា**

យក្ខទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងជើង ។

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច**

យក្ខទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង ។

**បុរិមទិសំ ធតរដ្ឋោ** ស្ដេចធតរដ្ឋៈ (នៅរក្សា) ខាងបុរិមទិស ។

**ទក្ខិណេន វិរុឡ្ហកោ** ស្តេចវិរុឡ្ហកៈ (នៅរក្សា) ខាងទក្ខិណទិស ។

**បច្ឆិមេន វិរូបក្ខោ** ស្តេចវិរូបក្ខៈ (នៅរក្សា) ខាងបច្ឆិម-ទិស ។

**កុវេរោ ឧត្តរំ ទិសំ** ស្តេចកុវេរៈ (នៅរក្សា) ខាងឧត្តរ-ទិស ។

**ចត្តារោ តេ មហារាជា លោកបាលា យសស្សិនោ**
មហារាជទាំងឡាយ៤នោះសុទ្ធតែមានយស ជាអ្នករក្សានូវលោក

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច**
មហារាជទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
ទេវតានិងនាគទាំងឡាយ មានឫទ្ធិច្រើន ដែលឋិតនៅក្នុងអាកាសក្តី ឋិតនៅលើផែនដីក្តី ។

**តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច**

ទេវតា និងនាគទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង ។

(នត្ថិ មេ សរណំ ... - មានហើយ)

(យំ កិញ្ចិ រតនំ លោកេ ... - មានហើយ)

(សក្កត្វា ពុទ្ធរតនំ ... - មានហើយ)

(សព្វីតិយោ វិវជ្ជន្តុ ... - មានហើយ)

# មង្គលចក្រវាឡ

សិរីធិតិមតិតេជោជយសិទ្ធិមហិទ្ធិមហាគុណា បរិមិតបុញ្ញាធិការស្ស សព្វន្តរាយនិវារណសមត្ថ-ស្ស ភគវាតោ អរហតោ សម្មាសម្ពុទ្ធស្ស ទ្វត្តឹស-មហាបុរិសលក្ខណានុភាវេន

ដោយអានុភាពនៃមហាបុរិសលក្ខណៈ ៣២ ប្រការ នៃព្រះ

ដ៏មានព្រះភាគ ជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យ-ធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ទ្រង់មានបុញ្ញាធិការនឹងកំណត់មិនបាន ដោយឫទ្ធិដ៏ធំ និងគុណដ៏ធំ ដ៏សម្រេចដោយសិរី ដោយបញ្ញាជាគ្រឿងតម្កល់មាំ ដោយបញ្ញាជាគ្រឿងដឹង ដោយតេជៈ ដោយជ័យជម្នះ ព្រះអង្គអាចក្នុងកិរិយាឃាត់បង់នូវអន្តរាយគ្រប់យ៉ាង ។

**អសីត្យានុព្យញ្ជនានុភាវេន** ដោយអានុភាពនៃអនុ-ព្យញ្ជនៈ ៨០ ។

**អដ្ឋុត្តរសតមង្គលានុភាវេន** ដោយអានុភាព នៃមង្គល ១០៨ ។

**ឆព្វណ្ណរំស្យានុភាវេន** ដោយអានុភាព នៃរស្មីមានពណ៌ ៦ ។

**កេតុមាលានុភាវេន** ដោយអានុភាពនៃព្រះកេតុមាលា

**ទសបារមីតានុភាវេន** ដោយអានុភាពនៃបារមី ១០

**ទសឧបបារមីតានុភាវេន** ដោយអានុភាព នៃឧប-បារមី ១០ ។

ទសបរមត្ថបារមីតានុភាវេន ដោយអានុភាពនៃបរ-មត្ថបារមី ១០ ។

សីលសមាធិបញ្ញានុភាវេន ដោយអានុភាពនៃសីល សមាធិ បញ្ញានៃព្រះអង្គ ។

ពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធ

ធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌

សង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃ

តេជានុភាវេន ដោយអានុភាពនៃតេជៈ

ឥទ្ធានុភាវេន ដោយអានុភាពនៃឫទ្ធិ

ពលានុភាវេន ដោយអានុភាពនៃកម្លាំង

ញេយ្យធម្មានុភាវេន ដោយអានុភាពនៃញេយ្យធម៌

ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន ដោយអានុ-ភាពនៃព្រះធម្មក្ខន្ធ ៨ ម៉ឺន ៤ ពាន់ ។

នវលោកុត្តរធម្មានុភាវេន ដោយអានុភាពនៃលោ-កុត្តរធម៌ ៩ ។

អដ្ឋង្គិកមគ្គានុភាវេន ដោយអានុភាពនៃព្រះអរិយមគ្គមានអង្គ ៨ ។

អដ្ឋសមាបត្យានុភាវេន ដោយអានុភាពនៃសមាបត្តិ៨

ឆឡភិញ្ញានុភាវេន ដោយអានុភាពនៃអភិញ្ញា ៦

ចតុសច្ចញ្ញាណានុភាវេន ដោយអានុភាពនៃសច្ចញ្ញាណ ៤ ។

ទសពលញ្ញានុភាវេនដោយអានុភាពនៃពលញ្ញាណ១០

សព្វញ្ញុតញ្ញាណានុភាវេន ដោយអានុភាពនៃសព្វញ្ញុតញ្ញាណ ។

មេត្តាករុណាមុទិតាឧបេក្ខានុភាវេន ដោយអានុភាពនៃមេត្តាករុណាមុទិតាឧបេក្ខា ។

សព្វបរិត្តានុភាវេន ដោយអានុភាពនៃព្រះបរិត្តទាំងពួង

រតនត្តយសរណានុភាវេន ដោយអានុភាពនៃកិរិយារឭកដល់ព្រះរតនត្រ័យ ។

តុយ្ហំ សព្វរោគសោកុបទ្ទវទុក្ខទោមនស្សុបាយា

**សា វិនស្សន្តុ** រោគ សោក ឧបទ្រព ទុក្ខ ទោមនស្ស និង ឧបាយាសទាំងពួងរបស់អ្នក ចូរវិនាសបាត់ទៅ ។

**សព្វអន្តរាយាបិ វិនស្សន្តុ** សេចក្តីអន្តរាយទាំងពួង (របស់អ្នក) ចូរវិនាសបាត់ទៅ ។

**សព្វសង្កប្បា តុយ្ហំ សមិជ្ឈន្តុ** សេចក្តីត្រិះរិះគ្រប់យ៉ាងរបស់អ្នក ចូរសម្រេចដោយល្អ ។

**ទីឃាយុកា តុយ្ហំ ហោតុ** ភាវៈជាអ្នកមានអាយុវែង ចូរមានដល់អ្នក ។

**សតវស្សជីវេន សមង្គិកោ ហោតុ សព្វទា** សូមឱ្យអ្នកជាបុគ្គល មានសេចក្តីសមប្រកបដោយកិរិយារស់នៅ អស់រយៈនៃឆ្នាំសព្វៗ កាល ។

**អាកាសបព្វតវនភូមិគង្គាមហាសមុទ្ទា អារក្ខកា ទេវតា** ទេវតាទាំងឡាយ ជាអ្នករក្សាដោយយកចិត្តទុកដាក់ ដែលស្ថិតនៅក្នុងអកាសបពឹត វនស្ថាន ភូមិស្ថាន និងទន្លេ និង មហាសមុទ្រ ។

សទា តុម្ហេ អនុរក្ខន្តុ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ សព្វៗ កាល ។

ភវតុ សព្វមង្គលំ មង្គលទាំងពួងចូរមាន (ដល់អ្នក)

រក្ខន្តុ សព្វទេវតា សូមទេវតាទាំងអស់ បីបាច់រក្សា (នូវអ្នក) ។

សព្វពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ ។

សទា សោត្ថី ភវន្តុ តេ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា ។

ភវតុ សព្វមង្គលំ មង្គលទាំងពួងចូរមាន (ដល់អ្នក)

រក្ខន្តុ សព្វទេវតា សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក) ។

សព្វធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌ទាំងពួង

សទា សោត្ថី ភវន្តុ តេ សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា។

ភវតុ សព្វមង្គលំ មង្គលទាំងពួងចូរមាន (ដល់អ្នក)

រក្ខន្តុ សព្វទេវតា សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក) ។

សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំង-ពួង ។

សទា សោត្ថី ភវន្តុ តេ សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា ។

នក្ខត្តយក្ខភូតានំ បាបគ្គហនិវារណា កិរិយារារាំងនូវបាបគ្រោះទាំងឡាយ (ដែលកើតអំពីសំណាក់) នៃនក្ខត្តឫក្សនិងយក្ស និងភូតបិសាចទាំងឡាយ ។

បរិត្តស្សានុភាវេន ហន្ត្វា តេសំ ឧបទ្ទវេ ដោយអានុភាពនៃព្រះបរិត្ត សូមកំចាត់បង់នូវឧបទ្រពទាំងឡាយ(ដែលកើតអំពីសំណាក់) នៃនក្ខត្តឫក្ស និងយក្ស និងភូតបិសាចទាំង-ឡាយនោះ

(សូត្រ ១ ចប់ក៏បាន សូត្រ ៣ ចប់ក៏បាន)

# ជយបរិត្តគាថា

មហាការុណិកោ នាថោ ហិតាយ សព្វបាណិនំ
បូរេត្វា បារមី សព្វា បត្តោ សម្ពោធិមុត្តមំ

ព្រះសម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណា ព្រះអង្គបំពេញនូវបារមីទាំងឡាយទាំងពួង ដើម្បីប្រយោជន៍ដល់សត្វទាំងអស់ ហើយទ្រង់បានដល់នូវសម្ពោធិ-ញ្ញាណដ៏ឧត្តមហើយ ។

ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គល កើតមានដល់អ្នក ។

ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ
ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ
អបរាជិតបល្លង្កេ សីសេ បថវិបោក្ខរេ
អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ញ៉ាំងសេចក្តីត្រេកអរ នៃសាក្យទាំង-ឡាយឱ្យចម្រើន ព្រះអង្គទ្រង់ឈ្នះមារហើយ បានដល់នូវភាពជា

បុគ្គលប្រសើរបំផុត ទ្រង់រីករាយ (ចំពោះធម៌ដែលព្រះអង្គត្រាស់ដឹង) លើអបរាជិតបល្ល័ង្ក ជាជយមង្គល ទៀបគល់ពោធិព្រឹក្សត្រង់ផ្ចិតផែនដី ដូចជាស្លឹកឈូក ជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះអង្គ (យ៉ាងណាមិញ) សូមឱ្យអ្នកជាបុគ្គល មានជំនះឈ្នះ (អស់សត្រូវ) យ៉ាងនោះឯង ។

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**

**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ**

(ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ពេលនោះ) ឈ្មោះថាជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ (ទានដែលបុគ្គលបានបូជាហើយ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿងបូជាល្អ ។

**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ**

**បទក្ខិណំ មនោកម្មំ បណិធិ តេ បទក្ខិណា**

(ក្នុងថ្ងៃនោះ) កាយកម្ម ក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើនវចីកម្មក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន មនោកម្ម ក៏ឈ្មោះថា

នាំឱ្យមានសេចក្តីចំរើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន ។

**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ**

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចំរើន (យ៉ាងនេះ) ហើយ ក៏រមែងបាននូវប្រយោជន៍ ដ៏ចំរើនទាំងឡាយ ។

## អភយបរិត្តគាថា

**យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ ពុទ្ធានុភាវេន វិនាសមេន្តុ** និមិត្តអាក្រក់ឯណាក្តី អព-មង្គលឯណាក្តី សម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្តី ដោយអានុ-ភាពនៃព្រះពុទ្ធជាម្ចាស់ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

**យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ**

**ធម្មានុភាវេន វិនាសមេន្តុ** និមិត្តអាក្រក់ឯណាក្តី អព-មង្គលឯណាក្តី សម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្តី ដោយអានុ-ភាពនៃព្រះធម៌ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

**យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ សង្ឃានុភាវេន វិនាសមេន្តុ** និមិត្តអាក្រក់ឯណាក្តី អព-មង្គលឯណាក្តី សម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្តី ដោយអានុ-ភាពនៃព្រះសង្ឃ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ** សត្វទាំងឡាយទាំងពួងដែលដល់ហើយ នូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ

សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយ នូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ ។

**ឯត្តាវតា ច អម្ហេហិ សម្ភតំ បុញ្ញសម្បទំ សព្វេ ទេវានុមោទន្តុ សព្វសម្បត្តិសិទ្ធិយា** សូមទេវតាទាំង-ឡាយទាំងពួង អនុមោទនានូវសម្បទា គឺបុណ្យដែលយើងទាំងឡាយបានកសាងហើយទាំងប៉ុណ្ណេះ ដើម្បីឱ្យបានសម្រេចនូវសម្បត្តិទាំងពួង ។

**ទានំ ទទន្តុ សទ្ធាយ សីលំ រក្ខន្តុ សព្វទា ភាវនាភិរតា ហោន្តុ គច្ឆន្តុ ទេវតា គតា** មនុស្សទាំងឡាយចូរនាំគ្នាឱ្យទានដោយសទ្ធា ចូរនាំគ្នារក្សាសីល ចូរជាអ្នកត្រេកអរចំពោះភាវនាសព្វៗកាលទៅ ទេវតាទាំងឡាយដែលមកហើយ សូមអញ្ជើញត្រឡប់ទៅវិញចុះ ។

**សព្វេ ពុទ្ធា ពលប្បត្តា បច្ចេកានញ្ច យម្ពលំ អរហន្តានញ្ច តេជេន រក្ខំ ពន្ធាមិ សព្វសោ** ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គ សុទ្ធតែទ្រទ្រង់នូវកម្លាំង ទាំងព្រះបច្ចេកពុទ្ធទាំងឡាយក៏មានកម្លាំង ព្រះអរហន្តទាំងឡាយ

ក៏មានកម្លាំង ខ្ញុំសូមចងនូវការរក្សាដោយតេជៈ (នៃកម្លាំងទាំង-ឡាយនោះ) ដោយប្រការៈទាំងពួង

# អាដានាដិយបរិត្តគាថា

សក្កត្វា ពុទ្ធរតនំ ឱសថំ ឧត្តមំ វរំ ហិតំ ទេវ-មនុស្សានំ ពុទ្ធតេជេន សោត្ថិនា នស្សន្តុបទ្ទវា សព្វេ ទុក្ខា វូបសមេន្តុ តេ សូមឱ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យសេចក្តីទុក្ខ ទាំងឡាយរបស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាព នៃព្រះពុទ្ធជាម្ចាស់ ព្រោះធ្វើគោរពនូវព្រះពុទ្ធរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ ។

សក្កត្វា ធម្មរតនំ ឱសថំ ឧត្តមំ វរំ ហិតំ បរិ-ឡាហូបសមនំ ធម្មតេជេន សោត្ថិនា នស្សន្តុបទ្ទវា សព្វេ ភយា វូបសមេន្តុ តេ សូមឱ្យឧបទ្រពទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យភ័យទាំងឡាយ របស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះធម៌ ព្រោះ

ធ្វើគោរពនូវព្រះធម្មរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាគ្រឿងរម្ងាប់នូវសេចក្តីក្រវល់ក្រវាយ ។

**សក្កត្វា សង្ឃរតនំ ឱសថំ ឧត្តមំ វរំ អាហុនេយ្យំ បាហុនេយ្យំ សង្ឃតេជេន សោត្ថិនា នស្សន្តុបទ្ទវា សព្វេ រោគា វូបសមេន្តុ តេ** សូមឱ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យរោគទាំងឡាយរបស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះសង្ឃ ព្រោះធ្វើគោរពនូវព្រះសង្ឃរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាវត្ថុគួរគេនាំមកបូជា ជាវត្ថុគួរគេទទួលរាក់ទាក់ ។

## យានទានានុមោទនាគាថា

**អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ ទានវត្ថុ ឥមេ ទស** ទានវត្ថុទាំងឡាយ ១០ យ៉ាងនេះ គឺបាយ ទឹក យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសំណាក់អាស្រ័យ គ្រឿងប្រទីប គឺចង្កៀងគោម ។

**អន្នទោ ពលទោ ហោតិ** អ្នកឱ្យរបស់បរិភោគ ឈ្មោះថា ឱ្យកម្លាំង ។

**វត្ថទោ ហោតិ វណ្ណទោ** អ្នកឱ្យសំពត់ ឈ្មោះថា ឱ្យពណ៌ ។

**យានទោ សុខទោ ហោតិ** អ្នកឱ្យយាន ឈ្មោះថា ឱ្យសេចក្ដីសុខ ។

**ទីបទោ ហោតិ ចក្ខុទោ** អ្នកឱ្យប្រទីប ឈ្មោះថា ឱ្យចក្ខុ គឺភ្នែក ។

**មនាបទាយី លភតេ មនាបំ** អ្នកឱ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត ។

**អគ្គស្ស ទាតា លភតេ បុនគ្គំ** អ្នកឱ្យវត្ថុដ៏លើស រមែងបាននូវវត្ថុដ៏លើស ។

**វរស្ស ទាតា វរលាភី ច ហោតិ** អ្នកឱ្យរបស់ល្អ រមែងបានរបស់ល្អ ។

**សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ** អ្នកឱ្យទីស្ថានដ៏ប្រសើរ រមែងចូលទៅដល់ទីស្ថានដ៏ប្រសើរ ។

**អគ្គទាយី វរទាយី សេដ្ឋទាយី ច យោ នរោ** នរជនប្រុសស្រីឯណា ឱ្យរបស់ដែលលើស ឱ្យរបស់ដែលល្អ និងទីស្ថានដ៏ប្រសើរ ។

**ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ** នរជនប្រុសស្រីនោះ កើតក្នុងទីណា។ រមែងជាអ្នកមានអាយុយឺនយូរ មានយសក្នុងទីនោះ។ ។

**ឯតេន សច្ចវជ្ជេន** ដោយភាសិតសច្ចវាចានេះ

**សុវត្ថិ ហោតុ សព្វទា អរោគិយសុខញ្ចេវ កុសលញ្ច អនាមយំ** សូមឱ្យសេចក្តីសួស្តី និងសេចក្តីសុខ ដែលកើតអំពីសេចក្តីមិនមានរោគ និងអនាម័យ គឺសេចក្តីប្រាសចាកទុក្ខព្យាធិ ស្រួលងាយ ចូរមានដល់អ្នកទាងឡាយ ឱ្យបានគ្រប់កាល

# ភគ្គានុមោទនាវម្គគាថា

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ** ផ្លូវទឹកទាំងឡាយ មានទន្លេ និងស្ទឹងជាដើមដ៏ពេញ ដែល ញ៉ាំងសាគរ

គឺសមុទ្រឱ្យពេញ ប្រៀបដូចម្ដេចមិញ **ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ** ទានដែលទាយកទាយិកា ឧទ្ទិសឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់អ្នកដែលចែកស្ថានទៅកាន់បរលោកហើយដូច្នោះឯង **ឥច្ឆិតំ បត្ថិតំ តុម្ហំ ខិប្បមេវ សមិជ្ឈតុ** សូមឥដ្ឋផលគឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយតាំងចិត្ត ហើយចូរឱ្យសម្រេចដល់អ្នក ឱ្យបានឆាប់រួសរាន់ទាន់ចិត្ត ។ **សព្វេ បូរេន្តុ សង្កប្បា** សូមតម្រិះត្រូវទាំងពួងចូរពេញ (ដល់អ្នក)។ **ចន្ទោ បណ្ណរសោ យថា** ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត **មណិជោតិរសោ យថា** (ពុំនោះសោត) ដូចកែវមណី មានរស្មីដ៏រុងរឿង ជាកែវពិសេសអាចញ៉ាំងសេចក្ដីប្រាថ្នាទាំងពួងឱ្យសម្រេចបាន

**តេ អត្ថលទ្ធា សុខិតា ហោន្តុ វិរុឡ្ហា ពុទ្ធសាសនេ**
**អរោគា សុខិតា ហោថ សហ សព្វេហិ ញាតិភិ**

អ្នកទាំងឡាយ (ទាំងបុរសទាំងស្ត្រី) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្ដីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា

ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្ដីសុខ ព្រមទាំងញាតិទាំង-ឡាយគ្រប់ៗ គ្នា ។

# សិទ្ធិយាចនគាថា

សិទ្ធមត្ថុ សិទ្ធមត្ថុ សិទ្ធមត្ថុ ឥទំ ផលំ ឯតស្មឹ រតនត្តយស្មឹ សម្បសាទនចេតសោ សូមផលនៃចិត្តដែលជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ ផលនេះ ចូរជាផលសម្រេច ចូរជាផលសម្រេច ចូរជាផលសម្រេច

# អគ្គប្បសាទសុត្តគាថា

អគ្គតោ វេ បសន្នានំ  អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ  វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ
អគ្គស្មឹ ទានំ ទទតំ  អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ

បុណ្យដ៏ប្រសើរ រមែងចំរើន អាយុដ៏ប្រសើរផង សម្បុរៈកាយដ៏ប្រសើរផង យសស័ក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សេចក្តីសុខដ៏ប្រសើរផង កំលាំងដ៏ប្រសើរផង រមែងចំរើនដល់ជនទាំងឡាយ ដែលដឹងច្បាស់នូវធម៌ដ៏ប្រសើរ ដែលជាអ្នកជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរដោយពិត ដែលជ្រះថ្លាក្នុងព្រះពុទ្ធជាបុគ្គលដ៏ប្រសើរលើសលប់ ជាទក្ខិណេយ្យបុគ្គល រកអ្នកឯណាមួយឱ្យស្មើនឹងព្រះអង្គគ្មាន ដែលជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរជាធម៌រម្ងាប់បង់នូវរាគាទិក្កិលេស ជាធម៌នាំមកនូវសេចក្តីសុខ (ដល់អ្នកប្រតិបត្តិ) ដែលជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាស្រែបុណ្យ រកស្រែបុណ្យឯទៀត ឱ្យក្រៃលែងជាងគ្មាន ដែលជាអ្នកឱ្យនូវទានដល់បុគ្គលដ៏ប្រសើរ ។

## អគ្គស្ស ទាតា មេធាវី អគ្គធម្មសមាហិតោ

បុគ្គលមានប្រាជ្ញា ដែលមានចិត្តដំកល់ក្នុងធម៌ដ៏ប្រសើរ ហើយជាអ្នកឱ្យនូវទានដល់បុគ្គលដ៏ប្រសើរ ។

## ទេវភូតោ មនុស្សោ វា អគ្គប្បត្តោ បមោទតិ

តែងនឹងបានទៅហើយជាទេវតា ឬមនុស្ស ក៏រមែងបានដល់នូវភាវៈជាអ្នកប្រសើរហើយរីករាយសប្បាយ

## ភោជនទានានុមោទនាគាថា

**អាយុទោ ពលទោ ធីរោ វណ្ណទោ បដិភាណ-ទោ** ជនអ្នកមានបញ្ញា ជាអ្នកឱ្យនូវអាយុ ជាអ្នកឱ្យនូវកម្លាំង ជាអ្នកឱ្យនូវសម្បុរកាយ ជាអ្នកឱ្យនូវប្រាជ្ញា ។

**សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ** អ្នកមានប្រាជ្ញាជាអ្នកឱ្យនូវសេចក្តីសុខ (ដល់អ្នកឯទៀតហើយ) រមែងបាននូវសេចក្តីសុខ (នោះមកខ្លួនវិញ) ។

**អាយុំ ទត្វា ពលំ វណ្ណំ សុខញ្ច បដិភាណទោ** (បុគ្គលឯណា) បានឱ្យនូវអាយុផង នូវកំលាំងផង នូវសម្បុរកាយផង នូវសេចក្តីសុខផង (ដល់អ្នកឯទៀត) ហើយឈ្មោះថា ឱ្យនូវប្រាជ្ញា ។

**ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ** បុគ្គលនោះលុះបានកើតក្នុងភពណា។ រមែងមានអាយុវែង មានយសបរិវារក្នុងភពនោះ។

# ជីវតគ្គានុមោទនាគាថា

**បណ្ឌុបលាសោវ ទានិសិ** ខ្លួនអ្នកក្នុងកាលឥឡូវនេះ ជាបុគ្គលប្រៀបដូចស្លឹកឈើទុំ មានពណ៌លឿង ។

**យមបុរិសាបិ ច តេ ឧបដ្ឋិតា** បុរស (ជាបំរើ) នៃយមរាជ គឺមរណៈសោត ក៏ប្រាកដដល់អ្នកហើយ ។

**ឧយ្យោគមុខេ បតិដ្ឋសិ** អ្នកជាបុគ្គលស្ថិតនៅក្នុងប្រធាននៃសេចក្តីសាបសូន្យ ។

**បាថេយ្យំបិ ច តេ ន វិជ្ជតិ** ស្បៀង គឺកុសលរបស់អ្នកសោត ក៏គ្មាន ។

**សោ ករោហិ ទីបមត្តនោ** ចូរធ្វើនូវទីពឹងនៃខ្លួនចុះ

**ខិប្បំ វាយម បណ្ឌិតោ ភវ** អ្នកចូរតាំងព្យាយាមរួតរះ ចូរជាអ្នកឈ្លាស (កុំជាអ្នកល្ងង់ខ្លៅឡើយ) ។

**និទ្ធន្តមលោ អនង្គណោ ទិព្វំ អរិយភូមិមេហិសិ** អ្នក (កាលធ្វើយ៉ាងនេះ) នឹងជាបុគ្គលមានមន្ទិល (មានរាគៈជាដើម) ខ្ជាត់ចេញមិនមានគ្រឿងពូន គឺកិលេស ហើយ

នឹងដល់នូវអរិយភូមិដ៏ជាទិព្វ

## សាមញ្ញានុមោទនាគាថា

**សព្វីតិយោ វិវជ្ជន្តុ** សូមឱ្យចង្រៃទាំងពួង ទាំងឡាយប្រាសចេញ គឺថា ចូរឱ្យចៀសវាងចេញឆ្ងាយទៅ **សព្វរោគោ វិនស្សតុ** សូមឱ្យរោគទាំងពួង (របស់អ្នក) ជាសះស្បើយទៅ ។

**មា តេ ភវត្វន្តរាយោ** អន្តរាយកុំបីមានដល់អ្នកឡើយ **សុខី ទីឃាយុកោ ភវ** សូមឱ្យអ្នកជាបុគ្គលមានសេចក្ដីសុខ មានអាយុវែង ។

**អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**
**ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ**

ធម៌គឺពរទាំងឡាយ ៤ ប្រការ គឺអាយុ ១ ពណ៌សម្បុរកាយ១ សេចក្ដីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្ដីឱនកាយថ្វាយបង្គំ ដល់ព្រះរតនត្រ័យជាប្រក្រតី និងអ្នកដែលមានសេចក្ដីគោរពកោតក្រែង ដល់បុគ្គល ដែលជា

អ្នកមានសេចក្តីចម្រើនដោយគុណ មានសីលគុណជាដើម ឬ ដែលចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ

# មង្គលចក្កវាឡ

សព្វពុទ្ធានុភាវេន ដោយអានុភាព នៃព្រះពុទ្ធគ្រប់ព្រះអង្គ ។ សព្វធម្មានុភាវេន ដោយអានុភាពនៃ ព្រះធម៌ទាំង-ពួង ។ សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង ។ ពុទ្ធរតនំ ធម្មរតនំ សង្ឃរតនំ តិណ្ណំ រតនានំ អានុភាវេន ដោយអានុភាពនៃព្រះរតនៈទាំង ៣ គឺ ពុទ្ធរតនៈ១ ធម្មរតនៈ ១ សង្ឃរតនៈ ១ ។

ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន ដោយអានុ-ភាពនៃព្រះធម្មក្ខន្ធ ៨ ម៉ឺន ៤ ពាន់ ។

បិដកត្តយានុភាវេន ដោយអានុភាពនៃព្រះត្រៃបិដក

ជិនសាវកានុភាវេន ដោយអានុភាពនៃសាវ័ក នៃព្រះជិនស្រី ។

សព្វេ តេ រោគា រោគទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ ភយា ភ័យទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ អន្តរាយា អន្តរាយទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ ឧបទ្ទវា ឧបទ្រពទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ ទុន្និមិត្តា និមិត្តអាក្រក់ទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ អវមង្គលា អពមង្គលទាំងឡាយទាំងពួងនៃអ្នក ។ វិនស្សន្តុ សូមឱ្យវិនាសបាត់ទៅ ។

អាយុវឌ្ឍកោ សេចក្តីចម្រើនដោយអាយុ

ធនវឌ្ឍកោ សេចក្តីចម្រើនដោយទ្រព្យ

សិរីវឌ្ឍកោ សេចក្តីចម្រើនដោយសិរីសួស្តី

យសវឌ្ឍកោ សេចក្តីចម្រើនដោយយសបរិវារ

ពលវឌ្ឍកោ សេចក្តីចម្រើនដោយកំលាំង

វណ្ណវឌ្ឍកោ សេចក្តីចម្រើនដោយសម្បុរកាយ

សុខវឌ្ឍកោ សេចក្តីចម្រើនដោយសុខ

ហោតុ សព្វទា សូមឱ្យមានដល់អ្នកឱ្យបានសព្វៗកាល

**ទុក្ខរោគភយា វេរា** សេចក្តីទុក្ខ និងរោគ និងភ័យ និងពៀរទាំងឡាយក្តី ។ **សោកា សត្តូចុបទ្ទវា** សេចក្តីសោកទាំងឡាយក្តី សត្រូវ និងឧបទ្រពទាំងឡាយក្តី ។ **អនេកា អន្តរាយាបិ** អន្តរាយទាំងឡាយដ៏ច្រើនក្តី ។ **វិនស្សន្តុ ច តេជសា** សូមឱ្យវិនាសបាត់ទៅដោយតេជះ (នៃអានុភាព មានពុទ្ធានុភាពជាដើមនោះ) ។ **ជយសិទ្ធិ ធនំ លាភំ** សេចក្តីសម្រេចនៃជ័យជំនះក្តី ទ្រព្យក្តី លាភក្តី ។ **សោត្ថិភាគ្យំ សុខំ ពលំ** សួស្តីក្តី ជោគជ័យល្អក្តី សេចក្តីសុខក្តី កំលាំងក្តី ។ **សិរិ អាយុ ច វណ្ណោ ច** បុញ្ញសិរីក្តី អាយុក្តី ពណ៌សម្បុរកាយក្តី។ **ភោគំ វុឌ្ឍី ច យសវា** ភោគសម្បទាក្តី សេចក្តីចម្រើនក្តី មានយសក្តី ។ **សតវស្សា ច អាយុ ច** អាយុប្រមាណ ១ រយឆ្នាំក្តី ។ **ជីវសិទ្ធី ភវន្តុ តេ** សេចក្តីសម្រេចនៃកិរិយាចិញ្ចឹមជីវិតជាសុខក្តី (ទាំងអស់នេះ សូមឱ្យមានដល់អ្នក)

ពិចារណានូវគ្រឿងឧបភោគ-បរិភោគ

ឱ្យឃើញត្រឹមតែធាតុ

## ធាតុប្បច្ចវេក្ខណៈ បាលី-ប្រែ:

ធាតុប្បច្ចវេក្ខណៈនោះ គឺត្រូវពិចារណា ក្នុងពេលដែលទទួលនូវបច្ច័យ ៤ ឱ្យឃើញថា ជាធាតុ ។ កាលដែលទទួលនូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

សំពត់ចីវរឯណានេះ សំពត់ចីវរនេះ គ្រាន់តែជាធាតុពិតប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកប្រើប្រាស់សំពត់ចីវរនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ**

**បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្ត-កោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

ចង្ហាន់បិណ្ឌបាតឯណានេះ ចង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគចង្ហាន់បិណ្ឌបាតនោះក្តី ក៏គ្រាន់តែជាធាតុមិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

**យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

ទីសេនាសនៈឯណានេះ ទីសេនាសនៈនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគប្រើប្រាស់ទីសេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវគិលានប្បច្ច័យ ឱ្យពិចារណា ដូច្នេះថា:

យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជ-កោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុមិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ

# បដិក្កូលប្បច្ចវេក្ខណៈ

បដិក្កូលប្បច្ចវេក្ខណៈ គឺត្រូវពិចារណាក្នុងខណៈ ដែលប្រារព្ធនឹងបរិភោគនូវបច្ច័យ ៤ ឱ្យឃើញថាជារបស់បដិក្កូល គួរខ្ពើមរអើម ។ កាលដែលប្រារព្ធនឹង ប្រើប្រាស់នូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

**សព្វានិ បនិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។**

សំពត់ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រាថ្នានឹងបរិភោគ នូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

**សព្វោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។**

ចង្ហាន់បិណ្ឌបាតទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រាថ្នានឹងប្រើប្រាស់ នូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

**សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនី-យានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ**

ជាយន្តិ ។

ទីសេនាសនៈទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងបរិភោគនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក

# តង្ខណិកប្បច្ចវេក្ខណៈ

តង្ខណិកប្បច្ចវេក្ខណៈនោះ គឺគប្បីពិចារណាក្នុងខណៈដែលបរិភោគនូវបច្ច័យ ៤ ។

កាលដែលប្រើប្រាស់នូវចីវរប្បច្ច័យ ឱ្យពិចារណាថា:

**បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។**

បព្វជិតគប្បីពិចារណាដោយឧបាយថា :

អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរ កំណត់ទុកដើម្បីការពារនូវត្រជាក់ ដើម្បីនឹងការពារ នូវសម្ផស្សរបោមមូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំងនូវអវៈយវៈដែលធ្វើនូវសេចក្ដីខ្មាសឱ្យកម្រើក។

កាលដែលបរិភោគ នូវបិណ្ឌបាតប្បច្ច័យ គប្បីពិចារណាដូច្នេះថា :

**បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ**

នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

បញ្ជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានះស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែង រាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រិយ ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារី អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង និងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្ត ទៅនៃឥរិយាបថទាំង

៤ ក្តី សេចក្តីមិនមានទោស មានមិនប្រអូសកាយ មិនប្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។

កាលដែលបរិភោគប្រើប្រាស់ នូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថាៈ

**បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។**

បព្វជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេពគឺបរិភោគប្រើប្រាស់នូវសេនាសនៈកំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីការពារនូវកំដៅ ដើម្បីការពារនូវសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបន្ទោបង់នូវគ្រោះរំលាយ ដែលកើតឡើងអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

កាលដែលបរិភោគនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះថា៖

**បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជ-បរិក្ខារំ បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យា-ពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈ-បរមតាយាតិ ។**

បព្វជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ទុកដើម្បីនឹង ការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា

# អតីតប្បច្ចវេក្ខណៈ

អតីតប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណានូវបច្ច័យ ៤ ក្នុងអតីតកាល គឺកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណាបានក្នុងថ្ងៃនោះ គឺក្នុងវេលាថ្ងៃ ១ យប់ ១ កុំឱ្យអរុណរះឡើង

ទាន់ ហើយក្នុងបច្ចវេក្ខណៈមួយៗ ពិចារណា ១ ចប់ ឬ ២ ចប់ ៣ ចប់ ឬច្រើនជាងនេះទៅទៀតក៏បាន ។

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិ-ឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។**

សំពត់ចីវរឯណា ដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារ នូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំង នូវអវយវៈដែលធ្វើនូវសេចក្ដីខ្មាសឱ្យកម្រើកបាន ។

**អជ្ជ មយា អបច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា**

ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុ-វិហារោចាតិ ។

ចង្ហាន់បិណ្ឌបាតឯណា ដែលអញមិនបានពិចារណា ហើយបរិភោគហើយក្នុងថ្ងៃនេះ ចង្ហាន់បិណ្ឌបាតនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងលេង ដូចក្មេងអ្នក ស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានៈស្រវឹង ដូចអ្នក ប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រីយ៍ ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់ នូវសេចក្ដីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារី អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្ដីឃ្លានដែលមានហើយផង នឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្ដី សេចក្ដីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្តជា

ដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមាន ដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិ-ឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយ វិនោទនំ បដិសល្លានារាមត្ថំ ។**

ទីសេនាសនៈឯណា ដែលអញមិនបានពិចារណា ហើយ បរិភោគប្រើប្រាស់ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញ បរិភោគកំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការ-ពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្ស របោមមូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹង បន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំ នៅក្នុងកម្មដ្ឋាន ។

**អជ្ជ មយា អបច្ចវេក្ខិត្វា យោ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារោ បរិភុត្តោ សោ យាវទេវ**

# ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណា ដែលអញមិនបានពិចារណាហើយបរិភោគ ហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគកំណត់ទុកដើម្បី នឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

**ចំណាំ :** បើកាលដែលទទួល និងកាលដែលប្រារព្ធ ដើម្បីបរិភោគ និងកាលដែលបរិភោគនោះ បានពិចារណា ដោយធាតុប្បច្ចវេក្ខណៈ ដោយបដិកូលប្បច្ចវេក្ខណៈ ដោយតង្ខណិក-ប្បវេក្ខណៈរួចសព្វគ្រប់ហើយ និងមិនបាច់ពិចារណាក្នុងអតីត-ប្បច្ចវេក្ខណៈទៀត ក៏បានដែរ

# បដិច្ចសមុប្បាទ

**អវិជ្ជាបច្ចយា សង្ខារា** សង្ខារទាំងឡាយ (កើតមាន) ព្រោះបច្ច័យ គឺអវិជ្ជា ពោលគឺសេចក្ដីល្ងង់ ។

**សង្ខារប្បច្ចយា វិញ្ញាណំ** វិញ្ញាណ (កើតមាន) ព្រោះបច្ច័យ គឺសង្ខារ ។

**វិញ្ញាណប្បច្ចយា នាមរូបំ** នាម និងរូបកើតមាន ព្រោះបច្ច័យ គឺវិញ្ញាណ ។

**នាមរូបប្បច្ចយា សឡាយតនំ** អាយតនៈ ៦ (កើតមាន) ព្រោះបច្ច័យ គឺនាម និងរូប ។

**សឡាយតនប្បច្ចយា ផស្សោ** សម្ផស្ស (កើតមាន) ព្រោះបច្ច័យ គឺអាយតនៈ ៦ ។

**ផស្សប្បច្ចយា ផស្សោ** សម្ផស្ស (កើតមាន) ព្រោះបច្ច័យ គឺអាយតនៈ ៦ ។

**ផស្សប្បច្ចយា វេទនា** វេទនា (កើតមាន) ព្រោះបច្ច័យ គឺសម្ផស្ស ។

**វេទនាបច្ចយា តណ្ហា** តណ្ហា (កើតមាន) ព្រោះបច្ច័យ គឺវេទនា ។

**តណ្ហាបច្ចយា ឧបាទានំ** ឧបាទាន (កើតមាន) ព្រោះបច្ច័យ គឺតណ្ហា ។

**ឧបាទានប្បច្ចយា ភវោ** ភព (កើតមាន) ព្រោះបច្ច័យ គឺឧបាទាន ។

**ភវប្បច្ចយា ជាតិ** ជាតិ (កើតមាន) ព្រោះបច្ច័យ គឺភព

**ជាតិប្បច្ចយា ជរាមរណំ** ជរា និងមរណៈ (កើតមាន) ព្រោះបច្ច័យ គឺជាតិ ។

**សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងកើតមាន (ព្រោះជាតិជាបច្ច័យដែរ)។ **ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** កិរិយាកើតមាននៃកងទុក្ខទាំងអស់នេះ មានដោយ ប្រការដូច្នេះ ។

អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារ-និរោធោ កិរិយារលត់នៃសង្ខារ ព្រោះកិរិយារលត់ ដោយអរិយមគ្គ ឥតមានសេសសល់នៃអវិជ្ជាមែនពិត ។

សង្ខារនិរោធា វិញ្ញាណនិរោធោ កិរិយារលត់នៃវិញ្ញាណ ព្រោះរលត់នៃសង្ខារ ។

វិញ្ញាណនិរោធា នាមរូបនិរោធោ កិរិយារលត់នៃនាម និងរូប ព្រោះកិរិយារលត់នៃវិញ្ញាណ ។

នាមរូបនិរោធា សឡាយតននិរោធោ កិរិយារលត់នៃអាយតនៈ ៦ ព្រោះរលត់នៃនាម និងរូប ។

សឡាយតននិរោធា ផស្សនិរោធោ កិរិយារលត់នៃសម្ផស្ស ព្រោះរលត់នៃអាយតនៈ ៦ ។

ផស្សនិរោធា វេទនានិរោធោ កិរិយារលត់នៃវេទនា ព្រោះរលត់នៃសម្ផស្ស ។

វេទនានិរោធា តណ្ហានិរោធោ កិរិយារលត់នៃតណ្ហា ព្រោះរលត់នៃវេទនា ។

**តណ្ហានិរោធា ឧបាទាននិរោធោ** កិរិយារលត់នៃឧបាទាន ព្រោះរលត់នៃតណ្ហា ។

**ឧបាទាននិរោធា ភវនិរោធោ** កិរិយារលត់នៃភព ព្រោះរលត់នៃឧបាទាន ។

**ភវនិរោធា ជាតិនិរោធោ** កិរិយារលត់នៃជាតិ ព្រោះរលត់នៃភព ។

**ជាតិនិរោធា ជរាមរណំ** ជរា និងមរណៈ (រលត់) ព្រោះកិរិយារលត់នៃជាតិ ។

**សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងរលត់ទៅ (ព្រោះកិរិយារលត់នៃជាតិដែរ) ។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ** កិរិយារលត់ទៅនៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ ។

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ

ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត មានកិរិយាកើតឡើង នឹងវិនាសទៅវិញជាធម្មតា រមែងតែកើតឡើងហើយរលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង ។

អចិរំ វត យំ កាយោ បឋវឹ អធិសេស្សតិ

ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

កាយនេះ មិននៅយូរប៉ុន្មានឡើយ តែមានវិញ្ញាណទៅប្រាសហើយ ជាកាយគឺគេបោះបង់ចោល ក៏នឹងដេកសង្កត់នៅលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

សព្វេ សត្តា មរិស្សន្តិ មរណន្តំ ហិ ជីវិតំ

យថាកម្មំ គមិស្សន្តិ បុញ្ញបាបផលូបគា និរយំ

បាបកម្មន្តា បុញ្ញកម្មា ច សុគតឹ ។

សត្វទាំងឡាយទៀងតែនឹងស្លាប់គ្រប់ៗគ្នា ព្រោះថា ជីវិត (របស់សត្វទាំងឡាយ) សុទ្ធតែមានសេចក្តីស្លាប់ នៅខាងចុង

បំផុតគ្រប់ៗប្រាណ (ម្យ៉ាងទៀត) សត្វទាំងឡាយ រមែងកាន់យកនូវផលបុណ្យ ផលបាប ហើយនឹងទៅតាមយថាកម្ម គឺទៅតាមគួរដល់អំពើល្អ និងអាក្រក់ដែលខ្លួនបានធ្វើ អ្នកដែលធ្វើបាបតែងធ្លាក់ទៅសោយទុក្ខក្នុងនរក ចំណែកខាងអ្នកធ្វើបុណ្យ តែងឡើងទៅកាន់សុគតិភព ។

**តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ**
**បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ។**

ព្រោះហេតុដូច្នោះហើយ សាធុជនអ្នកមានចំណង់ចង់បានសេចក្ដីសុខដល់ (ខ្លួន) គួរតែប្រញាប់ប្រញាល់ ធ្វើអំពើបុណ្យដែលជាគុណ គឺអ្នកប្រាជ្ញតែងរាប់អានឱ្យបានជានិច្ច គឺខ្លួនត្រូវកសាងសន្សំ (គ្រាន់នឹងបានជាទីពឹង) ទៅក្នុងភពខាងនាយ (ព្រោះថា) បុណ្យទាំងឡាយ តែងជាទីពឹងពុំនាក់របស់សត្វទាំង-ឡាយ ក្នុងបរលោក ។

**អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ**
**អបវិដ្ឋោ តទា សេតិ និរត្ថំវ កលិង្គរំ ។**

អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែលះបង់នូវកាយនេះ ទៅក្នុងកាលណាហើយ (កាយនេះក៏ដល់នូវសេចក្តីមិនគួរ នឹងទុក

ដាក់ឱ្យនៅលើផ្ទះសម្បែងបានឡើយ) គេតែងនាំយកទៅចោល ឱ្យដេកនៅ (លើផែនដី) ក្នុងកាលណោះឯង ដូចជាអង្កត់ឧស រកប្រយោជន៍គ្មានឡើយ ។

**យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ**

គង្វាលគោ គៀងគោទាំងឡាយ ទៅកាន់ទីគោចរ ដោយ អាជ្ញា គឺដំបង ឬរំពាត់ យ៉ាងណាមិញ ជរា គឺសេចក្ដីទ្រុតទ្រោមគ្រាំគ្រា និងមច្ចុរាជ គឺសេចក្ដីស្លាប់ ក៏គៀងទៅនូវអាយុរបស់សត្វទាំង-ឡាយ យ៉ាងនោះឯង

**ផេណុបិណ្ឌូបមំ រូបំ វេទនា បុព្វុឡូបមា មរីចិកូបមា សញ្ញា សង្ខារា កទលូបមា មាយូបមញ្ចវិញ្ញាណំ ទេសិតា ទិច្ចពន្ធុនា**

រូបមានសេចក្ដីប្រៀបធៀបនឹងដុំនៃពពុះទឹក វេទនាមានសេចក្ដី ប្រៀបធៀបនឹងក្រពេញទឹក ដែលប៉ោងឡើងព្រូចៗ សញ្ញាមាន សេចក្ដីប្រៀបធៀបនឹងថ្ងៃបណ្ដើរកូន សង្ខារទាំងឡាយ មាន សេចក្ដីប្រៀបធៀបនឹងដើមចេក វិញ្ញាណមានសេចក្ដីប្រៀប

ធៀបនឹងកលមាយា (សេចក្តីប្រៀបធៀបនៃខន្ធទាំង ៥ នេះ) គឺព្រះសម្ពុទ្ធមានផៅពង្សដ៏ខ្ពង់ខ្ពស់ ដូចជាព្រះអាទិត្យ ព្រះអង្គទ្រង់សម្តែងហើយ ។

## បឋមពុទ្ធវចនៈ

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

កាលតថាគតស្វែងរកជាងផ្ទះ (គឺតណ្ហា) មិនទាន់ជួបប្រទះតថាគតក៏ត្រាច់ទៅមក១ ក្នុងវដ្តសំសារ អស់ជាតិជាអនេក ការ

កើតក៏ជាទុក្ខញយៗ នៃ ! ជាងផ្ទះ គឺតណ្ហា ឥឡូវនេះ តថាគត ឃើញជាងឯងហើយ, ជាងឯងនឹងសង់ផ្ទះ គឺអត្តភាពរបស់តថា-គតតទៅទៀតមិនបានទេ ព្រោះឆ្អឹងជំនី គឺ (កិលេសដ៏សេស) ទាំងអស់របស់ជាងឯង តថាគតបានកាច់បំបាក់អស់រលីង គ្មានសល់ទេ (ទាំង) ដំបូលផ្ទះ គឺអវិជ្ជា តថាគតក៏រុះរើចោលចេញអស់រលីងហើយដែរ ចិត្តរបស់តថាគត បានដល់នូវព្រះនិព្វានដែលប្រាសចាកសង្ខារហើយ តថាគតដល់នូវការអស់ទៅនៃតណ្ហាទាំងឡាយហើយ ។

## bcäimBuT§vcn³

**យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ** ម្នាលអានន្ទ សភាវៈឯណា គឺព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយ ដល់អ្នកទាំងឡាយ ។

**សោ វោ មមច្ចយេន សត្ថា** សភាវៈ គឺព្រះធម៌ និង ព្រះវិន័យនោះ លុះអំណើះតតអំពីតថាគតទៅហើយ នឹងបានជា គ្រូប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

អហំ ឯកកោវ បរិនិព្វាយិស្សាមិ តថាគតជាព្រះពុទ្ធមួយអង្គឯងពិត នឹងបរិនិព្វានទៅ ។

អហញ្ច បនិទានិ ឯកកោវ ឱវទាមិ អនុសា-សេមិ តែថា ឥឡូវនេះ តថាគតជាព្រះពុទ្ធមួយអង្គឯងពិត តែងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

មយិ បរិនិព្វុតេ កាលបើតថាគតបរិនិព្វានទៅហើយ ។

ឥមានិ ចតុរាសីតិសហស្សធម្មក្ខន្ធានិ តុម្ហេ ឱវទិស្សន្តិ អនុសាសិស្សន្តិ ព្រះធម្មក្ខន្ធ ៨ ហ្មឺន ៤ ពាន់នេះ នឹងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ជាខាងក្រោយ ។

យោ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិធម៌វិន័យតាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្តីគោរពកោតក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាមធម៌

វិន័យជាប្រក្រតី ។

**សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ** បុគ្គលទាំងអស់នោះ បានឈ្មោះថា ធ្វើសក្ការៈនឹងតថាគត ធ្វើនូវសេចក្ដីគោរពរាប់អាន បូជានូវតថាគត ដោយបដិបត្តិបូជា ជាបូជាយ៉ាងក្រៃលែង ។

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ឥទម្បច្ឆិមពុទ្ធវចនំ** ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងផ្ដាំនូវអ្នកទាំងឡាយ ឱ្យបានដឹងគ្រប់គ្នា នៃភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅ និងសាបសូន្យទៅជាធម្មតា ។ អ្នករាល់គ្នា ចូរញុំាងប្រយោជន៍ ឱ្យដល់ព្រមដោយអប្បមាទៈ គឺការមិនបណ្ដែតបណ្ដោយក្នុងធម៌វិន័យ ពាក្យប្រៀនប្រដៅមានប្រមាណប៉ុណ្ណេះជាដើមនេះ ឈ្មោះថា បច្ឆិមពុទ្ធវចនៈ ជាពាក្យផ្ដាំពៅបំផុតរបស់ព្រះពុទ្ធជាម្ចាស់នៃយើង ។

**ឧភិន្នមន្តរេ យំ វុត្តំ ឯតំ មជ្ឈិមពុទ្ធវចនំ** ពាក្យប្រដៅឯណា ដែលទ្រង់ត្រាស់ពោលជាចន្លោះនៃបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ទាំងពីរនេះ ពាក្យប្រដៅនោះ ឈ្មោះថា មជ្ឈិមពុទ្ធវចនៈ គឺពាក្យប្រដៅ ជាកណ្តាលរបស់ព្រះពុទ្ធ ជាបរមគ្រូ (នៃយើង)

# PasietavaTsegçb

**ឧកាស** ខ្ញុំសូមគោរព !

**យោ បន ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិបដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ ។**

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ ជាប្រក្រតី អ្នកនោះឈ្មោះថា ធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួន ឱ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ ។**

អំណត់ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំង-ឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេក និងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**សីលសមាធិគុណានំ ខន្តិ បធានការណំ**
**សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ ។**

សេចក្តីអត់ធន់ ជាហេតុ ជាទីតាំងនៃគុណ គឺសីល និងសមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចំរើនដោយសេចក្តីអត់ធន់មែនពិត ។

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**
**គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ ។**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថា ជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀល និងការឈ្លោះប្រកែកជាដើម ។

**ខន្តិ ធីរស្ស លង្ការោ ខន្តិ តបោ តបស្សិនោ**

ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុខាវហា ។

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការ របស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែល មានតបធម៌ សេចក្តីអត់ធន់ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។

ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា
បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ ។

អ្នកអត់ធន់ ជាអ្នកមានមិត្រសំឡាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកអត់ធន់រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃទេវតា និងមនុស្សទាំងឡាយ ។

អត្តនោបិ បរេសញ្ច អត្ថាវហោ វ ខន្តិកោ
សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ ។

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ជាអ្នកឡើងកាន់ផ្លូវជាទីទៅស្ថានសួគ៌ និងព្រះនិព្វាន ។

សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ

**បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ ។**

អ្នកអត់ធន់ ឈ្មោះថា ធ្វើតាមនូវព្រះពុទ្ធដីកា ជាឱវាទនៃព្រះសាស្ដាមែនពិត អ្នកអត់ធន់ ឈ្មោះថា បូជានូវព្រះវិជិតមារដោយការបូជាដ៏ឧត្តម ។

**ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ ។**

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយ បានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយ បានដោយកម្រ កិរិយាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង ។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្ដីសុខ កិរិយាសំដែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្ដីសុខ សេចក្ដីព្រមព្រៀងគ្នារបស់សង្ឃ ឬពួកក្រុម នាំមកនូវសេចក្ដី

សុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្តីសុខ ។

សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ
អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ ។

សេចក្តីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ (ក្នុងទីស្ងាត់) ជាអ្នកមានធម៌បានស្តាប់ហើយ ពិចារណាឃើញ (នូវធម៌) នាំមកនូវសេចក្តីសុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ
អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ ។

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាស នូវអស្មិមានៈនេះឯង នាំមកនូវសេចក្តីសុខដ៏ឧត្តម ។

កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ។

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក កិរិយា

រស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្តាប់នូវព្រះសទ្ធម្មជាការកម្រ កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក ។

**សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មឹ ជិនសាសនេ កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ ។**

បុគ្គលឯណាបានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅ នៃព្រះវិជិតមារទាំងពួង បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ អស់សែនកប្ប ។

**បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ ។**

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជំរះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹកទ្រង់ស្តេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាចទ្រង់សំដែងធម៌ទេសនា ១ ក្នុងពេលព្រលប់ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអាធ្រាត្រ ទ្រង់

ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ [១] ទ្រង់ប្រមើលមើលនូវសត្វលោក ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១ ។

**កុក្កុដេ គព្ភវាសោ ច សោណេ ចុទរនិក្ខមិ ឧសភេ រាជសម្បត្តិ សសេ បព្វជិតោ ជិនោ ។**

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះ គភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតិចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួស ក្នុងឆ្នាំថោះ ។

**កុក្កុដេ សព្វញ្ញុពុទ្ធោ តត្ថ ចក្កំ បវត្តយិ និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ ។**

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ ក្នុងឆ្នាំរកា ទ្រង់សំដែងនូវព្រះធម្មចក្រ ក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វាន ក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥.០០០ គត់ ក្នុងឆ្នាំជូត ។

---

[១] ក្នុងអដ្ឋកថាធម្មបទសំដែងថាព្រះអង្គប្រមើលមើលឧបនិស្ស័យសត្វ ក្នុង ១ ថ្ងៃ ១ យប់ ពីរដង គឺក្នុងពេលជិតភ្លឺម្តង ពេលល្ងាចម្តង ។ ពេលជិតភ្លឺ ទ្រង់ប្រមើលមើលពីកណ្តាប់មាត់ ចក្រវាឡ រហូតដល់មកគន្ធកុដិ ពេលល្ងាច ទ្រង់ប្រមើលមើលពីគន្ធកុដិ រហូតដល់កណ្តាប់មាត់ចក្រវាឡ ។ ប្រមើលមើលនូវសត្វលោកដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១ ។

ឱក្កន្តោ ច គុរុវារស្មឹ សុក្រវារេ ច និក្ខមិ
សម្ពុទ្ធោ ពុធវារស្មឹ អង្គារេ បរិនិព្វុតោ ។

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។

អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ
វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ ។

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា)ក្នុងថ្ងៃ ពេញបូណ៌មីខែអាសាធ ប្រសូតិក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ។

និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ
បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ
ចតុរាសីតិសហស្ស. ធម្មក្ខន្ធា សុទេសិតា
អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ បាណិនំ ។

កាលព្រះសម្មាសម្ពុទ្ធជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមាផង ព្រះពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ហ្មឺន ៤ ពាន់ ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សំដែងហើយ ដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងស្ថានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។

**ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ ឋបេត្វា សម្មាសម្ពុទ្ធេន វុត្តប្បការេន បដិបត្តិបូជាយ បូជំ ករោន្តេន លោកិយលោកុត្តរសម្បត្តិសិទ្ធំ កាតព្វំ ឱកាស អារាធនំ ករោមិ ។**

បុគ្គលគួរដំកល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង ហើយទុកក្នុងចិត្ត ហើយធ្វើការបូជាដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សំដែងហើយ គួរធ្វើឱ្យសម្រេចនូវសម្បត្តិជាលោកិយ និងលោកុត្តរ ខ្ញុំសូមគោរពអារាធនាទុក ដោយប្រការដូច្នេះ ។

ឧកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវៈ-
ប្បច្ចូសសមយេ កុសិនារាយ យមកសាលានមន្តរេ
អមុម្ហិ សប្បសំវច្ឆរេ គិម្ហ ឧតុម្ហិ វិសាខមាសេ
សុក្កបក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ
អនុរាធនក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបា-
ទិសេសាយ និព្វានធាតុយា ។

ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងបច្ចូសម័យ ដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តប្ញក្ស ឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើត ខែវិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះហោង

(តពីនេះទៅ ត្រូវបកសករាជប្រាប់ថ្ងៃ ខែ ឆ្នាំ ដែលជាអតីតៈ បច្ចុប្បន្ន និងអនាគត ដរាបដល់ចប់) ។

# ពុទ្ធជយមង្គល

## ១_ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
## គ្រីមេខលំ ឧទិតឃោរសសេនមារំ
## ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និមិត្តដៃ ១ ពាន់ កាន់សាស្ត្រាវុធនានា ។
ជិះគ្រីមេខលជាតិ កោញ្ជនាទ ខ្ទរពសុធា
ព្រមដោយមារសេនា ពន្លឺកលន់កងស័ព្ទស៊ាន ។
ដោយធម្ម_ ពិធី ទានបារមី ជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះមារ គ្រានោះហោង ។

## ២_មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ
## ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ

## ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ

## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិននាយកៈ ផ្ចាញ់អាឡវយក្ខឃោរឃៅ
រឹងរូសមិនតាំងនៅ ក្នុងខន្តី គុណសត្យា ។
រហូតដល់រាត្រី ព្រះជិនស្រីទ្រង់ យុទ្ធនា
ក្រែលែងក្រុងមារា ក្នុងបឋម សម្ពោធិ ។
ដោយព្រះពិធីញាណ ទ្រង់ទូន្មាន ដោយខន្តី
ញុំាងចិត្ត អសុរី ឱ្យបង់ ព្យសន៍ ចុះវន្ទា
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះអាឡវយក្ខហោង។

## ៣_នាឡាគិរឹ គជវរំ អតិមិត្តភូតំ

## ទាវគ្គិចក្កមសនីវ សុទារុណន្តំ

## មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ

## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គិរី វរៈ គជា ដ៏ហានក្លាចុះព្រេងព្រេច ។

សាហាវធាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច
មុតដូច ចក្រក្រុតពេជ្រ ខ្លាំងដូចកាំ អសនី ។
ដោយព្រះពិធីស្រប់ ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញុាំងដវីរ ឱ្យជ្រះថ្លា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះនាឡាគីរី ។

## ៤.ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
## ធាវន្តិ យោជនបថង្គុលិមាលវន្តំ
## ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល៍ មានកម្រង គឺម្រាមដៃ
នៃមនុស្សដែលគាត់កាត់ មកដោតចាក់ជាមាល័យ
អង់អាចអំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវ ងារគ្រវី ដេញព្រះមុនីសាស្តាចារ្យ
ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា

ដោយតេជៈជយា ព្រះឈ្មោះអង្គុលិមាល៍ ។

៥_កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ ចាស់ចើសពោះ ។
យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្មោះកាលនោះ ដោយសមាចារពិធី ។
រម្ងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី
ចិញ្ចា ចាញ់បារមី គឺសច្ចំ ពាក្យសត្យា
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះសាស្តាឈ្មោះចិញ្ចា ។

៦_សច្ចំ វិហាយមតិសច្ចកវាទកេតុំ
វាទាភិរោបិតមនំ អតិអន្ធភូតំ
បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ

## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈ ជា និគ្រន្ថ ក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់ ។
បង្កើតម្ងូរ ងងឹត ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីប គឺបញ្ញា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ឈ្នះ សច្ចកៈ និគ្រន្ថ ។

## ៧_នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
## បុត្តេន ថេរភុជគេន ទមាបយន្តោ
## ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច
ឱ្យប្លែងជានាគរាជ ទៅទូន្មាន ព្យសន៍ ភុជង្គ ។
ឈ្មោះ នន្ទោបនន្ទ ចិត្តមោហន្ធ រឿង ឫទ្ធិរង់

ទិដ្ឋិ  កាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈ្នះ ។
គឺឱ្យ  ឧបទេស ឫទ្ធិវិសេស  ដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះភគវាឈ្នះនាគហោង ។

## ៨_ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
## ព្រហ្មំ  វិសុទ្ធិ ជុតិមិទ្ធិ ពកាភិធានំ
## ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
## តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថាអាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដៃកាន់អាសិរ្ពិស គឺចិត្តទ្រឹស្ត  ដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ។
ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ឈ្នះព្រហ្មាឥតមានហ្មង ។

## ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា

**យោ វាចនោ ទិនទិនេ សរតេ មតន្ទី**

**ហិត្វានេក វិវិធានិ ចុបទ្ទវានិ**

**មោក្ខំ សុខំ អធិកមេយ្យ នរោ សបញ្ញោ**

**យោ នរោ** ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល
ឧស្សាហ៍សាងទានសីល សូត្ររំឭកព្រះធម៌ថ្លៃ ។
គាថាប្រាំបីបទ នេះកំណត់ ឈ្មោះពុទ្ធជ័យ
ខំសូត្រសព្វៗថ្ងៃ កើតមង្គល ជានិរន្តរ៍ ។

**សោ នរោ** វីជននោះ បានរំដោះរោគអាសន្ន
ឧបទ្រព អនេកលន់ មានប្រការផ្សេងៗ ផង ។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វាន សុខកន្លង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជយមង្គលនេះ

# អារាធនាព្រះធម្មកថិក

គ្រានោះសហម្បតី ព្រហ្មជាឥ_សូរលោកា
ចូលគាល់ ព្រះសាស្ដា លើកហត្ថា សិរោរាប ។
ហើយពោល ពាក្យទូលថា សូមករុណា ស្ដេចទ្រង់ជ្រាប
ដ្បិតសត្វ អន់ទន់ទាប ទុព្វលភាព ចាបក្រៃក្រាស់ ។
ទន្ទឹង ព្រះធម៌ថ្លៃ ជានិស្ស័យ បច្ច័យច្បាស់
ឥឡូវ ទ្រង់បានត្រាស់ ត្រេកអរណាស់ ពុំកន្ដើយ ។
សត្វខ្លះ ក្រាស់ដោយកាម មិនយល់តាម ត្រៃលក្ខណ៍ឡើយ
ឥឡូវ យល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ ។
បើបានស្ដាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តប្រោសទេសនា ។
ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា
ងងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។
ត្រៃលោកគោកត្រៃលក្ខណ៍ សង្សារចក្រវិលមិនដល់
អវិជ្ជា កប្ចសគល់ ជាបច្ច័យ នៃសង្ខារ ។
នាំសត្វឱ្យសោកសៅ លិចលង់នៅក្នុងសង្សារ
បញ្ជូមារមោហន្ធការ វិតរុំហុំជុំជាប់នៅ ។

ហេតុនោះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ
ចម្លងសត្វឆ្លោះទៅ កាន់ត្រើយត្រានិព្វាននាយ ។
ដូចកល់ប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វ ទាំងឡាយ ឱ្យសប្បាយ ក្សាន្តភិរម្យ ។
ព្រះសទ្ធម្ម ជាស្គរជ័យ ព្រះវិន័យ ជារាងធំ
ព្រះសូត្រ ជាខ្សែរុំ ព្រះអភិធម្ម ជាស្បែកដាស់ ។
អរិយសច្ច ជាអណ្តូង សម្រាប់ទូង ឱ្យឮច្បាស់
សត្វលោកងោកងុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។
បរិស័ទ បួនជំពូក ដូចផ្កាឈូក ក្នុងជលដ្ឋាន
ខ្លះផុស ចាំសូរ្យឆាន រះនឹងរីក ដោយរស្មី ។
ព្រះធម៌ ជាសូរ្យសែង រះឡើងចែង ចាំងរស្មី
បំភ្លឺ លោកទាំងបី ឱ្យយល់ផ្លូវ ឋានសុខា ។
សហម្បតិ្ត ព្រហ្ម ឱនបង្គំ អារាធនា
សម្តេច ព្រះភគវា ដោយគាថា យ៉ាងនេះឯង ។
ព្រះពុទ្ធ ទ្រង់អនុកូល ព្រមទទួល នឹងសម្តែង
ដោយតុណ្ហីភាពថ្លែង តាមភាវៈ គុណករុណា ។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះ ព្រៃមិគទា
យាងចេញ ចរលីលា ពីទីនោះ ដោយព្រះបាទ ។

ញុំាងសត្វ ចូលពុទ្ធចក្រ មានបញ្ចវគ្គីយ៍ ជាអាទិ៍
ឱ្យផឹក អម្រឹតជាតិ រស់និព្វាន តាមធម្មតា ។
ចាប់ដើម ពីនោះឯង ទ្រង់សម្តែង ធម៌ទេសនា
ធ្វើពុទ្ធ ក្រឹត្យា អស់វស្សា សែសិបប្រាំ ។
ពុំថយ ពុំបន្ធូរ ប្រយោជន៍យូរ អង្វែងឆ្នាំ
សម្រេច បុណ្ណកម្ម ដល់សព្វសត្វ ទាំងភពត្រៃ ។
ហេតុនោះ ឥឡូវនេះ យើងខ្ញុំនេះ សាទរក្រៃ
បពិត្រ ព្រះគុណថ្លៃ សូមនិមន្ត ប្រោសទេសនា ។
អនុគ្រោះ ពួកបរិស័ទ ដែលជាប់ខាត់ ដោយមោហា
ឱ្យកើត មានបញ្ញា ប្រាកដនា ទីនេះហោង

ចប់

**យទិ ហីនេ គតោ ឋានេ កាយទុច្ចរិតេន វា**

បើញាតិណាមួយ ទៅកើតក្នុងទីដ៏ថោកទាប ព្រោះកាយទុច្ចរិតក្តី (វចីទុច្ចរិតក្តី មនោទុច្ចរិតក្តី) ។

**ឥមិនា បុញ្ញតេជេន តម្ហា ឋានា បមុញ្ចតុ**

ក៏សូមឱ្យរួចរំដោះចាកទី (ដ៏ថោកទាប) នោះ ដោយតេជះ គឺបុណ្យនេះ ។

**យទិ ទេវបុរេ រម្មេ វិមានេ រតនសោភិតេ ឬ**

បើទៅកើតក្នុងទេវបុរី ជាវិមានគួររីករាយ ដែលជាឋានមានលំអរដោយរតនៈផ្សេងៗ ស្រាប់ហើយ ។

**ឥមិនា បុញ្ញតេជេន ភិយ្យោ ភិយ្យោ បវឌ្ឍតិ**

ក៏សូមឱ្យរឹងរឹតតែចម្រើនជាភិយ្យោភាព ដោយតេជៈគឺបុណ្យនេះ។

**ឯវំ មហិទ្ធិយា ឯសា យទិទំ បុញ្ញសម្បទា**

**បុញ្ញសម្បទា** គឺគុណជាតិជាហេតុដល់ព្រម ដោយបុណ្យឯណា បុញ្ញសម្បទានេះ មានឫទ្ធិដ៏ធំក្រៃលែង ដោយប្រការយ៉ាងនេះ ។

**តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ**
ព្រោះហេតុនោះ បណ្ឌិតទាំងឡាយអ្នកមានប្រាជ្ញា រមែងសរសើរនូវភាពនៃបុគ្គលអ្នកមានបុណ្យធ្វើទុកហើយ ។

**សុខោ វិបាកោ បុញ្ញានំ** ផលរបស់បុណ្យទាំងឡាយ រមែងនាំមកនូវសេចក្ដីសុខ ។ **អធិប្បាយោ សមិជ្ឈតិ** សេចក្ដីប្រាថ្នា រមែងសម្រេច ។

**ខិប្បញ្ច បរិយោសានេ និព្វានំ សមធិគច្ឆតិ** ម្យ៉ាងទៀត ក្នុងកាលជាទីបំផុត បុគ្គលរមែងបាននូវព្រះនិព្វានដ៏ឆាប់រហ័ស ។

**យោ ភាជនសហស្សេហិ បូរណំ វរភោជនំ**
**ទទេយ្យា បរិមាណានំ ឯកបត្តម្បិ នាលភេ**
**ពុទ្ធុប្បាទេ សារីបុត្តោ យេ ចញ្ញេ អគ្គសាវកា**
បុគ្គលគប្បីឱ្យនូវវរភោជន ដ៏ពេញដោយភាជនៈមួយពាន់ ក៏មិនបានស្មើនឹងភោជនមួយបាត្រ ដែលគេបានឱ្យហើយ ដល់ព្រះសារីបុត្រ និងពួកអគ្គសាវកដទៃ ក្នុងពុទ្ធុប្បាទ (នេះ) ដែលមានគុណប្រមាណមិនបាន ។

បត្តប្ជានុភាវេន មាតាបិតា បមុញ្ចរេ (ព្រោះហេតុនោះ)បានជាមាតា និងបិតា រមែងរួច (ចាកទីដ៏ថោកទាប) ដោយអានុភាពនៃបាយដែលពេញក្នុងបាត្រ

## សុភមង្គលគាថា

ហោតុ សព្វំ សុមង្គលំ សុមង្គល គឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ រក្ខន្តុ សព្វទេវតា ទេវតាទាំង-ពួងទាំងឡាយ ចូររក្សានូវខ្ញុំ សព្វពុទ្ធានុភាវេន ដោយអានុ-ភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ សព្វធម្មានុភាវេន ដោយអានុ-ភាពនៃព្រះធម៌ទាំងពួង សព្វសង្ឃានុភាវេន ដោយអានុ-ភាពនៃព្រះសង្ឃទាំងពួង សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ។

# បរាភវសូត្រ

**ឯវម្មេ សុតំ** (សូត្រនេះឈ្មោះបរាភវសូត្រ) គឺខ្ញុំឈ្មោះអានន្ទបានស្តាប់មកហើយយ៉ាងនេះថា ៖

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។**

សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង វត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។**

លំដាប់នោះឯង ទេវតាអង្គ ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អញុំាងវត្តជេតពនជុំវិញទាំងអស់ ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា

ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គ ព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ ។**

កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា (យ៉ាងនេះ) ថា:

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ មកសូមទូលសួរ នូវហេតុដែលគួរ ចម្រើនវិនាស ប្រុសស្រីក្នុងលោ- កសន្និវាស ដែលនឹងវិនាស សាបសូន្យចាកគុណ។ ឆ្ពោះព្រះគោតម ព្រះអង្គមានបុណ្យ មេត្តានិមន្ត សម្តែងឱ្យទាន ធម្មជាតដូចម្តេច ដែលជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

(ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា:)

**១-សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ។**

អ្នកដែលចំរើន គេក៏អាចស្គាល់ងាយ អ្នកដែលអន្តរាយ គេក៏អាចស្គាលពិត

អ្នកប្រាថ្នាធម៌ ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្ត នឹងបានចម្រើន។
អ្នកដែលទ្រុស្តធម៌ ស្អប់ធម៌ឥតកើន ឥតកើនចំរើន វិនាសទៅមុខ។

**ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**

**ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១ទាន់ហន់។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**២_អសន្តស្ស បិយា ហោន្តិ សន្តេន កុរុតេ បិយំ**

**អសតំ ធម្មរោចេតិ តំ បរាភវតោ មុខំ។**

អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា អសប្បុរស
តែមិនស្រឡាញ់ ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរស មកធ្វើជាមិត្រ។
សេចក្តីស្រឡាញ់ ពេញចិត្តគំនិត ហើយទៅគប់មិត្រ អសប្បុរស
គាប់ចិត្តក្នុងធម៌ ឬមួយរបស់ ហេតុនោះទាំងអស់ នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**

**តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី២ទាន់ហន់។ បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន វិនាសទី ៣ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

៣_និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។

អ្នកដេកច្រើន១ និយាយច្រើន ១ និងអ្នកឥតព្យាយ ឥតគិតប្រឹងប្រែង អ្នកខ្ជិលច្រអូស មិនមានខ្នះខ្នែង ខឹងច្រើនសម្តែង ឱ្យគេឃើញបាន។ ហេតុធម៌ទាំងនោះ មិនជាកល្យាណ នាំឱ្យខកខាន ខាតខូចប្រយោជន៍ មានជាប្រធាន តិចច្រើនដោយហោច នាំបង់ប្រយោជន៍ ហើយឱ្យវិនាស។

ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៣ទាន់ហន់។ បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន វិនាសទី ៤ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

៤_យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ

បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ។

នរជនណា មានទ្រព្យធនធាន ហើយខ្លួនមិនបាន ចិញ្ចឹមរក្សា មាតាបិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឱ្យវិនាស។

ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ

បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៤ទាន់ហន់។ បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន វិនាសទី ៥ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

៥_យោ សមណំ ព្រាហ្មណំ វា អញ្ញំ វាបិ វនិព្វកំ

មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។

ជនបញ្ឆោតព្រាហ្មណ៍ ឬពួកសមណៈ ពួកស្មូម ឬអ្នក ដទៃៗ ។ ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ នោះប្រធាននៃ សេចក្តីវិនាស។

ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ

ឆដ្ឋំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៥ទាន់ហន់។

បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី ៦ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

## ៦_បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ

## ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។

បុរសអ្នកមាន ទ្រព្យធនធានច្រើន មាសប្រាក់ចម្រើន និងគ្រឿងអាហារ

លបលាក់របស់ ដែលឆ្ងាញ់ពិសារ ស៊ីម្នាក់ឯងជា ប្រធានវិនាស។

## ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ

## សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៦ទាន់ហន់។

បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី ៧ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

## ៧_ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ

## សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។

អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល ហើយមិនប្រមូល សាច់ញាតិសន្តាន

មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន នោះជាប្រធាន សេចក្ដីវិនាស។

# ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៧ទាន់ហន់។ បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន វិនាសទី ៨ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស ។

# ៨_ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។

ជនអ្នកប្រព្រឹត្ត ល្បែងបីប្រការ ល្បែងស្រីល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ ធ្វើទ្រព្យខ្លួនមាន ឱ្យអន្តរាយ ការល្បែងទាំងឡាយ នោះនាំវិនាស។

# ឥតិ ហេតំ វិជានាម អដ្ឋមោ សោ បរាភវោ នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៨ទាន់ហន់។ បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន វិនាសទី ៩ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស។

**៩_សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**

**ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ។**

ប្រុសមិនត្រេកអរ នឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន នឹងស្រីពេស្យា

ទ្រុស្តនឹងប្រពន្ធ កូនជននានា ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ**

**ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៩ទាន់ហន់។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី ១០ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

**១០_អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ**

**តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។**

បុរសមានវ័យ ដែលចាស់ហួសពេក ហើយមានតម្រេក ដោយក្តីតណ្ហា

នាំយកស្រីក្មេង មកធ្វើភរិយា ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទសមោ សោ បរាភវោ**

**ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១០ ទាន់ហន់។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

**១១_ឥត្ថឹ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ**
**ឥស្សរិយស្មឹ ថបេតិ តំ បរាភវតោ មុខំ។**

បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយ តាំងបុរសនោះ
ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះ នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ**
**ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១១ទាន់ហន់។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

**១២_អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ**
**កុលេ សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ។**

ជនណាកើតក្នុង ត្រកូលជាក្សត្រ អ្នកខ្សត់សម្បត្តិ ហើយប្រាថ្នាធំ

ចង់បានជាស្តេច សោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំ ឱ្យដល់វិនាស។

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ**

**អរិយទស្សនសម្បន្នោ សលោកំ ភជតេ សិវំ។**

ជនជាបណ្ឌិត គំនិតប្រសើរ បានឃើញដំណើរ នៃហេតុវិនាស

ដល់សត្វក្នុងលោ- កសន្និវាស រួចពីវិនាស គប់រកចម្រើន

## បរាភវសុត្តំ និដ្ឋិតំ

បរាភវសូត្រ ចប់

# បុព្វភាគប្បដិបត្តិ

បុរស-ស្ត្រី ដែលមានសទ្ធាជ្រះថ្លា ក្នុងគុណព្រះរតនត្រ័យ ហើយមានប្រាថ្នាប្ដេជ្ញាខ្លួនជាឧបាសក ឧបាសិកា ឱ្យបានពេញសិប់ ជាអ្នកកាន់ព្រះពុទ្ធសាសនានោះ, មុនដំបូងអង្គុស់ ត្រូវបញ្ចេញវចីភេទ សូមខមាទោសនឹងព្រះរតនត្រ័យ ក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះនឹព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធក៏បាន ចំពោះបុគ្គល គឺភិក្ខុទាំងឡាយតាំងពី ៤ រូបឡើងទៅក៏បាន លុះសូមខមាទោសរួចហើយ ត្រូវពោលប្រកាសប្ដេជ្ញាខ្លួន ឱ្យជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាឧបាសក ឧបាសិកា ក្នុងព្រះពុទ្ធសាសនារួចត្រូវសមាទាននិច្ចសីល រក្សាឱ្យខ្ជាប់តទៅ, បើមានសទ្ធាជ្រះ-ថ្លា ក៏គប្បីរក្សាឧបោសថសីលតាមកាលកំណត់ ដែលត្រូវរក្សាម្ដងៗ នោះផង នឹងមានផលានិសង្សច្រើន ដោយលំដាប់ៗឡើងទៅ ។

ឯពាក្យសូមខមាទោសនឹងព្រះរតនត្រ័យនោះ បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ ត្រូវសូធ្យថា:

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ (ប្រុសថា) យោហំ (ស្រីថា) យាហំ (ថារួមគ្នា) ភន្តេ កាយេន វា វាចាយ វា មនសា វា (ថាតាមឋានៈ) ភគវតោ វា/ ពុទ្ធស្ស វា (ថារួម) ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ (ប្រុសថា) តស្ស (ស្រីថា) តស្សា (ថារួមគ្នា) មេ ភន្តេ (ថាតាមឋានៈ) ភគវា/ អយ្យោ/ អយ្យា/ សង្ឃោ/ (ថារួម) អច្ចយំ អច្ចយតោ (ថាតាមឋានៈ) បដិគ្គណ្ហតុ បដិគ្គណ្ហតុ បដិគ្គណ្ហន្តុ បដិគ្គណ្ហតុ (ថារួម) អាយតឹ សំវរាយ ។

បពិត្រ (ថាតាមឋានៈ) ព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃទាំងឡាយ (ថារួម) ដ៏ចម្រើន ទោសកំហុស ដែលប្រព្រឹត្តកន្លងគ្របសង្កត់ នូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រ (ថាតាមឋានៈ)ព្រះដ៏មានព្រះភាគ /

ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃទាំងឡាយ (ថារួម) ដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាបានធ្វើហើយនូវសេចក្ដីល្មើសមិនគោរពដល់ (ថាតាមឋានៈ) ព្រះដ៏មានព្រះភាគក្ដី / ព្រះពុទ្ធជាម្ចាស់ក្ដី (ថារួម) ដល់ព្រះធម៌ក្ដី ដល់ព្រះសង្ឃក្ដី ដោយកាយក្ដីដោយវាចាក្ដី ដោយចិត្តក្ដី បពិត្រ (ថាតាមឋានៈ) ព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃទាំង-ឡាយ (ថារួមគ្នា) ដ៏ចម្រើន សូមព្រះ (ថាតាមឋានៈ) ដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃទាំង-ឡាយ (ថារួម) អត់នូវទោសកំហុសដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះ ជាសេចក្ដីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

រួចបើជាបុគ្គល ឬ គណៈ ឬសង្ឃ ដែលនៅជាប្រធាន ក្នុងទីនោះ ត្រូវទទួលថា **សាធុ** ប្រែថា ប្រពៃហើយ ។

បើបុរសត្រូវសូត្រថា **ឃោហំ** ថា **តស្ស មេ**, បើស្ត្រីត្រូវសូត្រថា **ឃាហំ** ថា **តស្សា មេ**, តាមគួរដល់បាលីភាសាដែលត្រូវផ្លាស់តាមបុរស-ស្ត្រី, ទោះបុរសក្ដី ស្ត្រីក្ដី បើសូមខមា-ទោសក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូប ឬចំពោះព្រះស្តូប ព្រះ

ចេតិយ ដែលមានបញ្ចុះព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធនោះ ត្រូវសូត្រថា **ភគវតោ វា** ថា **ភន្តេ ភគវា** ថា **បដិគ្គ-ណ្ហតុ**, បើចំពោះនឹងភិក្ខុ ១ រូប ត្រូវសូត្រថា **ពុទ្ធស្ស វា** ថា **ភន្តេ អយ្យោ** ថា **បដិគ្គណ្ហតុ**, បើចំពោះគណៈ គឺភិក្ខុ ២ រូប ឬ ៣ រូប ត្រូវស្ញូត្រថា **ពុទ្ធស្ស វា** ថា **ភន្តេ អយ្យា** ថា **បដិគ្គណ្ហន្តុ** បើចំពោះព្រះសង្ឃត្រូវស្ញូត្រថា **ពុទ្ធស្ស វា** ថា **ភន្តេ សង្ឃោ** ថា **បដិគ្គណ្ហតុ**, ត្រង់សេចក្តីប្រែ ក៏មានរបៀបតាមជួរបាលីដែលគាបនោះដែរ ។

បើសុទ្ធតែបុរស ឬសុទ្ធតែស្ត្រីច្រើននាក់ ឬបុរស និងស្ត្រីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅ ហើយស្ញូត្រសូមខមា-ទោសព្រមគ្នានោះ ត្រូវស្ញូត្រថា

**អច្ចយោ នោ ភន្តេ អច្ចគមា** (ប្រុសថា) **យថា-ពាលេ** (ស្រីថា) **យថាពាលា** (ប្រុសថា) **យថាមុឡ្ហេ** (ស្រីថា) **យថាមុឡ្ហា** (ប្រុសថា) **យថាអកុសលេ** (ស្រីថា) **យថាអកុសលា** (ប្រុសថា) **យេ** (ស្រីថា) **យា** (ថារួមគ្នា)

មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា (ថាតាមឋានៈ) ភគវតោ វា/ ពុទ្ធស្ស វា (ថារួមគ្នា) ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា (ប្រុសថា) តេសំ (ស្រីថា) តាសំ (ថារួមគ្នា) នោ ភន្តេ (ថាតាមឋានៈ) ភគវា/ អយ្យោ/ អយ្យា/ សង្ឃោ/ (ថារួមគ្នា) អច្ចយំ អច្ចយតោ (ថាតាមឋានៈ) បដិគ្គណ្ហតុ/ បដិគ្គណ្ហតុ/ បដិគ្គណ្ហន្តុ/ បដិគ្គណ្ហតុ/ (ថារួមគ្នា) អាយតឹ សំវរាយ

សេចក្តីប្រែដូចគ្នានឹងបែបមុនដែរ ប្លែកគ្នាតែត្រង់ពាក្យថា "ខ្ញុំព្រះករុណា" នោះ ក្នុងទីនេះ ត្រឡប់ប្រែថា "ខ្ញុំព្រះករុណាទាំងឡាយ" ដូច្នេះវិញ ក្រៅពីនោះនៅដូចគ្នាទាំងអស់ ។

បើបុរសត្រូវថា យថាពាលេ យថាមុឡ្ហេ យថា-អកុសលេ យេ មយំ តេសំ នោ ។

បើស្ត្រីត្រូវថា យថាពាលា យថាមុឡ្ហា យថា-អកុសលា យា មយំ តាសំ នោ ។ បើទុកជាគ្នាច្រើនមានបុរសមានស្ត្រីលាយគ្នា ហើយសូធ្យសូមខមាទោសព្រមគ្នា

នោះ ក៏ត្រូវតែសូធ្យខុសគ្នាត្រង់បទដែលគាបនោះដែរ វៀរលែង
តែត្រង់បទដែលគាប ៣ អន្លើ គឺត្រង់បទថា **ភគវតោ វា**
**ពុទ្ធស្ស វា, ភគវា អយ្យោ អយ្យា សង្ឃោ,**
**បដិគ្គណ្ហតុ បដិគ្គណ្ហន្តុ** នេះត្រូវសូធ្យដូចគ្នា ទាំងបុរស
ទាំងស្ត្រី តែបើគ្នាច្រើនហើយ សូធ្យសូមខមាទោសព្រមទាំង
អស់គ្នានោះ បើមិនបាច់សូធ្យដោយពាក្យជាពហុវចនៈតាមបែប
ខាងក្រោយនេះ នឹងសូធ្យដោយពាក្យជាឯកវចនៈ តាមបែបមុន
នោះក៏បាន ព្រោះសូធ្យសូមខមាទោសព្រមទាំងអស់គ្នា ។ លុះ
បានសូមខមាទោស នឹងព្រះរតនត្រ័យដូច្នេះរួចហើយ គប្បី
បញ្ចេញវចីភេទប្តេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃសរណគមន៍ គឺព្រះ
ពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ទីរឭក ដើម្បីនឹងឱ្យឡើងនាម-
បញ្ញត្តិ ជាឧបាសក ឬឧបាសិកា ក្នុងព្រះពុទ្ធសាសនាតទៅ, ឯ
ការប្តេជ្ញាខ្លួននោះ នឹងប្តេជ្ញាក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបក៏
បាន ចំពោះនឹងព្រះស្តូប ឬព្រះចេតិយដែលបញ្ចុះព្រះសារីរិក-
ធាតុព្រះដ៏មានបុណ្យក៏បាន ចំពោះមុខបុគ្គល ឬគណៈ ឬសង្ឃ
ក៏បាន, បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ សូធ្យប្តេជ្ញាខ្លួនចំពោះមុខ
បុគ្គល ឬគណៈ ឬសង្ឃនោះ ត្រូវប្តេជ្ញាដោយពាក្យថាៈ

ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច (ប្រុសថា) ឧបាសកំ (ស្រីថា) ឧបាសិកំ (ថារួមគ្នា) មំ (ថាតាមកាល) អយ្យោ / អយ្យា / សង្ឃោ /, ធារេតុ / ធារេន្តុ / ធារេតុ (ថារួមគ្នា) អជ្ជតគ្គេ បាណុបេតំ សរណំ គតំ។

ប្រែថា បពិត្រ (ថាតាមឋានៈ) ព្រះករុណា / ករុណាទាំង-ឡាយ / សង្ឃ / ដ៏ចម្រើន ខ្ញុំព្រះករុណា សូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរឭក សូម (ថាតាមឋានៈ) ព្រះករុណា/ ករុណាទាំងឡាយ/ សង្ឃ/ (ថារួមគ្នា) ជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសក ឧបាសិកា បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹង ទីរឭក ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

បុរសត្រូវថា ឧបាសកំ, បើស្ត្រីត្រូវថា ឧបាសិកំ, ត្រង់ពាក្យថា អយ្យោ ធារេតុ, អយ្យា ធារេន្តុ, សង្ឃោ ធារេតុ នេះមានសេចក្ដីអធិប្បាយ ដូចក្នុងវិធីសូមខមាទោស

ខាងដើមហើយ ។

បើគ្នាច្រើនតាំងពី ពីរនាក់ឡើងទៅ ទោះសុទ្ធតែបុរសក្តី សុទ្ធតែស្ត្រីក្តី បុរស និងស្ត្រីលាយគ្នាក្តី ត្រូវសូធ្យថា (ប្រុសថា) **ឯតេ** (ស្រីថា) **តា** (ថារួមគ្នា) **មយំ ភន្តេ សុចិរបរិ-និព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុ-សង្ឃញ្ច** (ប្រុសថា) **ឧបាសកេ** (ស្រីថា) **ឧបាសិកាយោ** (ថារួមគ្នា) **នោ** (ថាតាមឋានៈ) **អយ្យោ/ អយ្យា/ សង្ឃោ/** (ថាតាមឋានៈ) **ធារេតុ/ ធារេន្តុ/ ធារេតុ/** (ថារួមគ្នា) **អជ្ជតគ្គេ បាណុបេ** (ប្រុសថា) **តេ** (ស្រីថា) **តា** (ថារួមគ្នា) **សរណំ** (ប្រុសថា) **គតេ** (ស្រីថា) **គតា** ។

សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យមុនថា "ខ្ញុំព្រះករុណា" នោះ ក្នុងទីនេះថា "ខ្ញុំព្រះករុណាទាំងឡាយ" ដូច្នេះវិញ, ក្រៅអំពីនេះ នៅដូចគ្នាទាំងអស់ ។

បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ ហើយសូធ្យប្តេជ្ញាខ្លួន ចំពោះព្រះពុទ្ធរូប ឬព្រះស្តូប ព្រះចេតិយ ដែលបញ្ចុះព្រះសារី-រិកធាតុព្រះដ៏មានបុណ្យនោះ ត្រូវពោលប្តេជ្ញាដោយពាក្យថាៈ

**ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច** (ប្រុសថា) **ឧបាសកំ** (ស្រីថា) **ឧបាសិកំ** (ថារួមគ្នា) **មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

ប្រែថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុ-សង្ឃផង ជាទីពឹង ទីរឭក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជាឧបាសក ឧបាសិកា បានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹង ទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះ ជាដើមរៀងទៅ ។

បើគ្នាច្រើន ក៏ត្រូវសូធ្យជូចន័យមុន ហើយនឹងសូធ្យប្ដេជ្ញាខ្លួនព្រមគ្នា ដោយពាក្យជាឯកវចនៈក៏បាន ព្រោះសូធ្យព្រមទាំងអស់គ្នា ។

បុរស ឬស្ត្រី កាលបើបានពោលពាក្យប្ដេជ្ញា ខ្លួនជាអ្នកបានដល់ព្រះត្រៃសរណគមន៍ជាទីពឹង ទីរឭកដូច្នេះរួចហើយ ក៏បាននាមបញ្ញត្តិថា **“ឧបាសក”** ឬ **“ឧបាសិកា”** ក្នុង

ខណៈនោះឯង ។

វិធីសូមខមាទោសក្តី វិធីប្តេជ្ញាខ្លួនជាឧបាសក ជាឧបាសិកាក្តី បើអ្នកដែលមិនចេះសូធ្យជាបាលី នឹងសូធ្យជាសេចក្តីប្រែជាសម្រាយតាមភាសារបស់ខ្លួននោះក៏បាន បើចេះសូធ្យទាំងបាលីទាំងសេចក្តីប្រែជាសម្រាយផង ដូចបានពោលមកហើយនោះជាការប្រពៃពិត តែកុំសូធ្យតែបាលីទទេ ដោយមិនដឹងថាជាអ្វីនោះឡើយ ព្រោះកិច្ចដែលសូធ្យខមាទោស និងប្តេជ្ញាខ្លួននេះចំពោះយកសទ្ធា គឺសេចក្តីជឿជាក់ និងបញ្ញា ជាសម្មាទិដ្ឋិ ដែលដឹងពិត យល់ត្រូវពិត ជាប្រមាណប៉ុណ្ណោះ ។

# វិធីសុំសីល

## វិធីសុំនិច្ចសីលជាបច្ចេកសមាទាន

## បើម្នាក់ឯងសូត្រថា

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិ-សរណេន សហ បញ្ច សីលានិ យាចាមិ ។

ទុតិយម្បិ អហំ ភន្តេ... យាចាមិ ។

តតិយម្បិ អហំ ភន្តេ... យាចាមិ ។

**ប្រែថា** សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់ពីរដងផង

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់បីដងផង ។

## វិធីសុំបញ្ចសីលទៀត

**ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិ-សរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។**

**ទុតិយម្បិ អហំ ភន្តេ... មេ ភន្តេ ។**

**តតិយម្បិ អហំ ភន្តេ... មេ ភន្តេ ។**

**ប្រែថា** សូមគោរព ខ្ញុំព្រះករុណា សូមនូវនិច្ចសីល ដែល ប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីល ដល់ខ្ញុំព្រះករុណា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់ ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់បីដងផង ។

## បើ ២ ពីរនាក់ឡើងទៅសូត្រថា

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។

ទុតិយម្បិ មយំ ភន្តេ... យាចាម ។

តតិយម្បិ មយំ ភន្តេ... យាចាម ។

ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់ ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់បីដងផង

## វិធីសុំម្យ៉ាងទៀត

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

ទុតិយម្បិ មយំ ភន្តេ... នោ ភន្តេ ។

តតិយម្បិ មយំ ភន្តេ... នោ ភន្តេ ។

ប្រែថា សូមគោរព ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីល ដែលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ

ក្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ... ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ... ជាគម្រប់បីដងផង ។

រួចចាំថាតាមលោក រហូតដល់ចប់ព្រះត្រៃសរណគមន៍ ទើបលោកពោលថា **តិសរណគមនំ បរិបុណ្ណំ** ឬថា **តិសរណគមនំ និដ្ឋិតំ** = ការកាន់យកនូវព្រះត្រៃសរណគមន៍ចប់ហើយ, យើងត្រូវទទួលថា **អាម ភន្តេ** = ករុណាលោកម្ចាស់ ។ បើលោកថាតែបាលី យើងត្រូវទទួលត្រឹមតែបាលីថា **អាម ភន្តេ** បានហើយ ។ បន្ទាប់មកចាំថាតាមលោក ក្នុងសិក្ខាបទនីមួយៗ ជាបន្តទៀត ។ លុះដល់ចប់សិក្ខាបទទាំង ៥ លោកក៏ពោលដាស់តឿនយើងថា៖

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ** = អ្នក ឬអ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះ ឱ្យប្រពៃ ត្រូវរក្សាឱ្យល្អ អស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែស ឡើយ ។ យើងត្រូវទទួលថា **អាម ភន្តេ** = ករុណាលោកម្ចាស់ ។ បើលោកថាតែបាលី យើងត្រូវថា **អាម ភន្តេ** ។ បន្ទាប់មក លោកសំដែងអំពីអានិសង្សនៃសីលថា៖

“ **សីលេន សុគតឹ យន្តិ, សីលេន ភោគសម្បទា, សីលេន និព្វុតឹ យន្តិ, តស្មា សីលំ វិសោធយេ** = សត្វទាំងឡាយបានទៅកាន់ឋានសួគ៌ ដោយសារមានសីល, សត្វទាំងឡាយបានបរិបូរដោយភោគសម្បត្តិ ដោយសារមានសីល, សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខ ពោលគឺព្រះនិព្វាន ដោយសារមានសីល, ព្រោះហេតុនោះ សូមបុគ្គលជម្រះនូវសីល ឱ្យបានបរិសុទ្ធ កុំឱ្យសៅ

ហ្មងឡើយ ” ជាដើម ។ យើងត្រូវបញ្ចេញវាចាថា **សាធុ សាធុ សាធុ** ។

បើឧបាសក ឧបាសិកា ចង់សមាទាននិច្ចសីល ជាឯកជ្ឈសមាទាន ព្រមទាំងព្រះត្រៃសរណគមន៍នោះ ត្រូវសុំដូច្នេះ ៖

## វិធីសុំនិច្ចសីលជាឯកជ្ឈសមាទាន

## បើម្នាក់ឯងសូត្រថា

**ឱកាស អហំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។**

**ទុតិយម្បិ អហំ ភន្តេ... ទេថ មេ ភន្តេ ។**

**តតិយម្បិ មយំ ភន្តេ... ទេថ មេ ភន្តេ ។**

ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិច្ចសីល ដែលប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់ពីរ ដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់ បីដងផង ។

## បើ ២ នាក់ឡើងទៅសូត្រថា

**ឱកាស មយំ ភន្តេ តិសរណេន សហ ឯកជ្ឈំ**

## កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

## ទុតិយម្បិ មយំ ភន្តេ... ទេថ នោ ភន្តេ ។

## តតិយម្បិ មយំ ភន្តេ... ទេថ នោ ភន្តេ ។

**ប្រែថា** សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីល ដែលប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តងមួយអន្លើដោយព្រះ ត្រៃសរណគមន៏, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំង ឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ... ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ...
ជាគម្រប់បីដងផង ។

បន្ទាប់មកលោកអ្នកឱ្យសីល តាំង **នមោ** ៣ ចប់ រួច ឱ្យព្រះត្រៃសរណ-គមន៏ចប់ស្រេចហើយ ទើបឱ្យនិច្ចសីល ជាឯកជ្ឈសមាទានថា **បញ្ចង្គសមន្នាគតំ និច្ចសីលំ សមាទិយាមិ** = ខ្ញុំព្រះករុណា សូមសមាទាននូវនិច្ចសីលប្រកបព្រមដោយអង្គ ៥, ឬថា **បញ្ច សីលានិ សមាទិយាមិ** = ខ្ញុំព្រះករុណា សូមសមាទាននូវសីលទាំងឡាយ ៥ ដូច្នេះ ក៏បាន ។ អ្នកសមាទានត្រូវទទួលថាតាមលោក ៣ ដង, រួចលោកពោលដាស់តឿនក្រើនរំឭកថា ៖

**ឥមំ បញ្ចង្គសមន្នាគតំ និច្ចសីលំ សាធុកំ កត្វា**

**អប្បមាទេន និច្ចសីលំ សម្មារក្ខិតព្វំ ។**

ប្រែថា អ្នក ឬអ្នកទាំងឡាយ គប្បីធ្វើនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ នេះ ឱ្យប្រពៃ គឺត្រូវរក្សាឱ្យល្អ អស់កាលជានិច្ចដោយសេចក្ដីមិនប្រមាទ គឺថា កុំបីធ្វេសប្រហែសឡើយ ។ អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** = ករុណាលោកម្ចាស់ ។ ទើបលោកសំដែងអានិសង្សសីល ឱ្យស្ដាប់តទៅទៀត ដូចក្នុងវិធីបច្ចេកសមាទានខាងដើម ។

សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច មិនបាច់សូធ្យញែក ឈ្មោះសិក្ខាបទទាំង ៥ រាយមួយម្ដងៗ ដូចបច្ចេកសមាទាននោះឡើយ, សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំង វិរតិចេតនា វៀរចាកឱ្យគ្រប់សិក្ខាបទក្នុងនិច្ចសីល ដែលខ្លួនបានសមាទានហើយនោះ

## **វិធីសុំឧបោសថសីល** ( សីល ៨ )

ឧបាសក ឧបាសិកា អ្នករក្សាឧបោសថសីល កាលបើជិតដល់ថ្ងៃឧបោសថ-សីលមុនមួយថ្ងៃដែលកំណត់ថា ព្រឹកឡើង នឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែង មានការចាត់ចែងនូវម្ហូបអាហារជាដើម ដែលជាការងារ គឺខ្លួននឹងត្រូវធ្វើ ឬនឹងត្រូវប្រើគេឱ្យធ្វើក្នុងថ្ងៃស្អែក ឱ្យហើយជាស្រេច តែកុំចាត់ចែងការងារណាដែលមិនប្រកបដោយធម៌ ។ លុះដល់ព្រឹកឡើងជាថ្ងៃសីល ត្រូវរក្សាឧបោសថសីល គប្បីភ្ញាក់ពីព្រលឹម ហើយខ្ពុលមាត់ជម្រះធ្មេញ ឱ្យស្អាតរួចជាស្រេច បើបានសមាទាននូវឧបោសថសីលក្នុងវេលានោះ ក៏ជាការប្រពៃ តែបើសមាទានពីព្រលឹមនោះមិនទាន់ទេ គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីលក្នុង ១ ថ្ងៃ ១ យប់នោះ បើឧបាសកគប្បីបញ្ចេញវាចាអធិដ្ឋានថា **“អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧបោសថិកោ**

**តតិយម្បិ** = ថ្ងៃនេះ ជាថ្ងៃត្រូវរក្សានូវឧបោសថសីល អញនឹងជាអ្នករក្សានូវឧបោសថសីល អស់ថ្ងៃនេះ និងយប់នេះ ” ។ បើឧបាសិកាគប្បីបញ្ចេញវាចាអធិដ្ឋានថា “ **អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧបោសថិកា តតិយម្បិ** = ថ្ងៃនេះ ជាថ្ងៃត្រូវរក្សានូវឧបោសថសីល អញនឹងជាអ្នករក្សានូវឧបោសថសីល អស់ថ្ងៃនេះ និងយប់នេះ” ។ បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួន (សម្រាយ) ក៏បាន ។ លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនា វៀរចាកសីលភេទ គឺហេតុដែលជាទីទម្លាយនូវសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨ ។ កាលបើបានអធិដ្ឋានដូច្នេះហើយ តពីពេលនោះមក គប្បីសមាទាននូវឧបោសថសីល អំពីបុគ្គលណាមួយកុំខាន ដូចលោកពោលទុកក្នុងគម្ពីរ **មង្គលត្ថទីបនី** ភាគ ៣ ថា ៖

## ឧបោសថទិវសេ បាតោ វ ភិក្ខុស្ស វា ភិក្ខុនិយា វា ទសសីលលក្ខណញ្ញុនោ ឧបាសកស្ស វា ឧបា-សិកាយ វា សន្តិកេ វាចំ ភិន្ទិត្វា ឧបោសថង្គានិ សមាទាតព្វានិ ។

ប្រែថា ក្នុងថ្ងៃឧបោសថ អ្នកសមាទាន គប្បីបញ្ចេញ វាចាសមាទានអង្គឧបោសថ ក្នុងសំណាក់នៃភិក្ខុ ឬភិក្ខុនី ឧបាសក ឬក៏ឧបាសិកា អ្នកដឹងនូវលក្ខណៈនៃសីលទាំង ១០ តាំងអំពីព្រលឹមស្រាងៗ ។

តែកាលមិនដឹងបាលី (មិនចេះចាំបាលីក្នុងសិក្ខាបទ មានបាណាតិបាតាជាដើម) អ្នកសមាទានឧបោសថ គប្បីអធិដ្ឋានថា **ពុទ្ធប្បញ្ញត្តំ ឧបោសថំ**

**អធិដ្ឋាមិ** = អាត្មាអញអធិដ្ឋាននូវឧបោសថសីល ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់បញ្ញត្តទុកហើយ ។ កាលរកនូវបុគ្គលដទៃមិនបាន គប្បីអធិដ្ឋាន ដោយខ្លួនឯង ក៏បាន តែកុំភ្លេចត្រូវបញ្ចេញវាចាផង ។

បើតាមសេចក្ដីដែលលោកពោលទុកនៅក្នុង **មង្គលត្ថទីបនី** និងក្នុងគម្ពីរដទៃទៀត មានអដ្ឋកថា **មនោរថបូរណី** ត្រង់ឧបោសថសូត្រជាដើមថា បើមិនមានអ្នកចាំបាលីនៃសិក្ខាបទ (មានបាណាតិបាតាជាដើម) ទេ គ្រាន់តែអធិដ្ឋានថា **ពុទ្ធប្បញ្ញត្តំ ឧបោសថំ អធិដ្ឋាមិ** = អាត្មាអញអធិដ្ឋាន នូវឧបោសថសីល ដែលព្រះសម្ពុទ្ធទ្រង់បញ្ញត្តទុកហើយ; គ្រាន់តែបញ្ចេញវាចា ពោលពាក្យប៉ុណ្ណេះ ក៏ឈ្មោះថា បានរក្សាឧបោសថសីលហើយដែរ ។

កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីលប្រកបដោយអង្គ ៨ អំពីបុគ្គលដទៃ ពោលគឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំ រំឭកគុណព្រះរតនត្រ័យដោយសង្ខេបជាមុនសិន រួចហើយទើបសុំនូវឧបោសថសីល ព្រមទាំងព្រះត្រៃសរណគមន៍ នឹងភិក្ខុ ឬសាមណេរ ដូចតទៅ ៖

## វិធីសុំឧបោសថសីល ជាបច្ចេកសមាទាន
## បើម្នាក់ឯងសូត្រថា

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាមិ ។

ទុតិយម្បិ អហំ ភន្តេ... យាចាមិ ។

តតិយម្បិ អហំ ភន្តេ... យាចាមិ ។

ប្រែដូចក្នុងវិធីសុំនិច្ចសីលដែរ ប្លែកតែត្រង់ពាក្យថា **អដ្ឋ សីលានិ** = នូវសីលទាំងឡាយ ៨

## បើ ២ នាក់ឡើងទៅសូត្រថា

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិ-សរណេន សហ អដ្ឋ សីលានិ យាចាម ។

ទុតិយម្បិ អហំ ភន្តេ... យាចាម ។

តតិយម្បិ អហំ ភន្តេ... យាចាម ។

ប្រែដូចក្នុងវិធីសុំនិច្ចសីលដែរ ប្លែកតែត្រង់ពាក្យថា **អដ្ឋ សីលានិ** = នូវសីលទាំងឡាយ ៨

## វិធីសុំឧបោសថសីល ជាបច្ចេកសមាទាន

## ម្យ៉ាងទៀត បើម្នាក់ឯងសូត្រថា

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិ-សរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

ទុតិយម្បិ អហំ ភន្តេ... ទេថ មេ ភន្តេ ។

តតិយម្បិ អហំ ភន្តេ... ទេថ មេ ភន្តេ ។

**ប្រែថា** សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវឧបោ-សថសីល ដែលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តា ធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់ ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់បី ដងផង ។

## បើ ២ នាក់ឡើងទៅសូត្រថា

**ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**

**ទុតិយម្បិ មយំ ភន្តេ... ទេថ នោ ភន្តេ ។**

**តតិយម្បិ មយំ ភន្តេ... ទេថ នោ ភន្តេ ។**

**ប្រែថា** សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ដែលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ... ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ... ជាគម្រប់បីដងផង ។

បើឧបាសក ឧបាសិកា នឹងសមាទានឧបោសថសីល ជាឯកជ្ឈសមាទាន ព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសុំដូចតទៅ ៖

## វិធីសុំឧបោសថសីលជាឯកជ្ឈសមាទាន

## បើម្នាក់ឯងសូត្រថា

**ឱកាស អហំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។**

**ទុតិយម្បិ អហំ ភន្តេ... ទេថ មេ ភន្តេ ។**

**តតិយម្បិ អហំ ភន្តេ... ទេថ មេ ភន្តេ ។**

**ប្រែថា** សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវឧបោសថ-សីល ដែលប្រកបព្រមដោយអង្គ ៨ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍,បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់ ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា... ជាគម្រប់បី ដងផង

## បើ ២ នាក់ឡើងទៅសូត្រថា

**ឱកាស មយំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**

**ទុតិយម្បិ មយំ ភន្តេ... ទេថ នោ ភន្តេ ។**

**តតិយម្បិ មយំ ភន្តេ... ទេថ នោ ភន្តេ ។**

**ប្រែថា** សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ

សូមនូវឧបោសថសីល ដែលប្រកបព្រមដោយអង្គ ៨ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទាន រួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍,បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តា ធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ... ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ... ជាគម្រប់បីដងផង ។

បន្ទាប់មក លោកតាំង **នមោ** ៣ ចប់ រួចឱ្យនូវព្រះត្រៃសរណគមន៍ ចប់ដូចបានពន្យល់ ហើយឱ្យឧបោសថសីល ជាឯកជ្ឈសមាទានថា ៖

**អដ្ឋង្គសមន្នាគតំ ឧបោសថំ សមាទិយាមិ** = ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ប្រកបដោយអង្គ ៨, ឬថា **អដ្ឋ សីលានិ សមាទិយាមិ** = ខ្ញុំព្រះករុណា សូមសមាទាននូវសីលទាំងឡាយ ៨ ។ អ្នកសមាទានត្រូវទទួលថា តាម ៣ ដង, រួចត្រូវសូធ្យកំណត់កាលឧបោសថថា ៖

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ** = ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឱ្យជាក់ច្បាស់ នូវព្រះនិព្វានព្វដ៏អនាគតទៅឯមុខនោះហោង។ ទើបលោកពោលដាស់តឿនក្រើនរំឭកថា **ឥមំ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ** = អ្នក ឬអ្នកទាំងឡាយ គប្បីធ្វើនូវឧបោសថ ដ៏ប្រកបព្រមដោយអង្គ ៨ នេះ ឱ្យប្រពៃ គឺត្រូវរក្សាឱ្យល្អ អស់កាល

កំណត់ត្រឹមថ្ងៃនេះ និងយប់នេះ ដោយសេចក្តីមិនប្រមាទ គឺថា កុំគប្បីធ្វេស ប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** ( ប្រែដូចមុន ) ទើបលោកសំដែង អំពីអានិសង្សនៃសីលតទៅទៀត ( មានន័យដូចមុន ) ។

សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច មិនបាច់ចាំសូធ្យ ញែកឈ្មោះសិក្ខាបទទាំង ៨ រាយមួយម្តងៗ ដូចបច្ចេកសមាទាន នោះឡើយ, សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំង វិរតិចេតនា វៀរចាកឱ្យគ្រប់សិក្ខាបទក្នុងឧបោសថសីល ដែលខ្លួនបានសមាទានហើយនោះ អស់រយៈ ១ ថ្ងៃ ១ យប់

## អ្នកសមាទានសូត្រកំណត់ឧបោសថកាលថា:

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃអស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូលជាឧបនិស្ស័យធ្វើឱ្យជាក់ច្បាស់ នូវព្រះនិព្វានព្ធដ៏អនាគតកាល ទៅឯមុខនោះហោង ។

( បន្ទាប់មកចាំស្តាប់លោកសំដែងអំពីអានិសង្សនៃសីល)

# អង្គនៃសីល ៥ ឬនិច្ចសីល

## បាណាតិបាតៈ មានអង្គ ៥ គឺៈ

១.បាណោ សត្វមានជីវិត

២.បាណសញ្ញិតា សេចក្ដីដឹងថាសត្វមានជីវិត

៣.វធកចិត្តំ គិតនឹងសម្លាប់

៤.ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥.តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

## អទិន្នាទាន មានអង្គ ៥

១.បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់របស់គេ ហួងហែងរក្សា ។

២.បរបរិគ្គហិតសញ្ញិតា សេចក្ដីដឹងថា ទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា ។

៣.ថេយ្យចិត្តំ គិតនឹងលួច

៤.ឧបក្កមោ ព្យាយាមនឹងលួច

៥.តេន ហរណំ លួចបានមកដោយព្យាយាមនោះ ។

## កាមេសុមិច្ឆាចារៈ មានអង្គ ៤

១.អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ។

២.តស្មឹ សេវនចិត្តំ គិតនឹងសេពនូវមេថុនធម្ម នឹងស្ត្រីនោះ ។

៣.ឧបក្កមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤.មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា។

## មុសាវាទ មានអង្គ ៤

១.អតថំ វត្ថុ វត្ថុមិនពិត

២.វិសំវាទនចិត្តំ គិតនឹងពោលឱ្យខុស

៣.តជ្ជោ វាយាមោ ព្យាយាមនឹងពោលឱ្យខុស

៤.បរស្ស តទត្ថវិជាននំ ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ។

## សុរាមេរយៈ មានអង្គ ៤

**១.មជ្ជនីយវត្ថុ** វត្ថុជាទីតាំង នៃសេចក្ដីស្រវឹង គឺសុរា និងមេរ័យ ។

**២.បាតុកម្យតាចិត្តំ** គិតបំរុងនឹងផឹក

**៣.តជ្ជោ វាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

**៤.តស្ស បានំ** បានផឹកនូវទឹកស្រវឹងនោះ ឱ្យកន្លងបំពង់កចូលទៅ ។

## អង្គនៃសីល ៨ ឬ ឧបោសថសីល

អង្គនៃបាណាតិបាត និងអទិន្នាទាន ដូចនិច្ចសីលដែរ ។

## អព្រហ្មចរិយៈ មានអង្គ ៤

**១.ភេទនវត្ថុ** វត្ថុជាទីទម្លាយនូវសីល គឺទ្វារទាំង ៣០ ចំពោះត្រង់ទ្វារណាមួយ ។

**២.សេវនចិត្តំ** គិតនឹងសេព

**៣.តជ្ជោ វាយាមោ** ព្យាយាមនឹងសេពនូវមេថុននោះ

**៤.មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គ និងមគ្គឱ្យដល់គ្នា។

អង្គនៃមុសាវាទ និងសុរាមេរយ ដូចនិច្ចសីលដែរ ។

**វិកាលភោជនៈ មានអង្គ ៣**

**១.វិកាលោ** កាលខុស គឺព្រះអាទិត្យជ្រេទៅហើយ ដរាបទល់នឹងអរុណរះ ។

**២.យាវកាលិកំ** របស់ដែលគួរបរិភោគបាន ក្នុងកាល គឺតាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់ ។

**៣.អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

**នច្ចគីតៈ និងមាលា រួមគ្នាជាសិក្ខាបទ១ មានអង្គ៦ គឺៈ**

**១.នច្ចគីតាទិ** ការល្បែងមានរាំនិងច្រៀងជាដើម

**២.កត្តុកម្យតាចិត្តំ** គិតបំរុងនឹងធ្វើ

**៣.សុតទស្សនត្ថាយ គមនំ** ទៅដើម្បីនឹងស្តាប់ ឬមើល ហើយបានស្តាប់ ឬមើល ។

**៤.មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រង ជាដើម ។

**៥.ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង

**៦.តស្ស ធារណំ** បានប្រដាប់តាក់តែង នូវវត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

## ឧច្ចាសយនៈ មានអង្គ ៣

**១.ឧច្ចាសយនមហាសយនំ** ទីដេក ទីអង្គុយ ដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ ។

**២.បរិភោគចិត្តំ** គិតនឹងដេក ឬអង្គុយ

**៣.បរិភោគករណំ** បានដេក ឬអង្គុយ ។

កាលបើឧបាសក ឧបាសិកា ប្រព្រឹត្តកន្លងនូវសិក្ខាបទណាៗ លុះតែព្រមដោយអង្គ ក្នុងសិក្ខាបទនោះៗ ទើបបានឈ្មោះថា **កន្លង**, បើមិនទាន់ប្រកបដោយអង្គនោះទេ ក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះៗ ឡើយ

អង្គនៃនិច្ចសីល និងឧបោសថសីល ចប់តែប៉ុណ្ណេះ ។

## វិនិច្ឆ័យបន្ថែមដោយសង្ខេប

ដើម្បីភាពជាអ្នកឈ្លាសក្នុងសីល ៥ ឬសីល ៨ នេះ គប្បីជ្រាបថា:

បណ្តាសិក្ខាបទទាំង ៨ នោះ សិក្ខាបទខ្លះ កើតព្រោះធ្វើ

សិក្ខាបទខ្លះ កើតព្រោះមិនធ្វើ សិក្ខាបទខ្លះ កើតព្រោះធ្វើ និង មិនធ្វើ សិក្ខាបទខ្លះ គ្រាខ្លះកើតព្រោះធ្វើ គ្រាខ្លះកើតព្រោះមិន ធ្វើ សិក្ខាបទខ្លះ គ្រាខ្លះកើតព្រោះធ្វើ និងមិនធ្វើ ។ បណ្តាសិក្ខា-បទទាំងនេះ សិក្ខាបទដែលជាសញ្ញាវិមោក្ខ (រួចខ្លួនដោយការ សម្គាល់) ក៏មាន ជានោសញ្ញាវិមោក្ខ (មិនរួចខ្លួនដោយការ សម្គាល់) ក៏មាន ។ សិក្ខាបទណា មានអង្គ គឺចិត្តផង សិក្ខាបទ នោះ ជាសញ្ញាវិមោក្ខ ក្រៅពីនេះ ជានោសញ្ញាវិមោក្ខ ។ សិក្ខា បទដែលជាអចិត្តកៈក៏មាន ជាសចិត្តកៈក៏មាន ។ សិក្ខាបទណា មានចិត្តក្លែងទើបត្រូវ សិក្ខាបទនោះ ជាសចិត្តកៈ ។ សិក្ខាបទ ណា មិនមានចិត្តក្លែងក៏ត្រូវ សិក្ខាបទនោះ ជាអចិត្តកៈ ។ សិក្ខា-បទដែលជាលោកវជ្ជៈ (មានទោសតាមផ្លូវលោក) ក៏មាន បណ្ណត្តិវជ្ជៈ (មានទោសតាមផ្លូវបញ្ញត្តិ) ក៏មាន ។ សិក្ខាបទណា ប្រព្រឹត្តទៅតាមទ្វារកាយ សិក្ខាបទនោះ ជាកាយកម្ម សិក្ខាបទ ណា ប្រព្រឹត្តទៅតាមទ្វារវាចា សិក្ខាបទនោះ ជាវចីកម្ម ។ ប្រការមួយទៀត សិក្ខាបទដែលជាកុសលក៏មាន ជាអកុសល ក៏មាន ។ សិក្ខាបទណា ត្រូវដោយកុសលចិត្ត សិក្ខាបទនោះ ជា កុសល សិក្ខាបទណា ត្រូវដោយអកុសលចិត្ត សិក្ខាបទនោះ ជា អកុសល ។

សរុបមកវិញ ចំពោះសីល ៥ ឬ សីល ៨ នេះ ។ សិក្ខាបទ ៥ គឺ បាណា... អទិន្នាទាន... កាមេ... ឬអព្រហ្ម... មុសា... និងសុរា... ជាសចិត្តកៈ លោកវជ្ជៈ សញ្ញាវិមោក្ខ កិរិយា (ត្រូវទោសព្រោះធ្វើសកម្មភាព) ជាកាយកម្ម និងវចីកម្ម (ប្លែកតែ កាមេ... ឬអព្រហ្ម... គឺជាកាយកម្ម) ។ ឯសិក្ខាបទ ៣ ខាងចុង ដែលជាសិក្ខាបទបំពេញគម្រប់ដល់សីល ៨ គឺ វិកាល... ជាអ-ចិត្តកៈ បណ្ណត្តិវជ្ជៈ នោសញ្ញាវិមោក្ខ អកិរិយា និងជាកាយកម្ម ។ នច្ចគីត... ជាសចិត្តកៈ បណ្ណត្តិវជ្ជៈ សញ្ញាវិមោក្ខ កិរិយា កាយ-កម្ម និងជាវចីកម្ម ។ មាលា... ជាសចិត្តកៈ បណ្ណត្តិវជ្ជៈ សញ្ញាវិមោក្ខ កាយកម្ម និងជាកិរិយា ។ ឧច្ចា... ជាសចិត្តកៈ បណ្ណត្តិវជ្ជៈ សញ្ញាវិមោក្ខ កាយកម្ម កិរិយា និងជាកាយកម្ម

## អកុសលកម្មបថ ១០ យ៉ាង

គន្លង ឬផ្លូវនៃអំពើជាអកុសល ហៅថា អកុសលកម្មបថ មាន ១០ យ៉ាងគឺ **កាយកម្ម** អំពើដែលសម្រេចដោយ **កាយ** មាន ៣ យ៉ាង, **វចីកម្ម** អំពើដែលសម្រេចដោយ **វាចា** មាន ៤

យ៉ាង, **មនោកម្ម** អំពើដែលសម្រេច ដោយចិត្តមាន ៣ យ៉ាង រួមត្រូវជា ១០ យ៉ាង ។

## កាយកម្ម ៣ យ៉ាង

**១_បាណាតិបាតោ** កិរិយាសម្លាប់សត្វ ដោយកាយរបស់ខ្លួន ឬប្រើគេឱ្យសម្លាប់ដោយវាចា ។

**២_អទិន្នាទានំ** កិរិយាលួចលាក់ឆក់ដណ្តើមទ្រព្យគេ ដោយកាយរបស់ខ្លួន ឬប្រើគេឱ្យលួចលាក់ឆក់ ដណ្តើមដោយវាចា ។

**៣_កាមេសុ មិច្ឆាចារោ** កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈ នឹងស្ត្រីដែលមានគេហួង-ហែងរក្សា ។

## វចីកម្ម ៤ យ៉ាង

**១_មុសាវាទោ** កិរិយាពោលនូវពាក្យកុហក ។

**២_បិសុណាវាចា** កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ។

**៣_ផរុសវាចា** កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

**៤_សម្ផប្បលាបោ** កិរិយាពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

**១_អភិជ្ឈា** ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានជាទ្រព្យរបស់ខ្លួន ។

**២_ព្យាបាទោ** ចិត្តចងគំនុំគុំគួនគិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស ។

**៣_មិច្ឆាទិដ្ឋិ** គំនិតយល់ខុសហើយប្រកាន់ឡើងថាជាត្រូវ។

## កុសលកម្មបថ ១០ យ៉ាង

គន្លង ឬផ្លូវនៃអំពើជាកុសលហៅថា កុសលកម្មបទ មាន ១០ យ៉ាងគឺ **កាយកម្ម** អំពើដែលសម្រេចដោយ **កាយ** មាន៣យ៉ាង, **វចីកម្ម** អំពើដែលសម្រេចដោយ **វាចា** មាន ៤ យ៉ាង, **មនោកម្ម** អំពើដែលសម្រេចដោយចិត្តមាន ៣ យ៉ាង រួមត្រូវជា ១០ យ៉ាង ។

# កាយកម្ម ៣ យ៉ាង

**១-បាណាតិបាតា វេរមណី** កិរិយាវៀរចាកការសម្លាប់សត្វដោយកាយរបស់ខ្លួន ឬប្រើគេឱ្យសម្លាប់ដោយវាចា។

**២-អទិន្នាទានា វេរមណី** កិរិយាវៀរចាកការលួចលាក់ឆក់ដណ្តើមទ្រព្យគេ ដោយកាយរបស់ខ្លួន ឬប្រើគេឱ្យលួចលាក់ឆក់ដណ្តើមដោយវាចា ។

**៣-កាមេសុ មិច្ឆាចារា វេរមណី** កិរិយាវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈ នឹងស្ត្រីដែលមានគេហួងហែងរក្សា ។

# វចីកម្ម ៤ យ៉ាង

**១-មុសាវាទា វេរមណី** កិរិយាវៀរចាកការពោលនូវពាក្យកុហក ។

**២-បិសុណាវាចា វេរមណី** កិរិយាវៀរចាកការពោលនូវពាក្យញុះញង់ បំបែកបំបាក់អ្នកដទៃ ។

**៣-ផរុសវាចា វេរមណី** កិរិយាវៀរចាក ការពោល

នូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

**៤-សម្ផប្បលាបា វេរមណី** កិរិយាវៀរចាកការពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

**១-អនភិជ្ឈា** ចិត្តមិនសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានជាទ្រព្យរបស់ខ្លួន ។

**២-អព្យាបាទោ** ចិត្តមិនចងគំនុំគុំគួនគិតប៉ង នឹងឱ្យអ្នកដទៃដល់នូវសេចក្ដីវិនាស ។

**៣-សម្មាទិដ្ឋិ** គំនិតយល់ឃើញត្រូវ

## អង្គនៃអកុសលកម្មបថ

អង្គនៃបាណាតិបាត, អទិន្នាទាន, កាមេសុមិច្ឆាចារ និងមុសាវាទ ដូចបានមកក្នុងនិច្ចសីលខាងដើមរួចហើយ ។

## បិសុណាវាចា មានអង្គ ៤

**១.ភិន្ទិតព្វោ បរោ** អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក ។

**២.ភេទនបុរេក្ខារតោ** គិតនឹងញុះញង់បំបែកអ្នកដទៃ

**៣.តជ្ជោ វាយាមោ** ព្យាយាមនឹងញុះញង់ បំបែកអ្នកដទៃនោះ ។

**៤.តស្ស តទត្ថវិជាននំ** ញុាំងអ្នកនោះឱ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកនោះ ។

## ផរុសវាចា មានអង្គ ៣

**១.អក្កោសិតព្វោ បរោ** អ្នកដទៃដែលមានរូប គឺខ្លួនគប្បីជេរប្រទេច ។

**២.កុប្បិតចិត្តំ** ចិត្តខឹងរន្ធត់

**៣.អក្កោសនា** បានជេរប្រទេចគេ ។

## សម្ផប្បលាបៈ មានអង្គ ២

**១.ភារតយុទ្ធសិតាហរណាទិនិរត្ថកថា** ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃមហាភារតៈ និងរឿងរាពណ៍លួចនាំនាងសេតាយកទៅជាដើម ។

**២.តថារូបីកថាកថនំ** បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នោះ ។

## អភិជ្ឈា មានអង្គ ២

**១.បរភណ្ឌំ** ទ្រព្យជារបស់អ្នកដទៃ

**២.អត្តនោ បរិណាមនំ** គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឱ្យបានមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេងៗ ។

## ព្យាបាទ មានអង្គ ២

**១.បរសត្តោ** អ្នកដទៃក្រៅពីខ្លួន

**២.តស្ស តំ តំ វិនាសចិន្តា** គិតគុំគួនប្រុងនឹងឱ្យអ្នកនោះដល់នូវសេចក្តីវិនាស ដោយហេតុនោះៗ ។

## មិច្ឆាទិដ្ឋិ មានអង្គ ២

**១.វត្ថុនោ ច គហិតាការវិបរិត្តតា** ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម ។

## ២.យថា ច នំ គណ្ហាតិ តថាភាវេន តស្ស-បដ្ឋានំ គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះថាជាត្រូវវិញ

## ពាក្យថា ឧបោសថ

មុននឹងសំដែងរៀបរាប់អំពីកាលនៃឧបោសថ សូមអ្នកសិក្សាយល់អំពីពាក្យថា ឧបោសថ ជាមុនសិន ៖

នៅក្នុងគម្ពីរ **អភិធានប្បទីបកា** និង **អភិធានប្បទីបិកាសូចិ** សំដែងថា ៖

ពាក្យថា **ឧបោសថ** ( តិថិវិសេស ) តែងចូលទៅដុត នូវធម៌ជាសត្រូវ គឺ អកុសលធម៌, វិគ្គហៈថា **ឧបគន្ត្វា អរយោ ឧបាសតីតិ** = **ឧបោសថោ** (**តិថិវិសេសោ**) ។ ម្យ៉ាងទៀត ពាក្យថា **ឧបោសថ** < **ឧប** + **វស** + **អថ** (**វសនិវាសេ**) ប្រែថា ( តិថិវិសេស ) ជាទីចូលទៅនៅអាស្រ័យ ឬជាទី រក្សា, វិគ្គហៈថា **ឧបវសន្តិ ឯត្ថាតិ** = **ឧបោសថោ** (**តិថិវិសេសោ**)

### ឧបោសថ មានអង្គ ៣ គឺ :

**១. កាល** បានដល់ កាល គឺថ្ងៃដែលត្រូវរក្សា

**២. ចេតនា** បានដល់ ការវៀរចាកគ្រប់សិក្ខាបទ

**៣. វិធីភេទ** បានដល់ ការបញ្ចេញវាចាឱ្យឮច្បាស់ៗ ។

enAkgKmrmg1tTbnPaK 3 Ecgfa <

**តត្ថ បកតិប្បដិជាគរវសេន ឧទ្វិធំ ហោតិ ឧបោសថកម្មំ** = បណ្ដាកម្មទាំងឡាយនោះ ឧបោសថកម្មមាន ២ យ៉ាង គឺដោយអំណាចបកតិឧបោសថ ១ និងដោយអំណាចបដិជាគរឧបោសថ ១ ។ ចំណែកកាលដែល នឹងរក្សាបកតិឧបោសថនោះ ឧបាសក ឧបាសិកា អ្នករក្សាត្រូវដឹងថា តើថ្ងៃណា ជាថ្ងៃរក្សាឧបោសថ ? កាលបើដឹងកាលដែលត្រូវរក្សា

ហើយ គប្បីរក្សាតាមកាលនោះចុះ ។

នៅក្នុងគម្ពីរមង្គលត្ថទីបនី ភាគ ៣ និងគម្ពីរបរមត្ថ- ជោតិកា អដ្ឋកថាខុទ្ទកនិកាយ សុត្តនិបាត ត្រង់ធម្មិកសូត្រថា **ឥធន្ធេត្ត សន្និដ្ឋានំ បញ្ចមី អដ្ឋមី ចាតុទ្ទសី បណ្ណរសីតិ ជុណ្ហបក្ខេ ចត្តារោ តថា កាឡបក្ខេតិ មាសស្ស អដ្ឋទិវសា បកតិឧបោសថស្ស កាលោ** = ក្នុងកាលនៃបកតិ-ឧបោសថនេះ មានកំណត់ដូច្នេះ ៖

កាលនៃបកតិឧបោសថ ក្នុង ១ ខែ មាន ៨ ថ្ងៃ គឺ ៤ ថ្ងៃ ក្នុងជុណ្ហបក្ខ (ខាងខ្នើត) ពោលគឺថ្ងៃ ៥ កើត, ៨ កើត, ១៤ កើត និងថ្ងៃ ១៥ កើត; ក្នុងកាឡបក្ខ ( ខាងរនោច ) ក៏មាន ៤ ថ្ងៃដូចគ្នា ( គឺថ្ងៃ ៥ រោច, ៨ រោច, ១៤ រោច និងថ្ងៃ ១៥ រោច )[៤] ។

តែនៅក្នុងព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ( សុត្តនិបាត ) ទ្រង់សំដែងថា ៖

ព្រោះហេតុនោះ អ្នកចូរមានចិត្តជ្រះថ្លា រក្សាឧបោសថ ដែលប្រកបដោយអង្គប្រាំបី ឱ្យមានសភាពពេញលេញល្អអស់ថ្ងៃ ទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិកបក្ខផង ។

[៤] បើខែខ្វះ ត្រង់ថ្ងៃ ១៤ រោច ថយមក ១៣ រោច, ១៥ រោច ថយមកថ្ងៃ ១៤ វិញ ។

តាមព្រះពុទ្ធដីកានេះ ឃើញថា កាលនៃបកតិឧបោសថ ខាងខ្នើត គឺ ថ្ងៃ ១៤ កើត, ១៥ កើត និងថ្ងៃ ៨ កើត; ខាង រនោច គឺថ្ងៃ ១៤ រោច, ១៥ រោច និងថ្ងៃ ៨ រោចប៉ុណ្ណោះ ។

តែសេចក្តីនេះ លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយ ឬក្នុងគម្ពីរមង្គលត្ថទីបនីថា៖

**កាមញ្ច បញ្ចមី បាលិយំ នាគតា សា បន ធម្មសង្គាហកេហិ ឋបិតត្តា គហេតព្វា វ** = ថ្ងៃទី ៥ មិនមានមកក្នុងព្រះបាលី ( ព្រះពុទ្ធដីកា ) ក៏ពិតមែនហើយ, តែថា គប្បីកាន់យកនូវថ្ងៃទី ៥ នោះកុំខាន ព្រោះជាថ្ងៃដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានតាំង ( កំណត់) ទុកហើយ ។

កាលនៃបកតិឧបោសថ ដូចបានពណ៌នាមកនេះ ឧបាសក ឧបាសិកា អ្នកប្រាថ្នាបុណ្យកុសល គប្បីថែរក្សាឧបោសថសីល តាមកាលនេះចុះ ។ ចំណែកកាលនៃបដិជាគរឧបោសថ លោក សំដែងទុកក្នុងគម្ពីរមង្គលត្ថទីបនី ភាគ ៣ ថា៖

កាលនៃ**បដិជាគរឧបោសថ** ក្នុង ១ ខែ មាន ១១ ថ្ងៃ គឺ **ខាងខ្នើត** មាន ៥ ថ្ងៃ គឺ ថ្ងៃ ៤ កើត, ៦ កើត, ៧ កើត, ៩ កើត និងថ្ងៃ ១៣ កើត, **ខាងរនោច** មាន ៦ ថ្ងៃ គឺ ថ្ងៃ ១ រោច, ៤ រោច, ៦ រោច, ៧ រោច, ៩ រោច និងថ្ងៃ ១២ រោច ឬ ១៣ រោច ។

**តទញ្ញេ អបរិបុណ្ណមាសេ ទស បរិបុណ្ណមាសេ ឯកាទស ទិវសា ឧបោសថស្ស កាលោ ន ហោតិ** = កាលនៃឧបោសថ ( បដិជាគរឧបោសថ ) ក្នុងខែមិនពេញមាន ១០ ថ្ងៃ ក្នុងខែពេញមាន ១១ ថ្ងៃ ដទៃអំពីថ្ងៃនោះ មិនមែនជាកាលនៃឧបោសថទេ ។

នៅក្នុងគម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ តិកនិបាត ត្រង់រាជសូត្រ ពន្យល់ថា ៖

ពាក្យថា rkSanv]e)asf បានសេចក្តីថា ជនទាំងឡាយរមែងអធិដ្ឋាននូវអង្គឧបោសថ ១ ខែ ៨ ដង ។ ពាក្យថា bdCaKeran សេចក្តីថា រមែងធ្វើនូវឧបោសថកម្ម ឈ្មោះ បដិជាគរៈ។ ឧបាសកឧបាសិកា កាលធ្វើនូវបដិជាគរឧបោសថនោះ រមែងធ្វើដោយអំណាចការទទួល និងការបញ្ជូននៃថ្ងៃ ឧបោសថទាំងឡាយ ៤ ក្នុងកន្លះខែមួយ ។ កាលទទួលនូវឧបោសថក្នុងថ្ងៃទី ៥ រមែងជាអ្នករក្សាឧបោសថក្នុងថ្ងៃទី ៤ កាលបញ្ជូន រមែងជាអ្នករក្សាឧបោសថក្នុងថ្ងៃទី ៦ ។ កាលទទួលនូវឧបោសថក្នុងថ្ងៃទី ៨ រមែងជាអ្នករក្សាឧបោសថក្នុង ថ្ងៃទី ៧, កាលបញ្ជូន រមែងជាអ្នករក្សាឧបោសថក្នុងថ្ងៃទី ៩ ។ កាលទទួលនូវឧបោសថក្នុងថ្ងៃទី ១៤ រមែងជាអ្នករក្សាឧបោសថក្នុងថ្ងៃទី ១៣, កាលបញ្ជូន រមែងជាអ្នករក្សាក្នុងថ្ងៃ ១ រោច ។

នៅក្នុង KmrsartmBasa ជាដីកា នៃអង្គុត្តរនិកាយ ទុតិយភាគ បញ្ជាក់ថា ៖

ពាក្យថា Gsvar³ 8 dg សេចក្តីថា រមែងអធិដ្ឋាន អស់វារៈ ៨ ដង យ៉ាងនេះ គឺ ក្នុងកន្លះខែមួយ ៤ ដង, ក្នុងកន្លះ ខែមួយទៀត ក៏ ៤ ដង ដូចគ្នា ។ ពាក្យថា rEmgGFdan មាន ន័យថា រមែងតាំងជិត្តមាំ ។ ពាក្យថា **បដិជាគរោន្តិ** ប្រែថា រមែងភ្ញាក់រឭកដោយលំដាប់ៗ ។ ពិតមែនហើយ សត្វទាំងឡាយ កាលធ្វើបុណ្យ ឈ្មោះថា **រមែងភ្ញាក់រឭក** ព្រោះភាពជាអ្នកក្រវល់ក្រវាយក្នុងកិច្ចដែលខ្លួនគប្បីធ្វើ, តែថា សត្វដទៃទៀត ឈ្មោះថា រមែងដេកលក់ ព្រោះភាពជាអ្នករួចផុតចាក ប្រយោជន៍របស់ខ្លួន និងប្រយោជន៍អ្នកដទៃ ។ ការទទួលឧបោសថក្នុងថ្ងៃទី

១៥ រោច រមែងមិនបានដូចការបញ្ជូន ឧបោសថក្នុងថ្ងៃទី ១៤ រោច ព្រោះមិនមានថ្ងៃទេ

# បាដិហារិយឧបោសថ

នៅក្នុងគម្ពីរGPFanb,Tbkasc សំដែងថា ៖

( ធម្មជាត ) នាំទៅនូវធម៌ជាសត្រូវ ឈ្មោះថា បាដិហារ្យ៍

វិគ្គហៈថា **បដិបក្ខំ ហរតីតិ > បាដិហារិយំ** ( ធម្មជាតំ ) ។

នៅក្នុងKmrsartmBasa ជាដីកានៃGgtrnkay Tតិយភាគ សំដែងថា

**និច្ចំ និពន្ធំ ឧបោសថំ សំវច្ឆរេ សំវច្ឆរេ បដិបដិ ហរិតព្វតោ បវត្តេតព្វោ បាដិហារិយបក្ខោ នាម** = ឧបោសថជានិច្ច គឺអស់កាលមិនដាច់ ឈ្មោះថា បាដិហារិយបក្ខ ព្រោះត្រូវនាំទៅតាមលំដាប់ៗ គឺគប្បីប្រព្រឹត្តទៅរាល់ៗ ឆ្នាំ ។

នៅក្នុងគម្ពីរអដ្ឋកថា **មនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ តិកនិបាត** ត្រង់រាជសូត្រសំដែងថា ៖

ឧបោសថដែលរក្សាអស់កាលមិនដាច់ គឺត្រូវរក្សាជានិច្ច រហូតអស់ប្រជុំនៃខែ ៣ ( ៣ ខែ ) ខាងក្នុងវស្សា ឈ្មោះថា បាដិហារិយបក្ខ, កាលមិនអាច ( នឹងរក្សា ) ឧបោសថ សូម្បីខាងក្នុងវស្សា ៣ ខែនោះបាន ឧបោសថដែលរក្សាអស់កាល មិនដាច់ ( ជានិច្ច ) ( នឹងរក្សា ) អស់ប្រជុំនៃខែមួយ ( ១ ខែ ) ក្នុងរវាងថ្ងៃបវរណាទាំងពីរ គឺថ្ងៃ ១៥ កើត ខែកត្តិក ( ឬ ) កាលមិនអាច ( នឹងរក្សា ) ឧបោសថជានិច្ចអស់ ១

ខែនោះ បាននឹងរក្សាកន្លះខែ ចាប់តាំងអំពីថ្ងៃបវារណាដំបូង ក៏ឈ្មោះថា បាដិ-harybkដូចគ្នាដែរ ។

តែនៅក្នុងគម្ពីរ **បរមត្ថជោតិកា អដ្ឋកថាខុទ្ទកនិកាយ សុត្តនិបាត** ត្រង់ធម្មិក-សូត្រទុតិយភាគ សំដែងថា ៖

**បាដិហារិយបក្ខញ្ចាតិ ឯត្ថ បន វស្សូបនាយិកាយ បុរិមភាគេ អាសាឡ្ហមាសោ អន្តោវស្សេ តយោ មាសា កត្តិកមាសោតិ ឥមេ បញ្ច មាសា បាដិហារិយបក្ខោតិ វុច្ចន្តិ** = ក៏ក្នុងបទថា **បាដិហារិយបក្ខញ្ច**នេះ ខែទាំងឡាយប្រាំនេះ គឺខែអាសាឍក្នុងចំណែកខាងដើម ជិតនឹង ថ្ងៃចូលវស្សា, ៣ ខែ ខាងក្នុងវស្សា និងខែកត្តិក លោកហៅថា )adharybk ។

**សព្វំ វា បន បុញ្ញកាមេន ភាវិតព្វំ ។ ឯវមេតំ បាដិ-ហារិយបក្ខញ្ច បសន្នមានសោ អដ្ឋង្គុបេតំ សុសមត្តរូបំ សុបរិបុណ្ណរូបំ ឯកម្បិ ទិវសំ អបរិច្ចជន្តោ អដ្ឋង្គុបេតំ ឧបោសថំ ឧបវស្សាតិ សម្ពន្ធិតព្វំ ។**

ចំណែកបុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីចម្រើន ( គប្បីធ្វើ ) បានគ្រប់យ៉ាង ។ សេចក្តីថា បណ្ឌិតគប្បីចងចាំទុកយ៉ាងនេះថា ក៏បុគ្គលមានជិត្តជ្រះថ្លា កាលមិនលះបង់នូវបាដិហារិយបក្ខដែលប្រកបព្រមដោយអង្គ ៨ សូម្បីមួយថ្ងៃ គឺថា រក្សារៀងរាល់ថ្ងៃ ធ្វើឱ្យសម្បូរល្អ ឱ្យបរិបូណ៌ល្អ ឈ្មោះថា ចូលទៅរក្សានូវឧបោ-សថ ដែលប្រកបព្រមដោយអង្គប្រាំបី។

# គុណនៃឧបាសក ១០ យ៉ាង

ធម៌សម្រាប់ឧបាសក ឧបាសិកាគ្រប់រូប ប្រតិបត្តិដើម្បីនឹងឱ្យកើត ឱ្យចម្រើននូវសម្បត្តិទាំងពួង ឈ្មោះថា “គុណ” ។

គុណនេះ ជារបស់ឧបាសក ឧបាសិកា ហៅថា ឧបាសក-គុណ មាន ១០ យ៉ាង គឺ:

**១.សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ** ឧបាសកអ្នករួមសេចក្ដីសុខទុក្ខ មួយអន្លើដោយភិក្ខុសង្ឃ គឺថា បើភិក្ខុសង្ឃមានសេចក្ដីសុខក៏ត្រេកអរ បើភិក្ខុសង្ឃ មានសេចក្ដីទុក្ខព្រួយ ក៏ព្រួយជាមួយផងដែរ ។

**២.កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ** ឧបាសកមានកាយកម្ម និងវចីកម្ម រក្សាហើយដោយប្រពៃ ។

**៣.ធម្មោ អធិបតេយ្យោ ហោតិ** ឧបាសកមានធម៌ជាអធិបតី គឺថា បើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ជាធំ ជាទីតាំង ជាទីអាងមាំ មិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

**៤.យថា ថាមេន សំវិភាគរតោ វ ហោតិ**

ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិច និងច្រើន បើមានតិច ក៏ធ្វើតិច បើមានច្រើន ក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្តានចិត្តឡើយ ។

**៥.ជិនសាសនំ ជានិតុញ្ច វាយមតិ** ឧបាសកឧស្សាហ៍ព្យាយាម ដើម្បីនឹងឱ្យដឹងច្បាស់ នូវសាសនៈគឺពាក្យប្រៀនប្រដៅពាក្យបណ្ដាំនៃព្រះជិនស្រី ។

**៦.សម្មាទិដ្ឋិកោ វ ហោតិ** ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្ដីពិត ។

**៧.អបគតោ កោតុហលមង្គលិកោ វ ហោតិ** ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើម ឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសល និងអកុសលថាឱ្យផល ។

**៨.ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសកបើទុកជាមានហេតុ គួរដល់នូវសេចក្ដីវិនាសជីវិតក្ដី ក៏មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃ

ជាគ្រូអាចារ្យ ជាទីពឹងរបស់ខ្លួនថា ប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

**៩.សមគ្គារាមោ វា ហោតិ** ឧបាសកមានសេចក្ដីត្រេកអរ ក្នុងសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងគ្នា ។

**១០.សាសនេ ចរតិ** ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធ-សាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា ។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកា គប្បីប្រព្រឹត្តតាមកុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តឧបាសកឧបាសិកា អ្នកប្រតិបត្តិឱ្យសុចរិតផ្លូវផង់ ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង ។

# សំណួរ និង ចម្លើយ

សួរៈ ដូចម្ដេចហៅថា វិបត្តិរបស់ឧបាសក ?

ឆ្លើយៈ ធម្មជាតិដែលញ៉ាំងសីល និងអាជីវធម៌ឱ្យវិនាស ឈ្មោះថា វិបត្តិ ។

សួរៈ វិបត្តិនោះ មានប៉ុន្មានយ៉ាងអ្វីខ្លះ?

ឆ្លើយៈ វិបត្តិ មាន ៥ យ៉ាង គឺ :

១_អស្សទ្ធោ ហោតិ មិនជឿគុណព្រះរតនត្រ័យ ។

២_ទុស្សីលោ ហោតិ ជាអ្នកទ្រុស្តសីល

៣_កោតុហលមង្គលិកោ ហោតិ ជាអ្នកជឿមង្គលភ្ញាក់ផ្អើល ។

៤_មង្គលំ បច្ចេតិ នោ កម្មំ ជឿតែមង្គលភ្ញាក់ផ្អើលមិនជឿកម្មផលឡើយ ។

៥_ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ ឧបាសកស្វែងរកទក្ខិណេយ្យបុគ្គលក្រៅពុទ្ធសាសនា ។

សួរៈ ចុះអ្វីទៅជាគុណសម្បត្តិរបស់ឧបាសក ?

ឆ្លើយៈ ធម្មជាតិដែលញ៉ាំងសីល និងអាជីវធម៌របស់ឧបាសក ឱ្យល្អបរិសុទ្ធផូរផង់ឡើង ហៅថា សម្បត្តិឧបាសក ។

សួរៈ ចុះសម្បត្តិនោះមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ្លើយៈ សម្បត្តិនោះ មាន ៥ យ៉ាង គឺៈ

១.សទ្ធោ ហោតិ ឧបាសកមានសទ្ធា ជឿគុណព្រះរតនត្រ័យ ។

២.សីលវា ហោតិ ជាអ្នកមានសីល

៣.ន កោតុហលមង្គលិកោ ហោតិ មិនជឿមង្គលភ្ញាក់ផ្អើល ។

៤.កម្មំ បច្ចេតិ នោ មង្គលំ ជឿតែកម្មផល មិនជឿមង្គលភ្ញាក់ផ្អើលឡើយ ។

៥.ន ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ មិនស្វែងរកទក្ខិណេយ្យបុគ្គលក្រៅពុទ្ធសាសនា

## បុញ្ញកិរិយាវត្ថុ ១០ គឺ :

១.ទានមយៈ បុណ្យសម្រេចដោយការទាន

២.សីលមយៈ បុណ្យសម្រេចដោយការរក្សាសីល

៣.ភាវនាមយៈ បុណ្យសម្រេចដោយការចំរើនភាវនា

**៤_អបចាយនមយៈ** បុណ្យសម្រេចដោយការគោរពឱនលំទោន ។

**៥_វេយ្យាវច្ចមយៈ** បុណ្យសម្រេចដោយការខ្វល់ខ្វាយ

**៦_បត្តិទានមយៈ** បុណ្យសម្រេចដោយការផ្សាយចំណែកបុណ្យ ។

**៧_បត្តានុមោទនាមយៈ** បុណ្យសម្រេចដោយការអនុមោទនា ។

**៨_ធម្មស្សវនមយៈ** បុណ្យសម្រេចដោយការស្តាប់ធម៌

**៩_ធម្មទេសនាមយៈ** បុណ្យសម្រេចដោយការសំដែងព្រះធម៌ ។

**១០_ទិដ្ឋុជុកម្មៈ** បុណ្យ (សម្រេច) ដោយការធ្វើទិដ្ឋិ (ការយល់ឃើញ) ឱ្យត្រង់

១.ឱភាសោ រស្មីភ្លឺស្វាង កើតអំពីវិបស្សនាចិត្ត ភ្លឺស្វាងជាងអំពីកាលមុន ។

២.បីតិ សេចក្តីឆ្អែតកាយ ឆ្អែតចិត្ត កើតការក្លៀវក្លាជាងដែលធ្លាប់ប្រទះ ធ្លាប់ឃើញមក ។

៣.បស្សទ្ធិ សេចក្តីរម្ងាប់កាយ រម្ងាប់ចិត្ត កើតការក្លៀវក្លាជាងអំពីមុនមក ។

៤.អធិមោក្ខ សទ្ធិន្ទ្រិយយាងចុះ មានកម្លាំងក្លៀវក្លា

៥.បគ្គហោ ព្យាយាមក្លៀវក្លាអាចឱ្យសម្រេចសម្មប្បធាន

៦.សុខំ សេចក្តីសុខកើតឧត្តមក្រៃពេក

៧.ញាណំ បញ្ញាក្នុងគ្រានោះកើតការក្លៀវក្លា ដូចព្រះខ័នកែវវជិរៈរបស់សម្តេចអម្រិន្ទ្រាធិរាជ ។

៨.ឧបដ្ឋានំ សតិចូលទៅតាំងមាំមួនក្លៀវក្លា កើតជាសតិ-បដ្ឋាន ។

៩.ឧបេក្ខា ឧបេក្ខាកើតការក្លៀវក្លា ជាឧបេក្ខាសម្ពោជ្ឈង្គ

១០.**និកន្តិ** សេចក្តីប្រាថ្នា គឺសុខុមតណ្ហា ឱ្យយោគាវចរមានសេចក្តីត្រេកអរក្នុងរូបនិមិត្ត ។

សទ្ធាជឿគុណព្រះរតនត្រ័យទាំង ៣ គឺ ព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ជឿក្នុងទានសីលភាវនា ជឿកម្មនឹងផលនៃកម្ម ១ ។

**សតិ** ការរឭកក្នុងកុសល មានពុទ្ធានុស្សតិជាដើម រហូតដល់អានាបានស្សតិកម្មដ្ឋាន នឹងរលឹកដល់រាងកាយសង្ខារថាមានការកើតចាស់ ឈឺស្លាប់ជាធម្មតា ១ ។

**ហិរិ** ខ្មាសបាប អំពើអាក្រក់ លាមក ១។

**ឱត្តប្បៈ** ខ្លាចបាបអកុសល ពុំហ៊ានធ្វើ ទាំងទីវាល ទាំងទីកំបាំង ១ ។

**អលោភោ** មិនលោបចង់បានទ្រព្យគេមកជារបស់ខ្លួន ១

**អទោសោ** មិនប្រទុស្តរ៉ាយដល់សត្វ និងសង្ខារដែលខ្លួនមិនចូលចិត្ត មិនស្រឡាញ់ ១។

**តត្រមជ្ឈត្តតា** ធ្វើចិត្តឱ្យជាកណ្តាល ១ មិនស្រឡាញ់មិនស្អប់ក្នុងសត្វ និងសង្ខារដែលគួរស្រឡាញ់ គួរស្អប់ ១។

**កាយបស្សទ្ធិ** សេចក្ដីស្ងប់កាយ មិនក្រវល់ក្រវាយ ខ្វល់ខ្វាយដោយទុក្ខវេទនា ១ ។

**ចិត្តបស្សទ្ធិ** សេចក្ដីស្ងប់ចិត្តមិនអណ្ដែតអណ្ដូង រាយមាយទៅក្នុងអារម្មណ៍ទាំពួង ១ ។

**កាយលហុតា** កាយស្រាលចាកបាបអកុសល គឺសេចក្ដីលោភក្រោធវង្វេង ១ ។

**ចិត្តលហុតា** ចិត្តស្រាលចាកបាបអកុសលទាំងពួង ១

**កាយមុទុតា** កាយទន់ទោរឱនទៅក្នុងកុសល មានទានសីលជាដើម ១ ។

**ចិត្តមុទុតា** ចិត្តទន់ទោរឱនទៅក្នុងកុសលទាំងពួង ១

**កាយកម្មញ្ញតា** កាយគួរដល់ការងារដែលជាកុសល គឺមានកំលាំងកាយ មិនទម្រន់ខ្ជិលច្រអូស ១។

**ចិត្តកម្មញ្ញតា** ចិត្តគួរដល់ការងាដែលជាកុសល គឺជាសទ្ធាដែលជឿមាំ មិនងឿយណាយធុញទ្រាន់ ១ ។

**កាយបាគុញ្ញតា** កាយស្ទាត់ជំនាញពូកែក្នុងការកុសល គឺមិនទើសទាល់ ១ ។

**ចិត្តបាគុញ្ញតា** ចិត្តស្ទាត់ជំនាញវៀងវៃ ក្នុងការកុសល មិនមានសេចក្ដីរង្កៀសសង្ស័យ ១ ។

**កាយជុកតា** កាយត្រង់ក្នុងការដែលជាកុសល គឺមិនសំគាល់ថា ធ្ងន់ស្រាល ជិតឆ្ងាយ ត្រជាក់ ក្ដៅ ១ ។

**ចិត្តជុកតា** ចិត្តត្រង់ក្នុងការដែលជាកុសល គឺមិនគិតគេចវេះពីការកុសល ដែលខ្លួនគប្បីធ្វើតាមកម្លាំង ១ ។

**សម្មាវាចា** ពោលវាចាល្អប្រពៃ ប្រកបដោយអង្គ ៤ គឺៈ

មិនពោលកុហក បញ្ឆោតអ្នកដទៃ ១ ។

មិនពោលពាក្យញុះញង់ ស៊កសៀតអ្នកដទៃ ដែលស្រឡាញ់គ្នាឱ្យព្រាត់ប្រាសបាក់បែកពីគ្នា ១ ។

មិនពោលសំដីអាក្រក់ មានជេរត្មះតិះដៀល ជាតិត្រកូលជាដើម ១ ។

មិនពោលពាក្យឥតផលប្រយោជន៍ គឺពោលតែពាក្យមានប្រយោជន៍ ១ ។

សម្មាកម្មន្តោ ធ្វើការងារល្អត្រឹមត្រូវ ប្រកបដោយអង្គ ៣គឺៈ

-មិនសម្លាប់សត្វ ១

-មិនលួចទ្រព្យអ្នកដទៃ ១

-មិនប្រព្រឹត្តកន្លងប្រពៃណីចំពោះស្ត្រី ដែលមានអ្នកថែរក្សាទុក ១ ។

**សម្មាអាជីវោ** ធ្វើការចិញ្ចឹមជីវិតល្អប្រពៃ ប្រកបដោយអង្គ ៥ គឺៈ

-មិនលក់គ្រឿងប្រហារសត្វ និងមនុស្ស ១

-មិនលក់មនុស្សឱ្យទៅកូនបំណុល ឬខ្ញុំកំដរគេ ១

-មិនលក់សត្វមានជីវិត មានមាន់ ទា ជ្រូក គោជាដើម ១

-មិនលក់ទឹកស្រវឹង គឺសុរា និងមេរ័យ ១

មិនលក់ថ្នាំពិសដែលមនុស្ស និងសត្វបរិភោគស៊ីទៅស្លាប់។

**ករុណា** សេចក្តីអាណិតចំពោះមនុស្ស និងសត្វទាំងពួង១

**មុទុតា** សេចក្តីទន់ភ្លន់ រីករាយក្នុងសម្បត្តិនៃមនុស្ស និងសត្វ មិនមានសេចក្តីច្រណែនឈ្នានីស ១។

**បញ្ញា** ការពិចារណារិះរកប្រយោជន៍ ក្នុងជាតិនេះ និងជាតិមុខ ១ ។

សោភណចេតសិកទាំង ២៥ នេះ ជាបុណ្យកុសលសុទ្ធ ។

## អញ្ញសមានាចេតសិក ១៣

**ផស្សោ** ចេតសិកដែលទទួលសម្ផស្សផ្សេងៗ ដោយភ្នែក ត្រចៀក ច្រមុះ អណ្តែត កាយ និងចិត្ត ១ ។

**វេទនា** ចេតសិកដែលសោយអារម្មណ៍ជាសុខ ទុក្ខ ឧបេក្ខា សោមនស្ស ទោមនស្ស ១ ។

**សញ្ញា** ចេតសិកដែលសម្គាល់ដឹងនូវរូប សំឡេង ក្លិន រូប សម្ផស្ស ធម្មារម្មណ៍ ១ ។

**ចេតនា** ចេតសិកដែលដឹកនាំចិត្តឱ្យធ្វើបុណ្យបាបទាំងពួង១

**ឯកគ្គតា** ចេតសិកដែលផ្គងចិត្តទុកឱ្យនៅមាំ ក្នុងបុណ្យបាបទាំងពួង ១ ។

**ជីវិតិន្ទ្រិយ** ចេតសិកដែលចិញ្ចឹមទុកនូវចិត្តជាបុណ្យ និងបាបទាំងពួង ១ ។

**មនសិការោ** ចេតសិកដែលកំណត់នូវអារម្មណ៍ ជាបុណ្យ និងបាបទាំងពួង ១ ។

**វិតក្កោ** ចេតសិកដែលលើកចិត្តឡើងកាន់អារម្មណ៍ ជាបុណ្យ និងបាបទាំងពួង ១ ។

**វិចារោ** ចេតសិកដែលពិចារណានូវអារម្មណ៍ ជាបុណ្យ និងបាបទាំងពួង ១ ។

**អធិមោក្ខោ** ចេតសិកដែលញុំាងចិត្តឱ្យបង្អោនទៅកាន់អារម្មណ៍ហើយប្រកាន់មាំក្នុងបុណ្យ និងបាបទាំងពួង ១ ។

**វីរិយោ** ចេតសិកដែលញុំាងចិត្ត ឱ្យមានសេចក្តីព្យាយាមឧស្សាហ៍ធ្វើការបុណ្យ និងបាបទាំងពួង ១ ។

**បីតិ** ចេតសិកដែលញុំាងចិត្តឱ្យត្រេកអររីករាយ សោមនស្សឆ្អែតចិត្តក្នុងបុណ្យ និងបាបទាំងពួង ១ ។

**ឆន្ទោ** ចេតសិកដែលធ្វើឱ្យចិត្ត ស្រឡាញ់ចូលចិត្តក្នុងការបុណ្យ និងបាបទាំងពួង ១ ។

ចប់ចេតសិកទាំង ១៣

នេះជាបុណ្យក៏បាន ជាបាបក៏បាន កើតទូទៅក្នុងចិត្តបុណ្យ បាបទាំងពួង ។

# អកុសលចេតសិក ១៤

**មោហោ** សេចក្តីវង្វេង បានដល់ អវិជ្ជា មិនមានបញ្ញា ដែលនឹងពិចារណាឱ្យដឹងទាន់ក្នុងសង្ខារ ជាចំណែកខាងក្រៅ និងខាងក្នុងថាជា អនិច្ចំ ទុក្ខំ អនត្តា ១ ។

**អហិរិកំ** មិនមានសេចក្តីខ្មាសដល់បាបកម្ម ហ៊ានធ្វើក្នុង ទីវាល និងទីកំបាំង ដោយកាយ វាចា និងចិត្ត ១ ។

**អនោត្តប្បំ** មិនមានសេចក្តីខ្លាច បាប អំពើអាក្រក់ ដែល ឱ្យផលជាទុក្ខលំបាកក្នុងជាតិនេះ និងជាតិមុខ ១ ។

**ឧទ្ធច្ចំ** សេចក្តីអណ្តែតអណ្តូង រាយមាយ ក្នុងអារម្មណ៍ ផ្សេងៗ ១។

**លោភោ** សេចក្តីលោភចង់បានទ្រព្យរបស់អ្នកដទៃ មក ជារបស់ខ្លួន ១ ។

**ទិដ្ឋិ** ការឃើញខុសចាកធម៌វិន័យពុទ្ធសាសនា គឺឃើញថា លោកនេះទៀង លោកនេះសូន្យជាដើម ១។

**មានោ** សេចក្តីប្រកាន់ខ្លួន បុគ្គល សត្វថា នោះយើង នោះគេ អញជាដើម ១។

**ទោសោ** សេចក្តីក្រោធប្រទូសរ៉ាយ ដល់សត្វនឹងសង្ខារ ទាំងពួងដែលខ្លួនមិនចូលចិត្ត មិនស្រឡាញ់ ១។

**ឥស្សា** សេចក្តីច្រណែនឈ្នានីស បំបែរលាភយស និង សេចក្តីចំរើនរបស់មនុស្ស និងសត្វទាំងឡាយ ឱ្យសល់នូវសេចក្តី វិនាសអន្តរាយ ១ ។

**មច្ឆរិយះ** សេចក្តីកំណាញ់ហួងហែងទ្រព្យ មិនចែកចាយ ឱ្យទាន ធ្វើបុណ្យកុសលដោយហោចទៅសូម្បីតែបរិភោគខ្លួន ឯង ក៏មានសេចក្តីស្តាយអាឡោះអាល័យដែរ ១។

**កុក្កុច្ចំ** សេចក្តីស្ដុតចិត្តទៅក្នុងអារម្មណ៍ដែលខុស ១ ។

**ថីនំ** សេចក្តីរួសរាយចិត្តមិនខ្វល់ខ្វាយ ១ ។

**មិទ្ធំ** សេចក្ដីងោកងក់ ដេកលក់ មិនស្គាល់វេលាព្រឹកល្ងាច មិនគិតនឹងធ្វើកិច្ចការអ្វីមួយ ដែលនាំមកនូវប្រយោជន៍ ១ ។

**វិចិកិច្ឆា** សេចក្ដីសង្ស័យស្ទាក់ស្ទើរក្នុងគុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងសង្ស័យស្ទាក់ស្ទើរ ក្នុងបុណ្យ និងបាប ១។

អកុសល ចេតសិកទាំង ១៤ នេះ ជាបាបអកុសលសុទ្ធ តែងនាំសត្វឱ្យកើតអបាយភូមិទាំង ៤ ។

រូប ២៨ នេះ គឺមហាភូតរូប ៤ ឧបាទាយរូប ២៤ ។

## មហាភូតរូប ៤ គឺ:

**បឋវីធាតុ** ធាតុដី ១៩

**អាបោធាតុ** ធាតុទឹក ១២

**តេជោធាតុ** ធាតុភ្លើង ៤

**វាយោធាតុ** ១៩ ។

## បឋវីធាតុ ១៩ គឺ:

**កេសា** សក់ដែលដុះនៅលើក្បាល ១

**លោមា** រោមដែលដុះសព្វសារពាង្គកាយ វៀរលែងតែបាតដៃ បាតជើង ១។

**នខា** ក្រចកដែលដុះនៅចុងម្រាមដៃជើង ១

**ទន្តា** ធ្មេញដែលដុះនៅក្នុងមាត់សម្រាប់ទំពារអាហារ ១

**តចោ** ស្បែកដែលដុះព័ទ្ធរាងកាយ ១

**មំសំ** សាច់ ១

**នហារូ** សរសៃ ១

**អដ្ឋិ** ឆ្អឹងដែលកើតនៅក្នុងកាយ ១

**អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង ១

**វក្កំ** ទាច ឬតម្រងបស្សាវៈ ១

**ហទយំ** បេះដូង ១

**យកនំ** ថ្លើម ១

**កិលោមកំ** វាវ ១

**បិហកំ** ក្រពះ ១

បច្ចាសំ ស្ងួត ១

អន្តំ ពោះវៀនធំ ១

អន្តគុណំ ពោះវៀនតូច ១

ឧទរិយំ អាហារថ្មី ១

ករីសំ អាហារចាស់ ១ ។

## អាបោធាតុ ១២ គឺៈ

បិត្តំ ប្រមាត់ ១

សេម្ហំ ស្លេស្ម ១

បុព្វោ ខ្ទុះ ១

លោហិតំ ឈាម ១

សេទោ ញើស ១

មេទោ ខ្លាញ់ខាប់ ១

អស្សុ ទឹកភ្នែក ១

វសា ខ្លាញ់រាវ ១

ខេឡោ ទឹកមាត់ ១

សិង្ឃាណិកា ទឹកសំបោរ ១

លសិកា ទឹករំអិល ១

មុត្តំ ទឹកមូត្រ ១ ។

**តេជោធាតុ ៤ គឺះ**

សន្តប្បគ្គិ ភ្លើងដុតកាយឱ្យក្តៅឧណ្ហៗ ១

ជិរណគ្គិ ភ្លើងដុតកាយឱ្យចាស់ជរា ១

បរិទយ្ហគ្គិ ភ្លើងដុតកាយឱ្យក្តៅក្រហល់ក្រហាយ ១

បរិណាមគ្គិ ភ្លើងដុតអាហារឱ្យរលាយ ១ ។

**វាយោធាតុ ៦ គឺះ**

ឧទ្ធង្គមវាតា ខ្យល់បក់ពីជើងឡើងមកក្បាល ១

អធោគមាវាតា ខ្យល់បក់ពីក្បាលចុះមកចុងជើង ១

កុច្ឆិសយវាតា ខ្យល់បក់នៅក្នុងពោះ ១

កោដ្ឋាសយវាតា ខ្យល់បក់នៅក្នុងវៀនធំ ១

អង្គមង្គានុសារិវាតា ខ្យល់នៅក្នុងកាយទូទៅ ១

អស្សាសបស្សាសវាតា ខ្យល់ដកដង្ហើមចេញចូល ១។

**ឧបាទាយរូប ២៤ គឺៈ**

បសាទរូប ៥

ភាវរូប ២

វិសយរូប ៤

វិញ្ញត្តិរូប ២

លក្ខណរូប ៤

វិការរូប ៣

ហទយវត្ថុរូប (បេះដូង) ១

ជីវិតរូប (ទឹកចិញ្ចឹមបេះដូង) ១

អាហាររូប (បាយ និងទឹក) ១

បរិច្ឆេទរូប (ប្រហោងត្រចៀក ច្រមុះ) ១។

## បសាទរូប ៥ គឺៈ

ចក្ខុបសាទ បានដល់ ភ្នែក ១

សោតបសាទ បានដល់ ត្រចៀក ១

ឃានបសាទ បានដល់ ច្រមុះ ១

ជិវ្ហាបសាទ បានដល់ អណ្តាត ១

កាយបសាទ បានដល់ កាយ ១ ។

## ភាវរូប ២ គឺៈ

ឥត្ថិភាវោ បានដល់ ភេទស្រី ១

បុរិសភាវោ បានដល់ ភេទប្រុស ១ ។

វណ្ណោ បានដល់ ពណ៌សម្បុរ ១

គន្ធោ បានដល់ ក្លិន ១

រសោ បានដល់ រស ១

សទ្ទោ បានដល់ សម្លេង ១ ។

# វិញ្ញត្តិរូប ២ គឺ

កាយវិញ្ញត្តិ បានដល់ កំរើកកាយ ១

វចីវិញ្ញត្តិ បានដល់ កំរើកវាចា ១ ។

# លក្ខណរូប ៤ គឺៈ

រូបស្ស ឧច្ចយោ បានដល់ រូបដែលកើតដំបូង ១

រូបស្ស សន្តតិ បានដល់ រូបជាប់តគ្នាមកពីរូបនេះ ១

រូបស្ស ជរតា បានដល់ រូបដែលចាស់គ្រាំគ្រា ១

រូបស្ស អនិច្ចតា បានដល់ រូបដែលមិនទៀងទាត់ មិនប្រែប្រួល ១។

## វិការរូប ៣ គឺៈ

រូបស្ស លហុតា រូបស្រាលក្នុងឥរិយាបទទាំងបួន ១

រូបស្ស មុទុតា រូបទន់បង្អោនទៅក្នុងបដិសណ្ឋារ ១

រូបស្ស កម្មញ្ញតា រូបគួរដល់ការងារ គឺមិនខ្ជិលច្រអូស១

កុសលដែលខ្ញុំបានថ្វាយហើយ ព្រះគុណអើយខ្ញុំសច្ចា
ឧទ្ទិសផលនេះណា ជូនមាតាបិតាជីដូនជីតា
គ្រូអាចារ្យទាំងតូចធំ ញាតិមិត្រគ្រប់និគម
មកជួបជុំទទួលផល ដែលកូនចៅបានធ្វើ
នូវអំពើជាកុសល សូមទានឱ្យបានដល់
ទោះមណ្ឌលឆ្ងាយយ៉ាងណា កុសលទាំងអស់នឹង
សូមទីពឹងលើទេវតា ដែលមានចិត្តមេត្តា
នាំកុសលទាំងនោះទៅ ជូនឱ្យខ្ញុំផងដូចបំណង
កុំបីធ្វេស ថាកូនចៅនៅឯណេះ មិនប្រហែសបញ្ជូនទៅ
សូមមានចិត្តរីករាយ ដោយសប្បាយទទួលយក
កូនចៅបានលៃលក បញ្ជូនទៅលោកគ្រប់គ្នា
ដើម្បីសោយសុខកំសាន្ត សូមឱ្យបាននៅសុខជា
កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង ។

ខ្ញុំសូមអធិដ្ឋានចិត្តចំពោះខ្លួនខ្ញុំ ដែលបានសរសេរនូវធម៌ទាំងអស់នេះ សូមឆ្លងនូវអាយុជីវិតខ្ញុំ កូនចៅបងប្អូន ក្មួយ ព្រមទាំងញាតិទាំងឡាយ ឱ្យរួចផុតនូវអបាយភូមិ ហើយឆ្លងនូវអាយុជីវិតនេះ ឱ្យរួចផុតចាកទុក្ខទោស និងឧបសគ្គ ក្នុងបច្ចុប្បន្ន

អនាគត សូមឱ្យជាតិជាមនុស្សនេះ ជាជាតិចុងក្រោយបំផុត អស់ជីវិតទៅ សូមឱ្យបានទៅទេវលោក បានជួបព្រះអរិយបុគ្គល បានស្តាប់ធម៌ហើយ បានសម្រេចមគ្គផល ព្រះនិព្វានក្នុងទីនោះ។

# ពោលអំពីឥន្ទ្រិយ ២២

ធម្មជាតិដែលជាធំគ្រប់គ្រង ក្នុងកិច្ចផ្សេងៗ ក្នុងនាទីរបស់ខ្លួនហៅថា ឥន្ទ្រិយមាន ២២ ធម្មជាតិជាភូមិ ជាផ្ទៃនៃវិបស្សនាដែលឱ្យចំរើនល្ងូតលាស់ល្អវិបុលលើកឡើងទៅ ដរាបបានលុះលោកុត្តរធម៌ជាទីផុត បានដូចនឹងសំដែងឱ្យប្រកបដូតទៅនេះ :

**១.ចក្ខុន្ទ្រិយ** គឺភាពជាធំរបស់ភ្នែក មាននាទីទទួលពណ៌

**២.សោតិន្ទ្រិយ** គឺភាពជាធំរបស់ច្រមុះ មាននាទីទទួលរស ។

**៣.ឃានិន្ទ្រិយ** គឺភាពជាធំរបស់ច្រមុះមាននាទីទទួលខ្លិន

ឥន្ទ្រិយ គឺភាពជាធំរបស់ច្រមុះមាននាទីទទួលខ្លិន ។

**៤.ជិវ្ហិន្ទ្រិយ** គឺភាពជាធំរបស់អណ្តាតមាននាទីទទួលរស

**៥.កាយិន្ទ្រិយ** គឺភាពជាធំរបស់កាយ មាននាទីទទួលសម្ផស្ស ។

៦.ឥត្ថិន្ទ្រិយ ភាពជាធំរបស់ស្រី មាននាទីទទួលសំដែងលក្ខណៈ កិរិយារបស់ស្រី ។

៧.បុរិសិន្ទ្រិយ គឺភាពជាធំរបស់ប្រុស មាននាទីសំដែងលក្ខណៈ កិរិយា អាការៈរបស់ប្រុស ។

៨.ជីវិតិន្ទ្រិយ គឺភាពជាធំរបស់ជីវិត មាននាទីរក្សារូប នាម

៩.មនិន្ទ្រិយ គឺភាពជាធំរបស់ចិត្តមាននាទីដឹងអារម្មណ៍

១០.សុខិន្ទ្រិយ គឺភាពជាធំរបស់សុខវេទនា មាននាទីសប្បាយ ។

១១.ទុក្ខិន្ទ្រិយ គឺភាពជាធំរបស់ទុក្ខវេទនា មាននាទីមិនសប្បាយ ។

១២.សោមនស្សិន្ទ្រិយ គឺភាពជាធំរបស់សោមនស្សវេទនា មាននាទីត្រេកអរ។

១៣.ទោមនស្សិន្ទ្រិយ គឺភាពជាធំរបស់ទោមនស្ស-វេទនា មាននាទីតូចចិត្ត ។

**១៤.ឧបេក្ខិន្ទ្រិយ** គឺភាពជាធំរបស់ឧបេក្ខាវេទនា មាននាទីព្រងើយៗ ។

**១៥.សទ្ធិន្ទ្រិយ** គឺភាពជាធំរបស់សទ្ធា មាននាទីជឿជ្រះថ្លា ។

**១៦.វីរិយិន្ទ្រិយ** គឺភាពជាធំរបស់វីរិយៈមាននាទីព្យាយាម

**១៧.សតិន្ទ្រិយ** គឺភាពជាធំរបស់សតិ មាននាទីតាមទាន់បច្ចុប្បន្នហេតុ ។

**១៨.សមាធិន្ទ្រិយ** គឺភាពជាធំរបស់សមាធិ មាននាទីតាំងមាំក្នុងចិត្ត ។

**១៩.បញ្ញិន្ទ្រិយ** គឺភាពជាធំរបស់បញ្ញា មាននាទីដឹងត្រៃលក្ខណ៍ ។

**២០.អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ** គឺភាពជាធំរបស់សោតាបត្តិមគ្គញ្ញាណ មាននាទីទៅដឹងព្រះនិព្វាន កាត់អកុសលចិត្តបាន ៥ ។

២១.**អញ្ញិន្ទ្រិយ** គឺភាពជាធំរបស់សោតាបត្តិផលញ្ញាណ រហូតដល់អរហត្តមគ្គញ្ញាណ មានទាទីដឹងព្រះនិព្វាន កាត់អកុសល តាមលំដាប់ ។

២២.**អញ្ញាតាវិន្ទ្រិយ** គឺភាពជាធំ របស់អរហត្តផលញ្ញាណ មានទាទីដឹងព្រះនិព្វាន នឹងកាត់អកុសលចិត្ត ១២ អស់រលីង ។

## ទំនួញប្រេត កេសណីស្តាយក្រោយ

កេសណីស្តាយក្រោយ ដឹងហើយថា ឱះឱអនិច្ចា រូបអញអើយ កាលពីនៅរស់ធ្វើព្រងើយ ទានមិនដែលឱ្យ សីលមិនដែលធ្វើ ឆោតអើយសែនឆោតអ្វីដល់ម្លេះ បើបានជាចេះ ឥតអំពើទានសីលភាវនាមិនដែលធ្វើ នេះមកពីភ្លើភ្លេចរូបកាយ គិតស្មានថា ខ្លួនមិនទាន់ស្លាប់ ប្រឹងតែកាយកាប់កាត់នាយអាយ មិនដឹងថាខ្លួនឯងអន្តរាយ ចិត្តចេញចោលកាយ រូបស្គកស្គីង សូម្បីខោអាវកូនចៅដាក់ គេស្លៀកគេពាក់ខ្លួនមិនដឹង នឹងនឹករកអ្វីមកទីពឹងម្ទឹងៗ អញអើយពេញហៅខុស ។

ឥឡូវអញអើយកើតជាប្រេត ជាហេតុស្រែកឃ្លាន គ្មានសន្តោស រកកូនយូរថ្ងៃមិនឃើញសោះ បាត់មុខកូនប្រុសណាកូនអើយ ខែនេះគេធ្វើបុណ្យភ្ជុំ ម្តាយខ្ញុំដើររកច្រើនវត្តហើយ បាត់មុខកូនមិនឮឆ្លើយ កយអើយៗ កយ អ្នកទៅណា កូនឯងមិនធ្វើទាននឹងគេ ម្តាយពោះទទេឃ្លានអស្ចារ្យ ប្រាំពីរវត្តហើយកយទៅណា ម្តាយឃ្លានអាហារណាស់កូនអើយ កូនគេញាតិ គេមកជួបជុំ ចុះអាកយកូនខ្ញុំធ្វើកន្តើយ គ្មានគិតភ្ជុំភ្ជរនឹងគេឡើយ កូនអើយខំធ្វើនឹងគេទៅ ឈប់លេងឈប់ផឹកឈប់សម្លាប់ ពុទ្ធដិកា

ថ្លែងប្រាប់ចំជាត្រូវ កូនធ្វើសីលទានកូនកុំនៅ បញ្ជូលដល់ខ្ញុំនឹង ម៉ែផង សម្បត្តិដែលម៉ែបានចែកឱ្យកូនអើយ ម្ដេចឡើយមិនគិត ផង មួយឆ្នាំមិនដែលចូលវត្តម្ដង ម្ដាយឥតកន្លងរកស៊ីគ្នាន ។

កូនពៅស្រីខ្ញុំវាទៅណា គ្មានគិតវត្តវាធ្វើសីលទាន សម្បត្តិ ម៉ែចែកគួរតែមាន ដើរលេងរាំច្រៀងចោលកិច្ចការ គិតតែស្លៀក ពាក់លាបក្រមួន គ្មានសង្វេគខ្លួន គិតអនិច្ចាបើត្រង់រាំច្រៀងចេះ ណាស់ណា បើត្រង់ធម៌អាថ៌គ្មានមួយម៉ាត់ ដូច្នេះសប្បុរសផង ទាំងឡាយ ចូរខំខ្វល់ខាយលះបង់កាត់ ធ្វើបុណ្យឱ្យទានជាសម្បត្តិ ប្រយ័ត្នស្លាប់ទៅយំស្ដាយក្រោយ កុំចាំកូនចៅគេធ្វើឱ្យ ប្រយ័ត្ន ក្រែងធ្លោយដូចកេសណី ខ្លួនស្លាប់ជាខ្មោចដើររាល់ថ្ងៃ ស្រែក ហៅកយថ្ងៃ មិនឮឆ្លើយ ត្រូវប្រុងប្រៃកាយកុំព្រងើញ ធ្វើសីល ធ្វើទានទុកឱ្យហើយ សមាធិបញ្ញាទុកជាត្រើយ រំលត់អស់ហើយ និព្វានហោង ។

ជាទីបញ្ចប់សូមឱ្យការសរសេរ ទំនួញប្រែតកេសណីស្ដាយ ក្រោយរបស់ខ្ញុំនេះ ឱ្យបានជាគតិ ដាស់តឿនដល់សប្បុរសទាំង-ឡាយកុំឱ្យភ្លេចខ្លួន នឹងបានជាប្រយោជន៍ ចម្រើនសេចក្ដីសុខ ដល់បុព្វការីជន ដែលបានបែកបាក់ចែកឋានទៅផង ។